# ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៨

## បង្ក្រាបមេខ្យល់១ក្រុម ករណីនាំមនុស្សឆ្លងដែនដោយខុសច្បាប់យកទៅរៀបអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈទៅប្រទេសចិន

http://cambodiapolice.com/ 1:17 pm 3 មិថុនា 2018

**ភ្នំពេញ ៖** កម្លាំងនគរបាលនាយកដ្ឋានប្រឆាំងការជួញដូរ និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ សហការជាមួយស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ និងស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺ បានបង្ក្រាបមេខ្យល់ ដែលបានធ្វើសកម្មភាពនាំនារីខ្មែរ ៣០នាក់ ចាប់តាំងពីឆ្នាំ២០១៤ ដល់ខែឧសភា ឆ្នាំ២០១៨ យកទៅលក់អោយបុរសជនជាតិចិន នៅប្រទេសចិនធ្វើជាប្រពន្ធ ។ ប្រតិបត្តិការនេះ ធ្វើឡើងនៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ ដឹកនាំបញ្ជាផ្ទាល់ដោយ ឯកឧត្តម ឧត្តមសេនីយ៍ឯក ប៉ុល ភិធេយ្យ ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរ និងការពារអនីតិជន និងដោយមានការសម្របសម្រួលពីលោក សៀង សុខ ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

នគរបាលនាយកដ្ឋានប្រឆាំងការជួញដូរ បានឲ្យដឹងថា ក្នុងប្រតិបត្តិការខាងលើ សមត្ថកិច្ចបានចាប់ខ្លួនជនសង្ស័យ ៤នាក់ ៖ ទី១.ឈ្មោះ ស៊ូ សុភាព ហៅ ស្រីតា ភេទស្រី អាយុ ៣៧ឆ្នាំ ជនជាតិខ្មែរ (មេក្លោង) ,ទី២.ឈ្មោះ ឃួន សារ៉ាវុធ ភេទប្រុស អាយុ ៤៨ឆ្នាំ ជនជាតិខ្មែរ (អ្នកសម្របសម្រួល), ទី៣.ឈ្មោះ សុខ សុទ្ធារក្ស ភេទប្រុស អាយុ ៣៤ឆ្នាំ ជនជាតិខ្មែរ (អ្នកស្រ្តីខ្មែរទៅចិន) និងទី៤.ឈ្មោះ ផល់ ផា ភេទប្រុស អាយុ ៣៤ឆ្នាំ ជនជាតិខ្មែរ (ជាអ្នកដឹកជញ្ជូន) ។ អ្នកទាំង៤នាក់ នេះស្នាក់នៅផ្ទះជួលលេខ ៩៤B សង្កាត់ផ្សារដេប៉ូទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ នគរបាលនាយកដ្ឋានប្រឆាំងការជួញដូរ បានបន្តថា តាមការស្រាវជ្រាវជនសង្ស័យខាងលើបានធ្វើសកម្មភាព ឃោសនា ជ្រើសរើស នាំនារីខ្មែរបានចំនួន៣០នាក់ ចេញពីប្រទេសកម្ពុជា នាំឆ្លងដែនដោយសុខច្បាប់ទៅប្រទេសចិន ដើម្បីរៀបអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈ ដោយបានតម្លៃក្នុងម្នាក់ៗចាប់ពី ៥០០០ ដល់១០០០០ដុល្លារអាមេរិក ។ នគរបាលដដែលបញ្ជាក់ថា ក្នុងប្រតិបត្តិការនេះ សមត្ថកិច្ចបានធ្វើការដកហូត រថយន្តសម្រាប់ដឹកជញ្ជូនស្ត្រីខ្មែរ ចំនួន ២គ្រឿង (១គ្រឿង ម៉ាក Lexus RX330 ពណ៌ស្វ ស្លាកលេខ ភ្នំពេញ 2AS-8028 និង១គ្រឿងទៀតម៉ាក Lexus RX300 ពណ៌ខ្មៅ ស្លាកលេខភ្នំពេញ 2N-6180) និងលុយ ៩៥០០ដុល្លារអាមេរិក រួមនឹងទូរស័ព្ទដៃចំនួន ៨គ្រឿង ។

បច្ចុប្បន្នជនសង្ស័យទាំង ៤នាក់ រួមទាំងវត្ថុតាង ត្រូវបានកម្លាំងនគរបាលនាយកដ្ឋានប្រឆាំងការជួញដូរ និងការពារអនីតិជន បញ្ជូនទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ៕

## ក្រោយសួរនាំហើយ ទើបដឹងថាចាញ់បោកគេ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៨ ម៉ោង ១៨:០២ ម៉ុត សារុន

ខេត្តបន្ទាយមានជ័យ ៖ អំពើឆបោកកើតមានគ្រប់រូបភាព បើសិនជាយើងខ្វះការប្រុងប្រយ័ត្ន និងខ្វះការយល់ដឹងឆាប់ជឿគេពេក។ ជាក់ស្តែងជនរងគ្រោះជាពលករខ្មែរប្រុសស្រី៥នាក់ត្រូវបាននគរបាលអន្តោប្រវេសន៍ច្រកទ្វារអន្តរជាតិប៉ោយប៉ែតហៅសួរនាំ ខណៈពួកគេកាន់កាតចេញចូលដីថៃ (Immigration Card) ខុសប្រក្រតីមិនមែនជារបស់ខ្លួន នៅទីតាំងត្រួតពិនិត្យលិខិតធ្វើដំណើរចេញក្រៅប្រទេសជាប់និងគល់ស្ពានមិត្តភាពកម្ពុជា-ថៃនៃច្រកទ្វារអន្តរជាតិប៉ោយប៉ែតខ្លងលឹកថ្ងៃទី៣ មិថុនា ឆ្នាំ២០១៨នេះ។ ពលករជនរងគ្រោះទាំង៥នាក់ ប្រុស៤ ស្រី១នាក់ ដោយក្នុងចំណោមនេះមានកុមារ២នាក់។ ពលកររងគ្រោះទាំងនេះត្រូវបានសមត្ថកិច្ចត្រួតពិនិត្យឯកសារប៉ះចំពួកគេកាន់កាតចេញចូលដីថៃក្លែងក្លាយ មិនមែនជាឈ្មោះ និងរូបពួកគាត់ ក្រោយចូលទិញសំបុត្រចេញចូលដីថៃតម្លៃម្នាក់១០០រៀលដូចគេឯង ។

ឈ្មោះចិន សំបូរ ភេទប្រុស អាយុ៤០ឆ្នាំ មកពីភូមិ និងឃុំហាល ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ បានប្រាប់សមត្ថកិច្ចថា ខ្លួនប្រុងធ្វើដំណើរទៅធ្វើការនៅខេត្តសាមុទ្រសាខនជាប់ក្រុងបាងកក ប៉ុន្តែពុំមានឯកសារស្របច្បាប់

នោះទេ។ ពលករូបនេះប្រាប់ថា ខណៈធ្វើដំណើរមកដល់ព្រំដែននៅក្រុងប៉ោយប៉ែតក៏ជួបមេខ្យល់ម្នាក់និយាយលួងលោមគាត់ដោយប្រាប់ថា គេយកតែ១០០០បាតប្រាក់ថៃទេ គឺមានកាតអាចទិញសំបុត្រដើរចេញចូលដីថៃបាន ។

ក្រុមពលកររងគ្រោះផ្សេងៗទៀតក៏លើកឡើងដូចពលករម្នាក់ខាងលើដែរ គឺគ្រប់គ្នាត្រូវគេឆបោកយកអស់ម្នាក់១០០០បាត លុះទិញសំបុត្ររួចដើរចេញមិនទាន់ដល់លើស្ពានព្រំដែនផង ត្រូវសមត្ថកិច្ចហៅសួរនាំ ទើបដឹងថាចាញ់បោកគេ ។ ពលករដែលជាជនរងគ្រោះទាំងអស់សមត្ថកិច្ចអន្តោប្រវេសន៍មិនបានយកទោសពៃរ៍អ្វីឡើយគឺគ្រាន់តែឲ្យអង្គុយចាំមើលមុខអ្នកឆបោក បើឃើញ សមត្ថកិច្ចនឹងឃាត់ខ្លួនយកប្រាក់ឲ្យវិញ និងចាត់វិធានការលើជនឆបោកនោះតាមផ្លូវច្បាប់ ។

យ៉ាងណាក៏ដោយ មកទល់នឹងរសៀលថ្ងៃដដែលសមត្ថកិច្ចមិនទាន់ឃាត់បានជនសង្ស័យណាម្នាក់នៅឡើយទេ ហើយអះអាងថា ក្រោយសួរនាំធ្វើកំណត់ហេតុរួច ពលករជាជនរងគ្រោះ និងឲ្យត្រឡប់ទៅលំនៅដ្ឋានវិញរៀងខ្លួនៗ៕

## លក្ខខណ្ឌប្តូរនិយោជិត(ថៅកែថ្មី)ចំពោះពលករចូលមកធ្វើការតាមរយៈMOU

http://www.pheaktraprak.com June 2, 2018

លក្ខខណ្ឌប្តូរនិយោជិត (ថៅកែថ្មី) ចំពោះពលករចូលមកធ្វើការតាមរយៈMOU មានដូចខាងក្រោម÷

១-និយោជិកឈប់ជួលឬនិយោជិតស្លាប់បាត់បង់ជីវិត។

២-ក្រុមហ៊ុនក្ស័យធន

៣-និយោជិតធ្វើទារុណកម្មឬវាយដំលើរៀងកាយពលករ។

៤-និយោជិតមិនគោរពតាមកិច្ចសន្យាជួលឬមិនគោរពតាមច្បាប់គ្រប់គ្រងពលករ។

៥-ឲ្យពលករធ្វើការនៅកន្លែងដែលប្រថុយនិងគ្រោះថ្នាក់ឬកន្លែងធ្វើការស្ថិតក្នុងស្ថានភាពប៉ះពាល់ដល់សុខភាពផ្លូវកាយនិងផ្លូវចិត្តរបស់ពលករ។

៦-និយោជិតថ្មីព្រមចេញថ្លៃប្រាក់សំណងដល់និយោជិតដើមដែលធ្វើឯសារឲ្យពលករ។

ក្នុងករណីខាងលើនេះពលករត្រូវទំនាក់ទំនងទៅក្រុមហ៊ុនដែលនាំខ្លួនចូលមកធ្វើការ ដើម្បីប្តូរថៅថ្មីក្នុងរយៈ៣០ថ្ងៃ។

## ប្រទះឃើញសាកសពបុរសពលករខ្មែរម្នាក់,អណ្តែតទឹកនៅក្បែរកំពង់ផែរទូកខេត្តត្រាត

http://www.pheaktraprak.com June 3, 2018

កាលពីវេលាម៉ោង១០:០០ព្រឹក ថ្ងៃអាទិត្យ ទី០៣ ខែមិថុនា ឆ្នាំ២០១៨ មានករណីប្រទះឃើញសាកសពបុរសពលករខ្មែរម្នាក់ ត្រូវបានគេស្គាល់ឈ្មោះ គឿន ភូ អាយុ ៣៨ឆ្នាំ ជាកម្មករធ្វើការលើទូកនេសាទត្រីនៅក្នុងខេត្តត្រាត ត្រូវបានគេប្រទះឃើញស្លាប់អណ្តែតទឹកនៅក្បែរកំពង់ផែរសិនប្រាក់សីតស្ថិតនៅក្នុងខេត្តត្រាតប្រទេសថៃ ។ យោងតាមប្រភពបឋមពីសមត្ថកិច្ចបានសន្និដ្ឋានថាអ្នកស្លាប់ប្រហែលជាធ្លាក់ទឹកលង់ស្លាប់ បច្ចុប្បន្នសាកសពអ្នកស្លាប់ត្រូវបានសមត្ថកិច្ចយកទៅរក្សាទុកនៅមន្ទីរពេទ្យ ដើម្បីធ្វើការកោសល្យវិច័យរកមូលហេតុនៃការស្លាប់បាត់បង់ជីវិត។

## ក្រសួងការងារ បញ្ចេញឈ្មោះក្រុមហ៊ុនដែលបញ្ជូនពលករទៅថៃស្របច្បាប់

http://kleykley.sabay.com.kh/ ថ្ងៃសុក្រ, 1 មិថុនា 2018 10:30

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ បានបញ្ចេញឈ្មោះក្រុមហ៊ុនចំនួន៦៧ ដែលមានសិទ្ធិជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសថៃ។ ក្រសួងបញ្ជាក់ថា រាល់ក្រុមហ៊ុនឯកជនទាំងឡាយណា ដែលពុំមានឈ្មោះក្នុងបញ្ជីខាងក្រោមនេះ គឺចាត់ទុកថា ជាក្រុមហ៊ុនខុសច្បាប់ ដោយក្រសួងបានស្នើឱ្យសាធារណជនរាយការណ៍ជាបន្ទាន់ ទៅលេខទូរសព្ទ ០២៣ ៨៨០

៤៧៤ និងទាក់ទងទៅមន្ទីរការងារទាំង២៥រាជធានី-ខេត្ត នៅរៀងរាល់ម៉ោងធ្វើការ។ ខាងក្រោមនេះ គឺជាឈ្មោះ និង អាសយដ្ឋានរបស់ក្រុមហ៊ុនស្របច្បាប់ទាំង ៦៧៖

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សេចក្តីជូនដំណឹង

## ស្តីពី

## ទីភ្នាក់ងារជ្រើសរើសឯកជនដែលបានទទួលការអនុញ្ញាតឱ្យធ្វើការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅព្រះរាជាណាចក្រថៃឡង់ដ៍

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនសាធារណជនទាំងអស់ឱ្យបានជ្រាបថា ទីភ្នាក់ងារជ្រើសរើសឯកជនដែលមានសិទ្ធិឱ្យធ្វើការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅព្រះរាជាណាចក្រថៃឡង់ដ៍ មានចំនួន ៦៧ ក្រុមហ៊ុន ដូចខាងក្រោម៖

| ល.រ No. | លេខបញ្ជី Registration Number | ឈ្មោះក្រុមហ៊ុន Company Name | ឆ្នាំចុះបញ្ជី Year of Registration | អាសយដ្ឋាន Address | លេខទូរស័ព្ទ Telephone |
|---|---|---|---|---|---|
| 1 | 001 | ហ្យូមែន ផៅវ័រ<br>Human Power CO., LTD. | 2006 | ផ្ទះលេខ៥១ ផ្លូវលេខ ៣៧១ ក្រុមទី៤ ភូមិត្រា សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ<br>No. 51, St. 371, Trea Village, Sangkat Steung Meanchey, Khan Meanchey, Phnom Penh | 023 6482345/ 015660 555 |
| 2 | 003 | ហ្វីលីម័រ ខេមបូឌា<br>Philimore Cambodia CO., LTD. | 2006 | អគារលេខ១៨G ផ្លូវឧកញ៉ាឌួងងៀប II ភូមិ ពោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ<br>Building 18G, St. Doung Ngeab 2 , Sangkat Chom Chao, Khan Posenchey, Phnom Penh | 023 6600123/ 012 601 123/ 012 601 123 |
| 3 | 004 | ហ្យូមែន រីសសស៍ ឌីវេឡុបមេន<br>Human Resource Development CO., LTD. | 2006 | ផ្ទះលេខ ១៥៨០ ផ្លូវជាតិលេខ៥ ភូមិសាមគ្គី សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ<br>No. 1580, National Road 5, Sangkat Russey Keo, Khan Russey Keo, Phnom Penh | 023 6388377/ 088 9999744/ 012 783 886 |
| 4 | 005 | ខេមបូឌាន លេប័រ ស៊ីបផ្លាយ ភីធីអ៊ាយ<br>Cambodian Labour Supply PTY LTD. | 2006 | ផ្ទះលេខ ២៧ ផ្លូវលេខ ៨៩ ភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ<br>No.27, St. 89, Sangkat Beung Tompun, Khan Meanchey, Phnom Penh | 017 666 938/ 012 370 374/ 017 666810 |
| 5 | 006 | ឈុន ហុង មេនផៅវ័រ<br>Chhun Hong Manpower CO., LTD. | 2006 | ផ្ទះលេខ ៨៨ ផ្លូវវេងស្រេងភូមិ ដំណាក់ធំ(សុឡា) សង្កាត់ស្ទឹងមានជ័យខណ្ឌមានជ័យ<br>No. 88, St. Veng Sreng, Sangkat Steung Meanchey, Khan Meanchey, Phnom Penh | 092 678 888/ 023 428 653/ 012 693 398 |
| 6 | 007 | ថប មេនផៅវ័រ<br>Top Manpower CO., LTD. | 2006 | ផ្ទះលេខ ៣៤-A ផ្លូវ៤៤អ៊ឹមសេភូមិឫស្សី១ សង្កាត់ ស្ទឹងមានជ័យ ខណ្ឌមានជ័យ<br>No. 3-4A, St. 44, Sangkat Steung Meanchey, Khan Meanchey, Phnom Penh | 097 9322322/ 012 922 322/ 081 990 077 |
| 7 | 008 | ស៊ី ឌី អិម ត្រេឌីង មេនផៅវ័រ<br>CDM Trading Manpower CO., LTD. | 2006 | ផ្ទះលេខ ២១៩ ផ្លូវលេខ ១៥០ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក<br>No. 219, St. 150, Sangkat Tek Laak II, Khan Toul Kork, Phnom Penh | 023 8863747/ 012 793 999/ 078 950 999 |

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣)៨៨ ៤៣ ៧៥ និងទូរសារៈ [illegible]

| | | | | | |
|---|---|---|---|---|---|
| 8 | 009 | ម៉ី យន សឺវីស ខូអិលធីឌី<br>Mey Yorn Service CO., LTD. | 2006 | ផ្ទះលេខ ៦៥ ផ្លូវលេខ ៦០៦ សង្កាត់បឹងកក់២ ខណ្ឌទួលគោក<br>No. 65, St. 606, Sangkat Bueng Kak II, Khan Toul Kork, Phnom Penh | 012255955/<br>023 6376386/<br>017 366 626 |
| 9 | 010 | អេស.ធី.ភី អ៊ិនធើណេសិនណល (ខេមបូឌា) ផាប់ប្លិក<br>STP International Cambodia Public CO., LTD. | 2006 | ផ្ទះលេខ T១៦៨ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន<br>No. T168, Preah Norodom Blvd, Sangkat Tunle Basac, Khan Chamkamorn, Phnom Penh | 023 993 922/<br>016 282 442/<br>092 363 168 |
| 10 | 011 | អ៊ឹង រិទ្ធី គ្រុប<br>Ung Rithy Group CO., LTD. | 2006 | លេខ ១៧៤ ផ្លូវលេខ ២១ BTZ ភូមិសន្សំកុសល១ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ<br>No. 174, St. 21BTZ, Sangkat Beung Tompun, Khan Meanchey, Phnom Penh | 012 365777/<br>097 7273007/<br>012 686 996 |
| 11 | 012 | សឹកសេស មេនផៅវ័រ សឺវីស<br>Success Manpower Services CO., LTD. | 2006 | ផ្ទះលេខ៥១-៥៣ ផ្លូវណតប្រ៊ីជ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ<br>No. 51-53, St. North Bridge, Sangkat Tek Thla, Khan Sen Sok, Phnom Penh | 023 969 709/<br>099 799 799/<br>069 999 990 |
| 12 | 013 | ស៊ីប្រូ<br>C-Pro CO., LTD. | 2007 | ផ្ទះលេខ ១៩៥ BEO ផ្លូវលេខ ៣៤៨ សង្កាត់ទួលស្វាយព្រៃ ២ ខណ្ឌចំការមន<br>No. 195 BEO, St. 348, Sangkat Toul Svay Prey II, Khan Chamkamorn, Phnom Penh | 023 211 398/<br>0719397575/<br>015 665 411 |
| 13 | 015 | ម៉ាខេម ហ្យូមេនរីសស៍ ម៉េនេចមេន & ខនសាល់ធេន<br>Makam Human Resource Management Consultant Co., Ltd. | 2007 | ផ្ទះលេខ ៤៥A ផ្លូវលេខ ៤៦៤ សង្កាត់ទួលទំពូងទី២ ខណ្ឌចំការមន<br>No. 45 A, St. 464 , Sangkat Toul Tom Pong II, Khan Chamkamorn, Phnom Penh | 016 573 016/<br>098 333 367/<br>097 7061097 |
| 14 | 016 | ១៦៨ មេនផៅវ័រ សឹបផ្លាយ ខូអិលធីឌី<br>168Manpower Supply CO., LTD. | 2008 | ផ្ទះលេខ ៥D ៦D ផ្លូវសហព័ន្ធរុស្ស៊ី ភូមិព្រៃទ្រា សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ<br>No. 5-6 D, Rusian Federation Blvd, Sangkat Chom Chao, Khan Posenchey, Phnom Penh | 092 222 807/<br>097 2222807/<br>010 222 807 |
| 15 | 017 | ស៊ី អ៊ី ស៊ី អេច(ខេមបូឌា)<br>CECH (Cambodia) CO., LTD. | 2008 | ផ្ទះលេខ ៥៨៦ ភូមិស្នែងរលើង ក្រុមទី៥ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ<br>No. 586, Sneng Rom Lerng Village, Sangkat Tek Thla, Khan Sen Sok, Phnom Penh | 012 779205 /<br>093 630399 /<br>088 999 0212 |
| 16 | 019 | អេភី ធីអេសអ៊ី&ស៊ី (ខេមបូឌា) រីសស៍ ខូអិលធីឌី<br>A.P.T.S.E & C (Cambodia) Resources CO., LTD. | 2009 | ផ្ទះលេខ ១៦៩, ១៧១, ១៧៣ ផ្លូវលេខ៣ ភូមិសំបួរ សង្កាត់ដង្កោ ខណ្ឌដង្កោ<br>No.169,171,173, St. No 3, Sangkat DoungKor, Khan DoungKor, Phnom Penh | 077 7777 43/<br>097 7777468/<br>012 439 776 |
| 17 | 020 | យ៉ប អេស៊ា លីមីតធីត (ខេមបូឌា)<br>Job Asian (Cambodia) CO., LTD. | 2009 | ផ្ទះលេខ ២៨ AEO ភូមិម៉ុល សង្កាត់ដង្កោ ខណ្ឌដង្កោ<br>No. 28 AE0, Mol Village, Sangkat DoungKor, Khan DoungKor, Phnom Penh | 097 5353537/<br>097 793 2222<br>/017 839 567 |
| 18 | 021 | ជី ភី ជី ស៊ី អ៊ិនធើណេសិនណល ភីធីអ៊ី<br>G P G C International PTE., LTD. | 2009 | អគារលេខ ២៨១ ផ្លូវលេខ៦៨K សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ<br>Building 281, St. 68 K, Sangkat Kakab, Khan Posenchey, Phnom Penh | 097 6202095/<br>088 877 3965 |
| 19 | 022 | ម៉ាស្ទ័រ ខេម ហ្យូមេន រីសស៍<br>Master Cam Human Resource CO., LTD. | 2010 | ផ្ទះលេខ ៥B ផ្លូវលេខ ៤៣២ សង្កាត់បឹងត្របែក ខណ្ឌចំការមន<br>No. 5 B, St. 432, Sangkat Beung Trabek, Khan Chomkamorn, Phnom Penh | 011 715 677/<br>012 996 614/<br>093 766 357 |
| 20 | 023 | យូនីខន មេនផៅវ័រ ខូ អិលធីឌី<br>Unicorn Manpower CO., LTD. | 2010 | ផ្ទះលេខ ១១៧ ផ្លូវលេខ០៤ ភូមិទួលគោក សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ<br>No. 117, St. 04, Sangkat Toul Sangke, Khan Russey Keo, Phnom Penh | 023 6365633/<br>087 878 801/<br>096 7500 600 |
| 21 | 024 | អេស ខេ អិម អិម អ៊ិនវេសមេន គ្រុប<br>SKMM Investment Group CO., LTD. | 2010 | លេខ ១១០៤ ផ្លូវជាតិលេខ ០៥ សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ<br>No. 1104, National Road No 5, Sangkat Russey Keo, Khan Russey Keo, Phnom Penh | [illegible] 8887791/<br>012 [illegible] 899 |
| 22 | 025 | អិន.អេ.អេស មេនផៅវ័រ ខូអិលធីឌី<br>N.A.S Manpower CO., LTD. | 2010 | ផ្ទះលេខ ៥២ C ផ្លូវបេតុង សង្កាត់ដង្កោ ខណ្ឌដង្កោ<br>No. 52C, St. Betong, Sangkat DoungKor, Khan DoungKor, Phnom Penh | [illegible]555[illegible]/<br>[illegible]217 9[illegible] |

| | | | | | |
|---|---|---|---|---|---|
| 23 | 026 | អាយ អាយ អេស ខមភេនី<br>I I S Company LTD. | 2010 | ផ្ទះលេខ ១៥ ផ្លូវជាតិលេខ ៥ ភូមិសាមគ្គី សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ<br>No. 15, National Road No 5, Sangkat Russey Keo, Khan Russey Keo, Phnom Penh | 016 891 912 /<br>077 855 552 /<br>088 755 5525 |
| 24 | 029 | សេនជូរី (ខេមបូឌា) មេនផៅវ័រ<br>Century (Cambodia) Manpower CO., LTD. | 2011 | ផ្ទះលេខ៤C ផ្លូវលេខ៤៣២ ក្រុម៥ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ<br>No. 4C, St. 432, Sangkat Steung Meanchey, Khan Meanchey, Phnom Penh | 012 843 456/<br>066 51 9999 |
| 25 | 030 | អេល.ជី ខនសាល់តេន<br>LG. Consultant CO., LTD. | 2011 | ផ្ទះលេខ២៤៣-២៤៤ ផ្លូវលេខ ៥៩៨ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ<br>No. 243-244, St. 598, Sangkat Toul Sangke, Khan Russey Keo, Phnom Penh | 023 966 168/<br>015 811 111/<br>077 811 111 |
| 26 | 031 | ស៊ី.ធី.អេស៊ា លេប័រ<br>C.T. Asia Labour CO., LTD. | 2011 | ផ្ទះលេខ ៩៥៧ A ផ្លូវជាតិលេខ ០៥ ភូមិមិត្តភាព សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ<br>No. 957 A, National Road No 5, Sangkat Russey Keo, Khan Russey Keo, Phnom Penh | 089 848 409/<br>077 709 280/<br>077 886 762 |
| 27 | 032 | ភី អាយ ធី ធី ខេមបូឌា<br>P I T T Cambodia CO., LTD. | 2011 | ផ្ទះលេខ ១៧ អា ផ្លូវលេខ១៧៨ សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ<br>No.17 A, St. 178, Sangkat Phsar Thmey III. Khan Daun Penh, Phnom Penh | 023 214 454/<br>012 723 366 |
| 28 | 033 | ទូច ម៉ាណាក់ មេនផៅវ័រ ស៊ីបផ្លាយ<br>Touch Manak Manpower Supply CO., LTD. | 2011 | អគារលេខ៦៥E0E1 ផ្លូវលេខ២០១១ ភូមិគោកឃ្លាំង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ<br>Building 65 Eo, E1, St. 2011, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh | 017 9099697/<br>0975978888/<br>081 430 4342 |
| 29 | 034 | ភ្នំពេញ លេប័រ ស៊ីបផ្លាយ<br>Phnom Penh Labour Supply CO., LTD. | 2011 | ផ្ទះលេខ ១២- ផ្លូវលេខ ៤៤ MC សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ<br>No. 1-2, St. 44 MC, Sangkat Steung Meanchey, Khan Meanchey, Phnom Penh | 023 969 988/<br>012 995 666 |
| 30 | 035 | រ៉ាយស៍ ណែតជ្រល ឌីវេឡុបមិន<br>Rice Natural Deverlopment Plc. | 2011 | ផ្ទះលេខ ១០៧WA ផ្លូវទី៣ ភូមិទួលគោក សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ<br>No.107 WA, St. 3, Sangkat Toul Sangke, Khan Russey Keo, Phnom Penh | 099 929 288/<br>087 929 288/<br>071 7775859 |
| 31 | 036 | អេននី រីតា បេស មេនផៅវ័រ<br>Anny Rita Best Manpower CO., LTD. | 2012 | ផ្ទះលេខ ៣២៣៣- E ផ្លូវវែងស្រេង ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ<br>No. 32-33 E, St. Veng Sreng, Sangkat Chom Chao, Khan Posen Chey, Phnom Penh | 088 765 7777<br>086 7777 28<br>069 467 777 |
| 32 | 037 | សុខ ចំណូល<br>Sok Chamnol CO., LTD. | 2012 | អគារបុរីពិភពថ្មីឡាសែនសុខ លេខ០៥ ផ្លូវលេខ ០៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ<br>No. 5, St. 8, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh | 098 666 060/<br>097 259 6565<br>090 997 887 |
| 33 | 038 | ស៊ី.ជេ.ធី.ធី ត្រេឌីង<br>C.J.T.T Trading CO., LTD. | 2012 | ផ្ទះលេខ ២ ផ្លូវលេខ១០៧K ភូមិក្បាលដំរី សង្កាត់ កាកាប ខណ្ឌពោធិ៍សែនជ័យ<br>No. 2, St. 107K, Sangkat Kakab, Khan Posen Chey, Phnom Penh | 023 6504398/<br>069 633 604 |
| 34 | 039 | ប៊ី.អេស.អ.អូ បេស មេនផៅវ័រ<br>B.S.R.O Best Manpower CO., LTD. | 2012 | ផ្ទះលេខ ២៣៩ E0-E1 ផ្លូវលេខ០៥ ភូមិសំបួរ សង្កាត់ដង្កោ ខណ្ឌដង្កោ<br>No. 239 E0-E1, St. 05, Sangkat Doung Kor, Khan Doung Kor, Phnom Penh | 096 2947777/<br>097 8885581/<br>017 272 329 |
| 35 | 041 | ប៊ីក ប៊ី អ៊ីមិច គ្រុប<br>Big Bi Imex Group CO., LTD. | 2012 | ផ្ទះលេខ ១៦ ផ្លូវលេខ ៩ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ<br>No. 16, St. 09, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh | 015592225 /<br>097 3333 320 |
| 36 | 043 | កូបេ ហ្យូមេន សឺវីស(ខេមបូឌា)<br>Kobe Human Service (Cambodia) CO., LTD. | 2013 | ផ្ទះលេខ ២៦៥A ផ្លូវលេខ៦៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន<br>No.265 A, St. 63, Sangkat Tunle Basac, Khan Chamkamorn, Phnom Penh | 023 640 8666<br>017 644 246 |
| 37 | 044 | ដឹស៊ីប៊ត ខេមបូឌាន ឌីវេឡុបមេន ខនស្រ្តាក់សិន ខូអិលធីឌី<br>The Seaboard Cambodian Development Construction CO., LTD. | 2013 | ភូមិត្រពាំងទួល សង្កាត់កំបូល ខណ្ឌពោធិ៍សែនជ័យ<br>Tropeang Toul Village, Sangkat Kombol, Khan Posen Chey, Phnom Penh | 012 843 466 |

| | | | | | |
|---|---|---|---|---|---|
| 38 | 045 | **ស៊ី អេ ធី អឹម អេស៊ា មេនផៅវ័រ ខូអបពើរេសិន**<br>C A T M Asia Manpower Cooperation CO., LTD. | 2013 | ផ្ទះលេខ ៧២ ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ<br>No. 72, Tropeang Chhuk, Sangkat Tek Thla, Khan Sen Sok, Phnom Penh | 071 6978 987<br>061 699 999/<br>097 3369999 |
| 39 | 046 | **ឃី ឃី (ខេមបូឌា) ហ្យូមេនរីសស៍ ខូអិលធីឌី**<br>Kei Kei (Cambodia) Human Resource CO., LTD. | 2013 | ផ្ទះលេខ ២២២ ផ្លូវលេខ២០០៦ សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ<br>No. 222, St. 2006, Sangkat Kakab, Khan Posen Chey, Phnom Penh | 023 890 427/<br>023995074 /<br>012287655 |
| 40 | 047 | **វីន វីន មេនផៅវ័រ សឺវីស**<br>Win-Win Manpower Service CO., LTD. | 2014 | លេខ ២៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ<br>No. 23, Rusian Federation Blvd, Sangkat Tek Thla, Khan Sen Sok, Phnom Penh | 096 7070 674 |
| 41 | 051 | **អេលីត មេនផៅវ័រ អេជេនស៊ី**<br>ELITE MANPOWER AGENCY CO., LTD. | 2014 | ផ្ទះលេខ ៣២២ ប៉េ ផ្លូវលេខ ២៧១ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ<br>No. 322 P, St. 271, Sangkat Tek Thla, Khan Sen Sok, Phnom Penh | 088 990 0872<br>088 9900873/<br>017 693 777 |
| 42 | 053 | **ឌ្រីម មេនផៅវ័រ (ខេមបូឌា)**<br>Dream Manpower (Cambodia) CO., LTD. | 2014 | ផ្ទះលេខ៥ឌ ផ្លូវលេខ៣៧១ ភូមិត្រា សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ<br>No. 5D, St. 371, Sangkat Steung Meanchey, Khan Meanchey, Phnom Penh | 070 577 211 /<br>077 947 484/<br>086 797 993 |
| 43 | 056 | **សុខ លាភ មេត្រី**<br>Sok Leap Metrey CO., LTD. | 2015 | ផ្ទះលេខ ៤៧ D ផ្លូវលេខ ៣៦០ សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន<br>No. 47 D, St. 360, Sangkat Beung Kengkang I, Khan Chomkarmon, Phnom Penh | 015 301 111/<br>097 8077121 |
| 44 | 065 | **ណាត់ ថាកណាន មេនផៅវ័រ ឯក.**<br>NATH THAKNAN MANPOWER CO., LTD. | 2016 | ផ្ទះលេខ០៨ ផ្លូវលំ ភូមិពន្លា សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ<br>No. 8, St. Lum, Sangkat Prek Pra, Khan Chhbar Ampov, Phnom Penh | 097 336 9999<br>012 533 912 |
| 45 | 069 | **ខេម ហ្យូមេន ខេភីថល ឯក.**<br>CAM Human Capital CO., LTD. | 2016 | ផ្ទះលេខ ១១ ផ្លូវ ១៩២៨ ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ<br>No. 11, St. 1928, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh | 012 616 161 |
| 46 | 070 | **ហ្គ្រោវីង ផៅវ័រ**<br>Growing Power CO., LTD. | 2017 | អគារលេខ០២ ផ្លូវលេខ២៧៩ ភូមិ១៤ សង្កាត់បឹងកក់១ ខណ្ឌទួលគោក<br>Building No. 2, St. 279, Sangkat Beung Kok I, Khan Toul Kok, Phnom Penh | 023 882 276/<br>010 821 884/<br>010 609 539 |
| 47 | 071 | **ហ្វាស់អេប់ ឯ.ក (ខេមបូឌា)**<br>FASTUP(Cambodia) CO., LTD. | 2017 | អគារលេខ២៧K ផ្លូវបើកថ្មី ក្រុម១ ភូមិត្រា សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ<br>Building No. 27K, New Street, Sangkat Steung Meanchey, Khan Meanchey, Phnom Penh | 023 6304949/<br>089 450 656/<br>081 882 600 |
| 48 | 072 | **ភី.អឹម ប្រូហ្វេសិនណាល មេនផៅវ័រ ឯ.ក**<br>P.M. PROFESSIONAL MANPOWER CO., LTD. | 2017 | អគារលេខF១១ ផ្លូវឌូងងៀប៣ ភូមិទ្រុងមាន់ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខBuilding No. F11, St. Doung Ngeab, Sangkat Tek Thla, Khan Sen Sok, Phnom Penh | 096 2066828/<br>012 995 618/<br>097 699 8200 |
| 49 | 073 | **អរឌី មេនផៅវ័រ ឯក.**<br>RRD MANPOWER CO., LTD. | 2017 | ផ្ទះលេខ១៤E0 ផ្លូវ១៤ ភូមិទួលគោក សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ<br>Building 14 E0, St. 14, Sangkat Toul Sangke, Khan Russey Keo, Phnom Penh | 012 655 111 |
| 50 | 075 | **មាស សុវណ្ណ មាល្លិកេ មេនផៅវ័រ ឯ.ក**<br>MEAS SOVANN MEALEAKE MANPOWER CO., LTD. | 2017 | អគារលេខ៤៦៨ ផ្លូវលេខ១០១១ ភូមិភ្នំពេញថ្មី សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ<br>Building No. 468, St. 1011, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh | 092 231 111/<br>097 888 3888 |
| 51 | 076 | **យ៉ាគូស៊ីនកៃ (ខេមបូឌា)ឯ.ក**<br>YAKUSHIKAI (CAMBODIA) CO., LTD. | 2017 | អគារលេខ៤០ ផ្លូវ៣៦៣ សង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ<br>Building No. 40, St. 363, Sangkat Chbar Ampov, Khan Chhbar Ampov, Phnom Penh | 096 3676198/<br>089 885 001/<br>098 681 7989 |
| 52 | 077 | **ស៊ី.អិល. សឹបផ្លាយ(ខេមបូឌា)ឯ.ក**<br>C.L SUPPLY (CAMBODIA) CO., LTD. | 2017 | អគារលេខ C០១ ផ្លូវបេតុង ភូមិ[illegible] សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ<br>Building C01, St. Concrete, Sangkat Doung Kor, Khan Doung Kor, Phnom Penh | 023 648 023/<br>098 424 9999 |

| | | | | | |
|---|---|---|---|---|---|
| 53 | 078 | អេចអិន វើលដ៍ ខបភើរេសិន ឯក.<br>HN WORLD CORPORATION CO.,LTD. | 2017 | អគារលេខ ០៥ E0 E1 E2 ផ្លូវបេតុង ១០m សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ<br>Building No. 5 E0-E1-E2, St. Concrete, Sangkat Chom Chao, Khan Posen Chey, Phnom Penh | 010 571 117/<br>017571 117 |
| 54 | 081 | តាកាយ៉ាម៉ា លេប័រ សឹបផ្លាយ<br>TAKAYAMA LABOUR SUPPLY CO.,LTD. | 2017 | អគារលេខ១២១A ផ្លូវបេតុង ភូមិឫស្សី១ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ<br>Building No. 121 A, St. Concrete, Sangkat Steung Meanchey, Khan Meanchey, Phnom Penh | 088 7668888/<br>070 429 155/<br>097 5425140 |
| 55 | 082 | ហ្វាទីណា មេនផៅវ័រ ឯក.<br>FATINA MANPOWER CO.,LTD. | 2017 | អគារបុរីកពង្សីលេខ០១ ផ្លូវលេខ១០ ភូមិ៩១ សង្កាត់ច្រាំងចំរេះ ខណ្ឌឫស្សីកែវ<br>No. 01, St. 10, Sangkat Chrang Chom Res, Khan Russey Keo, Phnom Penh | 088 4217 287 |
| 56 | 083 | អេសភី អ៊ិនធើណេសិនណល មេនផៅវ័រ (ខេមបូឌា) ឯក<br>SP INTERNATIONAL MANPOWER (CAMBODIA) CO.,LTD | 2017 | អគារលេខ ៣២ ២០០៤អគើដ ផ្លូវបុរី ៣៤- សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ<br>Building No. 32-34, St. 2004, Sangkat Tek Thla, Khan Sen Sok, Phnom Penh | 077 769 976/<br>092788557/<br>016 583 828 |
| 57 | 084 | ប៊ី.អេហ្វ.ជី សឺវិស ឯ.ក<br>B.F.G SERVICE CO.,LTD | 2017 | អគារលេខ ៣C ផ្លូវលេខ៥១៤ ភូមិ១៣ សង្កាត់បឹងកក់១ ខណ្ឌទួលគោក<br>Building No. 3 C, St. 514, Sangkat Beung Kok I, Khan Toul Kok, Phnom Penh | 086 995 202/<br>097 8887543/<br>087 6667709 |
| 58 | 085 | អេកស្ពើត មេនផៅវ័រសឹបផ្លាយ ឯក.<br>EXPERT MANPOWER SUPPLY CO., LTD | 2017 | អគាគ្មានលេខ ផ្លូវលំ ភូមិប្រការ សង្កាត់ព្រៃសរ ខណ្ឌដង្កោ<br>St. Lum, Proka Village, Sangkat Prey Sor, Khan Daung Kor, Phnom Penh | 023 5217999/<br>010 227 597/<br>097 6707777 |
| 59 | 086 | ប៊ី.ភី មេនផៅវ័រ(ខេមបូឌា) ឯ.ក<br>B.P MANPOWER (CAMBODIA) CO.,LTD | 2017 | អគារលេខ៥២២C សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ<br>Building No. 522 C, Sangkat Russey Keo, Khan Russey Keo, Phnom Penh | 096 828 8888 |
| 60 | 087 | ហ្គ្រេន អ៊ីហ្គល (ខេមបូឌា) លេប័រ ឯ.ក<br>GRAND EAGLE (CAMBODIA) LABOR CO., LTD.. | 2017 | ផ្លូវដូងអៀប ភូមិត្រា សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ<br>St. Doung Ngeab, Sangkat Steung Meanchey, Khan Meanchey, Phnom Penh | 012 925 799 |
| 61 | 088 | 4 ថាយហ្គើរ លេប័រ សឹបផ្លាយ ឯ.ក<br>4 TIGERS LABOUR SUPPLY CO.,LTD | 2018 | អគារលេខ ៧៤ ផ្លូវលេខ១៥ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ<br>Building 74, St. 15, Sangkat Chom Chao, Khan Posen Chey, Phnom Penh | 017 900 400/<br>097 8888429 |
| 62 | 089 | មេត្រី អេចអ ឯក.<br>METREY HR CO.,LTD | 2018 | អគារលេខ៩០ ផ្លូវលេខ១៩ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ<br>Building 90, St. 19, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh | 085 888 535/<br>098 400 745/<br>017 743 954 |
| 63 | 090 | ជេ ខេប រីក្រូតម៉ិន ឯក.<br>J CAB RECRUITMENT CO., LTD | 2018 | អគារ៣៤ ផ្លូវលេខ៣៣៥ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក<br>Building 34, St. 335, Sangkat Beung Kok II, Khan Toul Kok, Phnom Penh | 096 9555 556<br>/092 913 133 |
| 64 | 091 | មហាចក្រ ឌីវើឡុបម៉ិន ឯក.<br>MAHACHAK DEVELOPMENT CO.,LTD | 2018 | អគារលេខ ៦៣១ ផ្លូវបេតុង ភូមិត្រពាំងល្វា សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ<br>Building 631, St. Concrete, Sangkat Kakab, Khan Posen Chey, Phnom Penh | 012 508 988/<br>010 508 988/<br>088 888 8456 |
| 65 | 092 | ៥៧ ហ្គោល មេនផៅវ័រ<br>57 Goal Manpower CO., LTD. | 2018 | ផ្ទះលេខ ១៧៤ ផ្លូវលេខ ២១ BTZ ភូមិសន្សំកុសល១ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ<br>No. 174, St. 21 BTZ, Sangkat Beung Tom Poun, Khan Meanchey, Phnom Penh | 081 6666 53 /<br>071 666 9596 |
| 66 | 095 | វី.អិល.អឹម.យូមេន រីសសស ឯ.ក<br>V.L.M HUMAN RESOUCES CO.,LTD. | 2018 | អគារលេខ C០១ ផ្លូវបេតុង ភូមិ[illegible] សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ<br>Building C01, St. Concrete, Sangkat Doung Kor, Khan Doung Kor, Phnom Penh | 08 8494 9999 |

| | | | | | |
|---|---|---|---|---|---|
| 67 | 096 | **អេមេនីធី យ៉យ ខ.ក (ខេមបូឌា)**<br>AMENITY JOY (CAMBODIA) CO.,LTD. | 2018 | អគារលេខ ៧៧E០ផ្លូវលំ ក្រុមទី១ ភូមិត្រពាំងឈូក សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ<br>Building 77E0 Tropeang Chhuk,Sangkat Obek korm, Khan Sen Sok Phnom Penh | 012 763 075 |

រាល់ទីភ្នាក់ងារជ្រើសរើសឯកជនទាំងឡាយណាដែលពុំមានឈ្មោះក្នុងបញ្ជីខាងលើនេះទេ គឺចាត់ទុកថាជាទីភ្នាក់ងារជ្រើសរើសឯកជនខុសច្បាប់ ដូច្នេះសូមសាធារណជនរាយការណ៍ជាបន្ទាន់ មកទូរស័ព្ទលេខ ០២៣ ៨៨០ ៤៧៤ និងទំនាក់ទំនងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទាំង២៥ រាជធានី-ខេត្ត នៅរៀងរាល់ម៉ោងធ្វើការ ឬពិនិត្យមើលបញ្ជីឈ្មោះក្រុមហ៊ុនដែលមាននៅក្នុងគេហទំព័ររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ www.mlvt.gov.kh ។

ដើម្បីជៀសវាងការផ្សព្វផ្សាយព័ត៌មានខុស ដែលអាចនាំឱ្យប្រជាពលរដ្ឋរងគ្រោះ ការផ្សព្វផ្សាយពាណិជ្ជកម្មពាក់ព័ន្ធនឹងការជ្រើសរើស ឬផ្តល់សេវាកម្មការងារឱ្យធ្វើដល់ពលករខ្មែរនៅតាមបណ្តាសារព័ត៌មានណាមួយ ជាពិសេសតាមបណ្តាស្ថានីយវិទ្យុត្រូវមានលិខិតអនុញ្ញាតចេញដោយអគ្គនាយកដ្ឋានការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជាមុន ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន អង្គភាពពាក់ព័ន្ធ បណ្តាសារព័ត៌មានទាំងអស់ជ្រាបជាព័ត៌មាន និងសហការអនុវត្ត ។

ថ្ងៃព្រហស្បតិ៍ ២រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៨

## ម្តាយសុំទោសកូនសំលាញ់...កូនៗស្រែកយំ ដង្ហោយហៅម៉ែ ម៉ែកុំទៅបានទេម៉ែ

https://www.khmernews.news/ By sitha back June 4, 2018

ភ្នំពេញ៖ ទិដ្ឋភាពគួរឲ្យអាសូរនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ខណៈកូនតូចអាយុប្រមាណ ២ខួបកន្លះបានស្រែកដង្ហោយហៅម្តាយឲ្យវិលត្រលប់ទាំងខ្លួននៅជីដូនពជាប់នឹងដៃ ម្តាយឮហើយចង់វិលវិញជួបកូនណាស់ប៉ុន្តែម្តាយត្រូវចេញទៅរកលុយមកផ្គត់ផ្គង់គ្រួសារក៏ដូចជាឲ្យកូនសួនពេលធំឡើងមានឱកាសរៀនសូត្របានជ្រៅជ្រះដូចគេ។ ដំណើរចេញទៅប្រទេសចិននោះ ត្រូវបានផេក «កំពូលអ្នកយកព័ត៌មាន» សរសេរថា «ព្រោះតែក្រពះ សុខចិត្តបែកពីក្រុមគ្រួសារ ទៅធ្វើជាពលការិនី ជាមេផ្ទះនៅហុងកុង ជាលើកដំបូង ខណៈដែលកូនតូចកំពុងឈរយំនៅខាងក្រោយ! ទឹកភ្នែកម៉ែស្រក់ខ្លោចចិត្តចំពោះទឹកភ្នែកកូនដង្ហោយហៅម៉ែៗ ម៉ែកុំទៅបានទេម៉ែ»។ ប្រភព៖ dara-news

## ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៨
## បើកវគ្គបណ្តុះបណ្តាលមន្រ្តីនគរបាលប៉ុស្តិ៍ស្តីពីបច្ចេកទេសសម្ភាសន៍និងការកំណត់អត្តសញ្ញាណជនរងគ្រោះ

http://cambodiapolice.com/ 9:36 am 5 មិថុនា 2018

បាត់ដំបង ៖ នៅថ្ងៃច័ន្ទ ០៦រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី០៤ ខែមិថុនា ឆ្នាំ ២០១៨ នៅសណ្ឋាគារ ប្រេស៊ីដង់ អង្គការបេសសកម្មយុត្តិធម៌អន្តរជាតិនិងអង្គការ ទស្សនៈពិភពលោកបានបើកវគ្គបណ្តុះបណ្តាលមន្រ្តីនគរបាលប៉ុស្តិ៍ ស្តីពីបច្ចេកទេសសម្ភាសន៍ និងការកំណត់អត្តសញ្ញាណ ជនរងគ្រោះដោយអំពើ

ជួញដូរមនុស្ស ក្រោមអធិបតីភាព ឯកឧត្តម ឧត្តមសេនីយ៍ឯក ឃឹម.សុវណ្ណារ៉ុត គ្រូនគរបាល ជាតិនៃបណ្ឌិត្យសភានគរបាលកម្ពុជា ដែលមានសិក្ខាកាម ចូលរួមចំនួន ៦៥នាក់ ស្រី ០៦នាក់ ៕

## បោកថាជាតម្រួត ឆក់លុយពលករខ្មែរ ១៤០០បាត ជិះគេចខ្លួនបាត់"

http://www.pheaktraprak.com June 4, 2018

នារីពលករិនីខ្មែរ០២នាក់ ធ្វើការស្នាក់នៅក្នុងខេត្តនុនថាក់បុរី ប្រទេសថៃ ត្រូវបានបុរសម្នាក់មិនស្គាល់អត្តសញ្ញាណជិះម៉ូតូពណ៌ខ្មៅ-ស មួយគ្រឿងមកឈប់ក្បែរដោយអះអាងថាខ្លួនជាតម្រួតថៃ ហើយសុំឆែកមើលប៉ាស្ប័រ និងការបូបលុយ រួចហូតយកលុយនារីទាំងពីនាក់ចំនួន១៤០០បាត ហើយជិះម៉ូតូគេចខ្លួនបាត់។ ករណីនេះបានកើតឡើងនៅថ្ងៃច័ន្ទទី០៤ ខែមិថុនា ឆ្នាំ២០១៨ ស្ថិតនៅក្នុងស្រុកបាងស៊ីមឿង ខេត្តនុនថាក់បុរី ក្រោយកើតហេតុបងប្រុសរបស់នារីរងគ្រោះទាំងពីនាក់បាននាំទៅដាក់ពាក្យបណ្ដឹងនៅស្ថានីតម្រួតបាងស៊ីមឿង ដើម្បីឲ្យតម្រួតស្វែងរកចាប់ខ្លួន ជនខិលខូចរូបនោះយកមកផ្ដន្ទាទោសតាមផ្លូវច្បាប់។ ប្រភពពី÷ខ្មាវឆនេ ០៤-០៦-២០១៨

## ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨

## រដ្ឋមន្ត្រីមហាផ្ទៃបញ្ជាឲ្យទប់ស្កាត់-បង្ក្រាបបទល្មើសឆ្លងដែន អំពើភេរវកម្ម ការជួញដូរដឹកអាវុធគ្រឿងផ្ទុះ

http://www.rasmeinews.com/ June 5, 2018, 9:22 PM

ដោយៈ មុនីរ័ត្ន/ភ្នំពេញៈសម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានណែនាំឲ្យកម្លាំងសមត្ថកិច្ចនៅតាមបណ្ដោយព្រំដែនបង្កើនវិធានការទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រប់ប្រភេទ ជាពិសេសបទល្មើសឆ្លងដែនដូចជា អំពើភេរវកម្ម ការជួញដូរដឹកអាវុធគ្រឿងផ្ទុះ ការចរាចរណ៍ជួញដូរគ្រឿងញៀនខុសច្បាប់ ការជួញដូរមនុស្ស ជួញដូរពលកម្ម ការដឹកជញ្ជូនអនុផលព្រៃឈើខុសច្បាប់...និងពង្រឹងត្រួតពិនិត្យច្រកចេញ-ចូល ឆ្លងកាត់ព្រំដែនឲ្យបានម៉ត់ចត់ និងលុបបំបាត់ច្រករបៀងព្រំដែនទាំងអស់។ នេះបើយោងតាមសេចក្ដីណែនាំស្ដីពីការពង្រឹងស្ថិរភាព សន្តិសុខ សណ្ដាប់ធ្នាប់តាមបណ្ដោយព្រំដែន ចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៨។

នៅក្នុងសេចក្ដីណែនាំសម្ដេចក្រឡាហោម ស ខេង បានបញ្ជាក់ថា មកទល់ពេលនេះ សភាពការណ៍សន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម នៃព្រះរាជាណាចក្រកម្ពុជា មានលក្ខណៈល្អប្រសើរ បង្កភាពអនុគ្រោះដល់ដំណើរការអភិវឌ្ឍន៍ជាតិលើគ្រប់វិស័យ។ សភាពការតាមតំបន់ព្រំដែនមានសភាពស្ងប់ស្ងាត់ប្រកបដោយសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍន៍។ ប៉ុន្តែសង្កេតឃើញថា នៅមានបាតុភាពកើតឡើងជារឿយៗ ពាក់ព័ន្ធនិងបទល្មើស និងការចេញ-ចូលឆ្លងកាត់ព្រំដែនខុសច្បាប់ដែលជាបច្ច័យអាក្រក់អាចបង្កឲ្យមានអសន្តិសុខតំបន់ព្រំដែន ប៉ះពាល់ដល់មិត្តភាព សហប្រតិបត្តិការជាមួយប្រទេសជិតខាង និងការអភិវឌ្ឍន៍សេដ្ឋកិច្ចនៃកម្ពុជា។ សម្ដេចក្រឡាហោមបានបន្តថា ក្នុងគោលបំណងពង្រឹងស្ថិរភាព សន្តិសុខ សណ្ដាប់ធ្នាប់ និងកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍន៍ តាមបណ្ដោយព្រំដែនរវាងកម្ពុជា និងប្រទេសជិតខាង ព្រមទាំងទប់ស្កាត់ប្រកបដោយប្រសិទ្ធភាពនូវផលប៉ះពាល់នានាជាអវិជ្ជមានក្រសួងមហាផ្ទៃ សូមធ្វើការណែនាំដល់អគ្គស្នងការនគរបាលជាតិអគ្គនាយកដ្ឋានអន្តោប្រវេសន៍គណៈបញ្ជាការឯកភាពរដ្ឋបាលខេត្តជាប់ព្រំដែន និងអាជ្ញាធរពាក់ព័ន្ធដូចខាងក្រោម៖

១.ត្រូវយកចិត្តទុកដាក់ពង្រឹងសភាពការណ៍នៅតាមតំបន់ព្រំដែន ឲ្យបន្តស្ថិតក្នុងស្ថានភាពល្អប្រសើរ ដោយរក្សាបាននូវសន្តិភាពស្ថិរភាពសន្តិសុខនិងសណ្ដាប់ធ្នាប់តាមរយៈបង្កើនវិធានការប្រមែប្រមូលព័ត៌មានជាប្រចាំ ដើម្បីមានវិធានការទាន់ពេលក្នុងការទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រប់ប្រភេទ ជាពិសេសបទល្មើសឆ្លងដែនដូចជាអំពើភេរវកម្ម,ការជួញដូរដឹកអាវុធគ្រឿងផ្ទុះការចរាចរជួញដូរគ្រឿងញៀនខុសច្បាប់ ការជួញដូរមនុស្ស ជួញដូរពលកម្ម ការដឹកជញ្ជូនអនុផលព្រៃឈើខុស ច្បាប់...។

២.ត្រូវពង្រឹងវិធានការត្រួតពិនិត្យការចេញ-ចូលឆ្លងកាត់ព្រំដែនឲ្យបានហ្មត់ចត់ប្រកបដោយ ស្មារតីទទួលខុសត្រូវខ្ពស់ក្នុងនោះត្រូវយកចិត្តទុកដាក់លើកកម្ពស់សមត្ថភាពការងារប្រចាំថ្ងៃរបស់មន្ត្រីចក្រទ្វារព្រំដែន។ ...ត្រូវចាត់វិធានការទប់ស្កាត់នូវការចេញ-ចូលមិនស្របច្បាប់ឲ្យមានប្រសិទ្ធភាព ជាពិសេសត្រូវលុបបំបាត់ច្រករបៀងព្រំដែនទាំងអស់នៅក្នុងភូមិសាស្ត្រទទួលខុសត្រូវរបស់ខ្លួន។

៣.ត្រូវបង្កើនកិច្ចសហប្រតិបត្តិការឲ្យបានកាន់តែជិតស្និទ្ធជាមួយសមភាគីនៃប្រទេសជាប់ព្រំដែន ដោយយកចិត្តទុកដាក់ជម្រុញយន្តការដែលបានចាត់ទាំងកន្លងមកឲ្យបំពេញភារកិច្ចបានសកម្មភ្លៀវក្លា ពង្រឹងរបបប្រជុំយន្តការព្រំដែនគ្រប់ថ្នាក់ដែលមានគោលការណ៍ឲ្យបានទៀងទាត់ដើម្បី ផ្លាស់ប្តូរសភាពការណ៍ និងរឹតចំណងមិត្តភាពសហប្រតិបត្តិកាតបាមស្មិតរមូតជាមួយគ្នាត្រូវរៀបចំ នូវប្រព័ន្ធទំនាក់ទំនងទាន់ហេតុការណ៍ ដើម្បីសហការដោះស្រាយលលិច្ចការបន្ទាន់។

៤.ត្រូវរៀបចំយន្តការដឹកនាំ ត្រួតពិនិត្យ និងរបៀបរបាយការណ៍ សំដៅធានាប្រសិទ្ធភាពរាល់វិធាន ការដែលបានដាក់ចេញដោយត្រូវចាត់ឲ្យមន្ត្រីទទួលបន្ទុកតាមដានកិច្ចការច្បាស់លាស់ មានកម្មវិធីចុះត្រួតពិនិត្យជាក់ស្តែង ដើម្បីក្រើនរម្លឹកកែលំអរឬលើកទឹកចិត្តដល់កងកម្លាំងមានសមត្ថកិច្ចតាមព្រំដែន និងក្តាប់បានអំពីស្ថានភាពប្រែប្រួលជាក់ស្តែងតាមបណ្តោយព្រំដែន៕មន

## អាជ្ញាធរថៃ បញ្ជូនពលករខ្មែរ៤នាក់ មកកម្ពុជាតាមច្រកទ្វារព្រំដែនអន្តរជាតិចាំយាម

https://www.facebook.com/ApsaraNewsNetwork/ ថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០១៨

ខេត្តកោះកុង៖ ពលករខ្មែរចំនួន៤នាក់ ដែលលួចឆ្លងដែនខុសច្បាប់ ទៅធ្វើការនៅប្រទេសថៃ នៅព្រឹកថ្ងៃទី ៦ ខែឧសភា ឆ្នាំ២០១៨ នេះ ត្រូវបានអាជ្ញាធរប្រទេសថៃ ចាប់បញ្ជូនមកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នៃខេត្តកោះកុង។ កម្លាំងសមត្ថកិច្ចជំនាញ បានឲ្យដឹងថា ពលករខ្មែរដែលឆ្លងដែនខុសច្បាប់ទាំងនោះ មានស្រុកកំណើតនៅខេត្តបាត់ដំបង ខេត្តពោធិសាត់ និងខេត្តកំពង់ចាម ដោយពួកគាត់រស់នៅ និងធ្វើការគ្មានច្បាប់ និងឯកសាគ្រប់គ្រាន់ ត្រូវអាជ្ញាធរថៃ ចាប់បញ្ជូនមកពីកោះឆាង ខេត្តត្រាត ប្រទេសថៃ មកកាន់តាមច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នៃខេត្តកោះកុង។ បច្ចុប្បន្នកម្លាំងប៉ុស្តិ៍ច្រកទ្វារ បានអប់រំណែនាំ និងបានរកមធ្យោបាយសម្រួលដល់ការធ្វើដំណើរ ដល់ពលករខាងលើ ត្រលប់ទៅស្រុកកំណើតវិញផងដែរ៕ ដោយ៖ ANN

## ពលករខ្មែរវាយគ្នានឹងដំបងឈើជ្រុងស្លាប់ម្នាក់នៅ ខេត្តឈុនបុរី

http://nokorwatnews.com/ ថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ២០១៨

ប៉ោយប៉ែត ៖ ជនរងគ្រោះម្នាក់ដែលជាកម្មករខ្មែរធ្វើការនៅក្នុងខេត្តឈុនបុរី ប្រទេសថៃ បានស្លាប់ភ្លាមៗក្រោយពីបានបញ្ជូនទៅកាន់មន្ទីរពេទ្យ ខណៈដែលជនរងគ្រោះរូបនេះកំពុងអង្គុយធ្វើការស្ងៀមៗ ស្រាប់តែមានជនជាតិខ្មែរដូចគ្នាបានលបវាយនឹងដំបងឈើជ្រុងចំក្បាលពីក្រោយ ព្រមទាំងបានវាយបន្ថែមទើបរត់គេចខ្លួន។

ហេតុការណ៍ដែលយើងទទួលបានពីសារព័ត៌មានថៃនេះ គឺបានកើតឡើងកាលពីថ្ងៃចន្ទ ៦រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក្តិ ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង ១២ ថ្ងៃត្រង់ នៅត្រង់ចំណុចទីតាំងកន្លែងបាញ់ថ្នាំរថយន្ត មួយកន្លែង លេខ ១៩/១ ស្ថិតក្នុងភូមិ១ ឃុំណងរី ស្រុកមឿង ខេត្តឈុនបុរី ប្រទេសថៃ ដោយជនរងគ្រោះមានឈ្មោះ វ៉ា គឹមសេង ភេទប្រុស អាយុ៣៧ឆ្នាំ ប៉ុន្តែគេមិនទាន់ដឹងថាជនរងគ្រោះរស់នៅក្នុងខេត្តណានៃប្រទេសកម្ពុជា នោះឡើយ ។

បើតាមការអះអាងពីសាក្សីឈ្មោះ ស៊ុំ សក្តិ ភេទប្រុស អាយុ៤៧ឆ្នាំ ជាជនជាតិថៃធ្វើការនៅកន្លែងជាមួយគ្នាបាននិយាយថា នៅមុនពេលកើតហេតុ គឺជនរងគ្រោះ កំពុងអង្គុយធ្វើការជាធម្មតា ឯខ្លួនក៏នៅធ្វើការមិនឆ្ងាយពីគ្នាប៉ុន្មានដែរ ។ ភ្លាមនោះក៏ស្រាប់តែឮដូចជាសម្លេងគេវ៉ៃមនុស្ស លុះពេលក្រលេកមើលទៅម្តងទៀត គឺឃើញ ជនរងគ្រោះដួលដេកទៅលើធរណី ពោរពេញដោយឈាមទៅហើយ ដោយនៅពីក្រោយខ្នង ឃើញឈ្មោះ ផេក លៀប

ភេទប្រុស អាយុ២៧ឆ្នាំ ត្រូវជាក្មួយ កំពុងឈរកាន់ដំបងឈើជ្រុងវាយបន្ថែមទៀត ទើបខ្លួនបានលោតទៅស្រែយាត់ ហើយជនសង្ស័យក៏បានរត់គេចខ្លួនបាត់តែម្តង ។

ដោយឡែកអ្នកស្រី ចុនឌី សកល អាយុ៣៧ឆ្នាំ ជាថៅកែនៅកន្លែងកើតហេតុនេះ បានលើកឡើង និងសរសើរថា ជនសង្ស័យខាងលើ គេគឺជាមនុស្សរាបសារណាស់ ដោយមិនដែលចេះកោងកាចដាក់អ្នកណាម្នាក់ឡើយ ដោយគ្រាន់តែកន្លងមក គេធ្លាប់មានរោគសសៃប្រសាទហើយសង្ស័យថា អាចខានលេបថ្នាំយូរពេកទើបរោគសញ្ញានេះរើឡើងវិញ ។ នៅក្នុងពេលនោះ ក្រុមតម្រួតបានបញ្ជូនជនរងគ្រោះទៅកាន់មន្ទីរពេទ្យខេត្តឈុនបុរី ព្រមទាំងបានជួយធ្វើចលនាបេះដូងផង ប៉ុន្តែជនរងគ្រោះបានស្លាប់ដោយមិនទាន់បានទៅដល់មន្ទីរពេទ្យផង ។ ឯជនសង្ស័យត្រូវបានសមត្ថកិច្ចថៃ តាមប្រមាញ់នឹងចាប់ខ្លួនបាននៅត្រង់ចំណុចឃុំបាងប្លាសយក្នុងស្រុកមឿង ដើម្បីយកមកផ្តន្ទាទោសតាមច្បាប់ ៕ វណ្ណា

## ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨

## បែកប្តីមួយយប់សោះ! មិនគួរណាប្រុសថ្លៃទៅជាយ៉ាងនេះ!

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៨ ម៉ោង ១២:៤៨ ម៉ុត សារុន

ខេត្តបន្ទាយមានជ័យ ៖ ស្ត្រីវ័យក្មេងស្រស់សោភាម្នាក់យំរៀបរាប់ទាំងទឹកភ្នែកថា មិនគួរសោះបែកប្តីមួយយប់ បែជាទទួលព័ត៌មានថា ប្តីបានដេកស្លាប់ សង្ស័យខ្យល់គរ ហើយត្រូវបានភាគីថៃបញ្ជូនឲ្យសាច់ញាតិតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតនៅម៉ោងជិត១២ព្រឹកថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ នេះ ។

ស្ត្រីដែលយំខាងលើឈ្មោះ សិ អួន អាយុ២៤ឆ្នាំ មានទីលំនៅភូមិឃុំតាបែន ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ។ នាងប្រាប់ថា ជនរងគ្រោះជាប្តីឈ្មោះ ស៊ិន សោម អាយុ២៧ឆ្នាំ ជាកម្មករសំណង់ និងមានទីលំនៅភូមិតានី ឃុំរពាងគោ ស្រុកក្រឡាញ់ ខេត្តសៀមរាប ។ នាងជាប្រពន្ធប្រាប់ថា បើនៅជុំគ្នាប្តីនាងប្រហែលជាមិនស្លាប់ទេ ព្រោះនាងអាចកោសជប់ឲ្យប្តី ។ នាងថា មុនស្លាប់មួយថ្ងៃបុរសជាប្តីជូននាងឡើងជិះរថយន្តពីខេត្តឈុនបុរីមកកម្ពុជាវិញ ដើម្បីធ្វើលិខិតឆ្លងដែនដឹងអីបែកគ្នាតែ១ថ្ងៃ ព្រឹកឡើងទទួលព័ត៌មានថា ប្តីស្លាប់ទៅវិញ ។

ជនរងគ្រោះដេកស្លាប់នៅខេត្តឈុនបុរីប្រទេសថៃ ខណៈទៅធ្វើការជាកម្មករសំណង់នៅទីនោះត្រូវកម្មកររួមអាជីពប្រទះឃើញដេកស្លាប់ នៅព្រឹកថ្ងៃទី០៦មិថុនា ម្សិលមិញ ។ សាច់ញាតិសពប្រាប់ថា ជនរងគ្រោះមុនស្លាប់នៅរសៀលថ្ងៃទី២៥ ខណៈកំពុងធ្វើការប្រាប់គេឯងថា ខ្លួនចុកពោះ ប៉ុន្តែមិនព្រមសម្រាកពីការងារទេ បើទោះជាកម្មកររួមអាជីពគ្រប់គ្នាប្រាប់ឲ្យឈប់សម្រាក ។ សពរងគ្រោះក្រោយបញ្ជូនដល់កម្ពុជាត្រូវបានសាច់ញាតិជួលរថយន្តម៉ាកស៊ីណាដឹកទៅស្រុកក្រឡាញ់ ដើម្បីធ្វើបុណ្យតាមប្រពៃណី ៕

## មូលនិធិ LPN ប្រទេសថៃ ជួយបណ្តុះបណ្តាលកូនពលករខ្មែរនិងភូមាឲ្យបានរៀនសូត្រ

http://www.pheaktraprak.com June 7, 2018

កូនចៅរបស់ពលករខ្មែរនិងពលករភូមា ត្រូវបណ្តុះបណ្តាលឲ្យបានចូលរៀនសូត្រ នៅក្នុងកន្លែងស្នាក់នៅក្នុងការដ្ឋានសំណង់ ប្រកបដោយសុវត្ថិភាព ដោយបានការជំរុញជ្រែងពីលោក Sompong Srakaew ប្រធានមូលនិធិ LPN ប្រទេសថៃ ។ នេះគឺជាកូនរបស់ពលករខ្មែរនិងភូមា ដែលបានចូលរៀនសូត្រ នៅនិងកន្លែងស្នាក់នៅក្នុងការដ្ឋានសំណង់ដែលមានសុវត្ថិភាព ក្នុងសាលារដ្ឋប្រទេសថៃ ធ្វើឲ្យឪពុកម្តាយកុមារទាំងអស់នោះមានក្តីសុខនៅពេលកូនបានរៀនសូត្រ នៅពេលកុមារទាំងអស់នោះធំពេញវ័យពួកគេនឹងក្លាយជាបុគ្គលចេះដឹងមានគុណភាពឆ្ពោះទៅរកការអភិវឌ្ឍនៅក្នុងសង្គមថៃ និងអាស៊ានទាំងមូល។ ប្រភពពី÷https://goo.gl/R5XGpP

## តើជនជាតិណាខ្លះដែលច្បាប់ប្រទេសថៃមិនបញ្ជូនខ្លួនទៅ.!

http://www.pheaktraprak.com June 6, 2018

យោងតាមមាត្រាលេខ (៦៣/១) នៃ ព្រះរាជាណាចក្រថៃឡង់ បានកំណត់ថា បុគ្គលដែលគ្មានសញ្ជាតិត្រឹមត្រូវ ៣ ប្រភេទ ដែលច្បាប់ ប្រទេសថៃលើកលែងនិងអោយរស់នៅធ្វើការបន្តនៅក្នុងប្រទេសថៃបាន។ មានដូចខាងក្រោមនេះ÷

១-បគ្គលដែលធ្លាប់ទទួលបានសញ្ជាតិថៃ តែត្រូវដកហូតសញ្ជាតិវិញ តាមជំពូក(១)

២-បុគ្គលដែលកើតនៅលើដីប្រទេសថៃ តែមិនបានទទួលសញ្ជាតិថៃ តាមជំពូក(២)

៣- ជនភៀសខ្លួនមករស់នៅប្រទេសថៃឬ(ជនជាតិភាគតិច)និង ជាតិសាសន៍ដទៃទៀតដែលចូលមករស់នៅអស់រយៈកាលជាយូរលង់មកហើយ តាមជំពូក(៣)។

ដូច្នេះបុគ្គលដែលដូចការរៀបរាប់ខាងលើត្រូវបានច្បាប់ប្រទេសថៃអនុញ្ញាតឲ្យរស់នៅក្នុងប្រទេសថៃបាន តែត្រូវសុំច្បាប់អនុញ្ញាតធ្វើការដូចជាពលករបរទេសដែរប៉ុន្តែមានលក្ខណៈខុសគ្នាត្រង់រឿងប័ណ្ណ សម្គាល់ខ្លួននិងសពុលភាពច្បាប់អនុញ្ញាតធ្វើការ ។

## ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៨

## ឱកាសចុងក្រោយហើយ,ចំពោះពលករខ្មែរ,ឡាវ,ភូមាដែលកំពុងធ្វើការនៅក្នុងប្រទេសថៃ

http://www.pheaktraprak.com June 7, 2018

រដ្ឋមន្ត្រីក្រសួងការងារថៃប្រកាសឱ្យនិយោជិកថៃ ប្រញាប់នាំពលករបរទេសទៅបញ្ជាក់អត្តសញ្ញាណអោយរួចរាល់មុនថ្ងៃទី៣០ ខែមិថុនា មិនដូច្នោះទេនឹងត្រូវមានទោសទាំងថៅកែទាំងពលករ។ នៅថ្ងៃព្រហស្បតិ៍ ទី០៧ ខែមិថុនា ឆ្នាំ២០១៨នេះ លោក Thawarat Thaerat អគ្គនាយកនៃអគ្គនាយកដ្ឋានការងារថៃបានមានប្រសាសន៍ថាលោកឧត្តមសេនីយ៍ឯក Adul Sangsaengkaew រដ្ឋមន្ត្រីក្រសួងការងារថៃ បានប្រកាសតឿនដល់និយោជិកថៃដែលកំពុងគ្រប់គ្រងពលករខ្មែរ,ឡាវ,ភូមា សូមអោយប្រញាប់នាំពលករទាំងអស់នោះទៅបញ្ជាក់អត្តសញ្ញាណនៅមជ្ឈមណ្ឌលផ្តល់សេវាកម្ម,OSS One Stop Service អោយរួចរាល់ ។ បច្ចុប្បន្ននេះរយៈពេលធ្វើតៀនប្រវត្តិជូនពលករបរទេសនៅដល់រយៈពេលត្រឹមតែ២៣ថ្ងៃប៉ុណ្ណោះ មជ្ឈមណ្ឌលផ្តល់សេវាកម្ម, OSS នឹងបិតដំណើរការហើយ ដូច្នេះហើយសូមនិយោជិតថៃទាំងអស់ប្រញាប់ប្រញាល់នាំពលករដែលមិនទាន់បានធ្វើទៅទំនាក់ទំនងមជ្ឈមណ្ឌលផ្តល់សេវាកម្ម,OSS អោយបានមុនថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨នេះ។ បើសិននិយោជិតជួលពលករអោយធ្វើការខុសពីលក្ខខណ្ឌច្បាប់អនុញ្ញាតធ្វើការ ត្រូវមានទោសផាកពិន័យជាប្រាក់ចាប់ពី១.០០០បាតដល់១០០,០០០បាតក្នុងពលករម្នាក់។

ក្នុងករណីជួលពលករដោយគ្មានច្បាប់អនុញ្ញាតអោយធ្វើការត្រូវមានទោសតាមច្បាប់អន្តោប្រវេសន៍ ដោយត្រូវផាកពិន័យជាប្រាក់ចាប់តាំងពី៥.០០០បាត ដល់ ២០០.០០០០បាតក្នុងពលករម្នាក់ និងជាប់ពន្ធនាគាររយៈពេល០១ឆ្នាំ ឬទាំងពីរយ៉ាង និងហាមជួលពលករបរទេសរយៈ០៣ឆ្នាំ។ ចំពោះពលករដែលធ្វើការដោយគ្មានច្បាប់អនុញ្ញាតវិញនឹងត្រូវមានទោសពិន័យជាប្រាក់ពី៥.០០០បាត ដល់ ៥០.០០០បាត ក្រោយពេលបង់ថ្លៃផាកពិន័យហើយ ពលករខុសច្បាប់រូបនោះត្រូវបញ្ជូនអោយទៅមាតុភូមិរបស់ខ្លួនវិញ និងហាមចូលធ្វើការនៅក្នុងប្រទេសថៃរយៈពេល០២ឆ្នាំ ចាប់តាំងពីថ្ងៃត្រូវទទួលទោស។

## មូលនិធិ LPN ប្រទេសថៃ ចុះធ្វើការអប់រំពលករខ្មែរចំនួន ៤៥នាក់ ដែលកំពុងធ្វើនៅក្នុងរោងចក្រ CPF

http://www.pheaktraprak.com June 7, 2018

នៅថ្ងៃព្រហស្បតិ៍ ទី០៧ ខែមិថុនា ឆ្នាំ២០១៨ តំណាងមូលនិធិ LPN ប្រទេសថៃ ដឹកនាំដោយលោក Samak Tubtanee បានចុះធ្វើការអប់រំបងប្អូនពលករខ្មែរចំនួន៤៥នាក់ ដែលកំពុងធ្វើការរោងចក្រផលិតគ្រឿងឧភោគ បរិភោគ CPF ស្ថិតនៅក្នុងស្រុកឆោកឆៃ ខេត្តណាខនរាជស៊ីម៉ា អោយបានយល់ដឹងអំពីច្បាប់និងបញ្ហាការជួញដូរមនុស្សនៅក្នុងប្រទេសថៃ។ ការចុះអប់រំនិងផ្សព្វផ្សាយស្តីពីច្បាប់ការងារនិងបញ្ហាការជួញដូរមនុស្សដល់ពលករខ្មែរទាំងអស់នេះ ដោយមានការសហការពីក្រុមហ៊ុន CPF និងមូលនិធិ LPN ប្រទេសថៃ ដើម្បីអោយពលករខ្មែរដែល កំពុងបំពេញការងារនៅក្នុងប្រទេសថៃទាំងអស់បានយល់ដឹងពីច្បាប់ការងារប្រទេសថៃកាន់ច្បាស់លាស់។

## មូលនិធិ LPN ប្រទេសថៃដឹកនាំដោយលោក Samak Tubtanee បានចុះធ្វើការបណ្តុះបណ្តាលអប់រំអ្នកគ្រប់គ្រងនៅក្នុងរោងចក្រ CPF ស្ថិតនៅក្នុងខេត្តសារ៉ាក់បុរីចំនួន៥០នាក់

https://www.facebook.com/khmerlabour/ ពលករខ្មែរ-KhmerLabour ០៨-០៦-២០១៨

នៅថ្ងៃសុក្រ ទី០៨ ខែមិថុនា ឆ្នាំ២០១៨ តំណាងមូលនិធិ LPN ប្រទេសថៃដឹកនាំដោយលោក Samak Tubtanee បានចុះធ្វើការបណ្តុះបណ្តាលអប់រំអ្នកគ្រប់គ្រងនៅក្នុងរោងចក្រ CPF ស្ថិតនៅក្នុងខេត្តសារ៉ាក់បុរីចំនួន ៥០នាក់ (វគ្គព្រឹក) និងវគ្គរសៀលមានការអប់រំដល់ពលករខ្មែរចំនួន៥០នាក់បន្ថែមទៀត។ ក្នុងវគ្គចុះអប់រំបណ្តុះបណ្តាលដល់ពលករខ្មែរដែលកំពុងធ្វើការនៅក្នុងរោងចក្រ CPF ក្នុងខេត្តសារ៉ាក់បុរី លើកនេះ គឺដើម្បី ផ្តល់ចំណេះដឹងស្តីពីច្បាប់ការងារនិងការប្រឆាំងអំពើជួញដូរមនុស្សនៅក្នុងប្រទេសថៃ ដើម្បីឲ្យពលករខ្មែរទាំងអស់ បានយល់ដឹងអំពីច្បាប់របស់ប្រទេសថៃ ។

## ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨
## អគ្គនាយកដ្ឋានក្រសួងគាំពារសិទ្ធពលករប្រទេសថៃ,ហាមនិយោជិតបង្ខំអោយពលករធ្វើការលើសម៉ោង

http://www.pheaktraprak.com June 9, 2018

នៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៨ លោក អាណានថៃ អ៊ូថៃផាត់ណាជីព អគ្គនាយកកដ្ឋាននៃក្រសួងគាំពារសិទ្ធិពលករនៃក្រសួងការងារថៃ។ បានមានប្រសាសន៍ថា ច្បាប់គាំពារសិទ្ធិពលករបានកំណត់ហាមមិនឲ្យបង្ខំឲ្យពលករធ្វើការហួសម៉ោងលើកលែងតែមានការស្ម័គ្រចិត្តពីពលករជាមុនសិនទើបអាចធ្វើបាន។ តែក្នុងករណីនិយោជិតមានការចំបាច់ត្រូវអោយពលករធ្វើការបន្ថែមម៉ោងត្រូវមានការយល់ព្រមពីពលករជាមុនសិនទើបអាចអោយពលករធ្វើការបាន។ បើសិនជាស្ថានភាពការងារនោះតំរូវអោយពលករធ្វើការអោយរួចរាល់ឬមិនដូច្នោះទេត្រូវវងការខូចខាតដល់ការងារនោះ និយោជិតអាចអោយពលករធ្វើការបន្ថែមម៉ោងបានតាមការចាំបាច់ប៉ុណ្ណោះ ប៉ុន្តែត្រូវសួរការយល់ព្រមពីពលករជាមុនសិនរាល់លើក។ ក្នុងករណីពលករធ្វើការលើសម៉ោង និយោជិតត្រូវបន្ថែមប្រាក់ឈ្នួល បន្ថែមម៉ោងជូនដល់ពលករមិនតិចជាង១.៥ ភាគរយនៃប្រាក់ឈ្នួលធ្វើការពេញម៉ោង ក្នុងថ្ងៃធ្វើការនោះផងដែរ។ ធ្វើការលើសម៉ោងនៅក្នុងថ្ងៃឈប់សម្រាក ត្រូវផ្តល់ប្រាក់បន្ថែមម៉ោងមិនតិចជាង៣ភាគរយនៃអាត្រាប្រាក់ជួលក្នុងមួយម៉ោងនៃមួយថ្ងៃ។ ដូច្នេះនិយោជិតអនុវត្តអោយត្រឹមត្រូវតាមច្បាប់ការងារ ក្នុងករណីបំពានច្បាប់ត្រូវមានទោសជាប់ឃុំមិនលើសពី៦ខែ ពិន័យជាប្រាក់មិនលើស១០០០០០បាត (១សែនបាត)ឬទាំងជាប់ឃុំទាំងពិន័យ។

### "បញ្ជូនពលករខ្មែរមួយគ្រួសារទៅមន្ទីរពេទ្យដោយសារពុលសំម្លរផ្សិត"

https://www.facebook.com/khmerlabour/ ពលករខ្មែរ-KhmerLabour ១០-០៦-២០១៨

កាលពីវេលាម៉ោង១០:០០ព្រឹក ថ្ងៃអាទិត្យទី១០ខែមិថុនា ឆ្នាំ២០១៨ មានករណីពលករខ្មែរមួយគ្រួសារ ទី១មានឈ្មោះ ភ័ក្រ្ត ភេទប្រុស អាយុ ៣៦ឆ្នាំ (ឪពុក) ទី២ឈ្មោះ ចាន់កែវ ភេទស្រី អាយុ ៣៦ឆ្នាំ(ម្តាយ) ទី៣ឈ្មោះ ដា នាង ភេទប្រុស អាយុ ១៤ឆ្នាំ (កូន) ទី៤ ឈ្មោះ នាង ណេក ភេទស្រី អាយុ ១០ឆ្នាំ (កូន) ជាពលករធ្វើនៅក្នុងចំកៅស៊ូមួយកន្លែងស្ថិតនៅឃុំក្រែងស្រុកក្រែងខេត្តាក់យ៉ង ប្រទេសថៃ បានបរិភោគសំម្លរផ្សិតម្យ៉ាងបណ្តាលឲ្យ(ពុល)មានអាការៈក្អួតចង្អោរវិលមុខ ត្រូវបានប្រជាពលរដ្ឋថៃ ទំនាក់ទំនងហៅរថយន្តសង្គ្រោះដឹកយកទៅព្យាបាលនៅមន្ទីរពេទ្យស្រុកក្រែង ខេត្តាក់យ៉ងនៅវេលាបន្តបន្ទាប់។ ពលករខ្មែរ-KhmerLabour

### ទីប្រឹក្សាទទួលបន្ទុកពលករប្រចាំប្រទេសថៃ បានចូលរួមប្រជុំពិភាក្សាជម្រុញការបញ្ជាក់អត្តសញ្ញាណជូនដល់ពលករ និងការគ្រប់គ្រងការិយាល័យចេញចូលតែមួយរបស់ប្រទេសថៃ

https://www.facebook.com/ ទីប្រឹក្សាទទួលបន្ទុកពលករប្រចាំប្រទេសថៃ June 8 at 3:27pm ·

នៅថ្ងៃសុក្រ ១០រោច ខែជេស្ឋ ឆ្នាំច សំរិទ្ធស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៨ ក្រុមការងារទីប្រឹក្សាទទួលបន្ទុកពលករ បានចូលរួមប្រជុំពិភាក្សាអំពីការជម្រុញការបញ្ជាក់អត្តសញ្ញាណជូនដល់ពលករ និងការគ្រប់គ្រងការិយាល័យចេញចូលតែមួយរបស់ប្រទេសថៃ(OSS) ដោយភាគីថៃបានបញ្ជាក់ជូនថា ពុំមានការបន្តសុពលភាពប័ណ្ណមិនមែនសញ្ជាតិថៃ(ប័ណ្ណស៊ីជំពូ)បន្តទៀតទេ ដូច្នេះពលករទាំងអស់ត្រូវមកធ្វើការបញ្ជាក់អត្តសញ្ញាណ និងស្នើសុំទិដ្ឋាការ និងប័ណ្ណអនុញ្ញាតការងារអោយបានរួចរាល់ត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨។ ចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៨ តទៅភាគីថៃនឹងចាប់ផ្តើមអនុវត្តច្បាប់ តាមព្រះរាជក្រឹត្យស្តីពីការគ្រប់គ្រងការធ្វើការរបស់ពលករបរទេស ដែលមានការផាកពិន័យ និងដាក់ទោស ទាំងពលករដែលធ្វើការដោយពុំមានឯកសារគ្រប់គ្រាន់ ទាំងនិយោជកដែលប្រើប្រាស់ពលករដែលពុំមានឯកសារ។ ដូច្នេះសូមបងប្អូនពលករទាំងអស់ដែលមិនទាន់បានដំណើរការឯកសារស្របច្បាប់ ប្រញាប់ប្រញាល់ទៅដំណើរការឯកសារទាំងនោះ អោយបានទាន់ពេលកំណត់ ទើបអាចស្នាក់នៅ និងធ្វើការនៅក្នុងប្រទេសថៃបានដោយស្របច្បាប់។

### ថៃអំពាវនាវឲ្យ ពលករបរទេសរួមទាំងកម្ពុជាផង ទៅបញ្ជាក់អត្តសញ្ញាណ

http://km.rfi.fr/cambodia/labour-minister ដោយ សឿង ភារៈ 11/06/2018

រដ្ឋមន្ត្រីក្រសួងការងារ បានអំពាវនាវឲ្យពលករបរទេសកំពុងធ្វើការក្នុងប្រទេសថៃ ដែលក្នុងនោះមានពលករកម្ពុជាផង ទៅចុះឈ្មោះបញ្ជាក់អត្តសញ្ញាណ ដើម្បីទទួលបានភាពស្របច្បាប់ធ្វើការក្នុងប្រទេសថៃ មុនពេលការអនុវត្តច្បាប់ត្រូវធ្វើនាដំណាច់ខែមិថុនាខាងមុខនេះ។ ចំណែកកម្ពុជាធ្លាប់បានអះអាងថា ពលករដែលធ្វើការខុសច្បាប់ក្នុងប្រទេសថៃ បានទទួលភាពស្របច្បាប់ជិតអស់ហើយ។ រដ្ឋមន្ត្រីក្រសួងការងារថៃ លោក Pol Gen. Adul sangsingkeo បានអំពាវនាវឲ្យពលករខ្មែរ ភូមា និងឡាវ មកបញ្ជាក់អត្តសញ្ញាណ និងចុះឈ្មោះ ដើម្បីធ្វើការងារស្របច្បាប់ក្នុងប្រទេស មុនពេលយុទ្ធនាការចុះឈ្មោះនេះត្រូវបញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា។ នេះបើតាមការចុះផ្សាយរបស់គេហទំព័រThe Nation របស់ប្រទេសថៃកាលពីថ្ងៃទី៨ ខែមិថុនា។

នាយកដ្ឋានផ្នែកការងាររបស់ថៃ លោក Anurak Thossarat បានបញ្ជាក់កាលពីថ្ងៃសុក្រប្រាប់សារព័ត៌មាន The Nation ថា ការចុះឈ្មោះពលករបរទេសក្នុងប្រទេសថៃ នឹងមិនមានការពន្យារពេលតទៅទៀតទេ។ នាយកដ្ឋានផ្នែកការងាររបស់ថៃបញ្ជាក់ថា នៅក្រោយថ្ងៃទី៣០ ខែមិថុនា ពលករដែលធ្វើការខុសច្បាប់ ថៅកែរបស់ពួកគេនឹងប្រឈមនឹងការផាកពិន័យពីអាជ្ញាធរថៃក្រោមច្បាប់គ្រប់គ្រងពលករបរទេស ដែលបានវិសោធនកម្មកាលពីឆ្នាំ២០១៧កន្លងទៅ។

អ្នកនាំពាក្យក្រសួងការងារកម្ពុជាមិនមានអត្ថាធិប្បាយអ្វី ឆ្លើយតបទៅនឹងការអំពាវនាវរបស់ប្រទេសថៃនាពេលនេះទេ។ ប៉ុន្តែបើតាមលោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ កាលពីថ្ងៃទី២២ ឧសភា កម្ពុជា និងថៃបាន

សហការរួមគ្នាផ្តល់ភាពស្រុបច្បាប់ជូនពលករកម្ពុជាបានជាង៣០ម៉ឺននាក់រួចហើយ ក្នុងចំណោមពលករជាង៤០ម៉ឺននាក់ ដែលកំពុងបំរើការងារ ដោយខុសច្បាប់នៅក្នុងប្រទេសថៃ។

លោក អ៊ិត សំហេង ថាពលករកម្ពុជា ដែលបំរើការងារ ដោយគ្មានឯកសារស្របច្បាប់ នៅក្នុងប្រទេសថៃ ពីមុនមកនោះ ឥឡូវនេះបានទទួលភាពស្របច្បាប់ជិតអស់ហើយ និងកំពុងបន្តធ្វើកិច្ចការនេះឱ្យបានរួចរាល់ នៅមុនដំណាច់ ខែ មិថុនា ឆ្នាំ២០១៨ខាងមុខនេះ។ លោកបញ្ជាក់ថានៅពាក់កណ្តាលខែមិថុនានេះ លោកនឹងទៅបំពេញទស្សនកិច្ចផ្លូវការនៅប្រទេសថៃ ដើម្បីពិនិត្យចុងក្រោយ និងដោះស្រាយបញ្ហាដែលនៅសេសសល់។

កាលពីថ្ងៃទី១៨ ខែឧសភា គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលរដ្ឋកម្ពុជា បានអំពាវនាវឲ្យពលករខ្មែរដែលពុំទាន់បានមកបញ្ជាក់អត្តសញ្ញាណ ត្រូវប្រញាប់រួសរាន់មកធ្វើការបញ្ជាក់អត្តសញ្ញាណជាមួយក្រុមការងារដែលមានទីតាំងនៅទីក្រុងបាងកក ខេត្តផាធុមថានី ខេត្តរ៉ាក់យ៉ង និងក្រុមការងារចល័តដែលចុះទៅតាមខេត្តពលករស្នាក់នោះឲ្យបានត្រឹមថ្ងៃទី៣០ ខែមិថុនា។

សូមជម្រាបជូនថា ពលករបរទេស ដែលធ្វើការនៅក្នុងប្រទេសថៃ ដោយគ្មានការអនុញ្ញាតនឹងត្រូវផាកពិន័យពី១៥៥ដុល្លារ ដល់១,៥៦០ដុល្លារ ហើយនឹងមិនអនុញ្ញាតឲ្យដាក់ពាក្យសុំធ្វើការរយៈពេល២ឆ្នាំ។ ចំណែកឯនិយោជករូបណា ដែលទទួលយកពលករបរទេសមកធ្វើការខុសច្បាប់នឹងត្រូវផាកពិន័យពី៣១២ដុល្លារ ដល់៣,១២០ដុល្លារ ក្នុងពលករម្នាក់៕

## ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៨

## លោកស្រី ម៉ែន សំអនៈ ពលករខ្មែរធ្វើការនៅប្រទេសថៃ ត្រូវបានការយក ចិត្តទុកដាក់ពីអាជ្ញាធរ ថៃ ពួកគាត់មានប្រាក់ ចំណូលសមរម្យសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច គ្រួសារ

http://nokorwatnews.com/ ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០១៨

ភ្នំពេញ៖ លោកស្រីកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច បានជួបពិភាក្សាការងារជាមួយ លោក ផានយ៉ារ៉ាក់ ភលធុប( Panyarak Poolthup ) ឯកអគ្រាជទូតថៃប្រចាំនៅកម្ពុជា ក្នុងគោលបំណងបន្តកិច្ចសហប្រតិបត្តិការជាមួយគ្នាឲ្យបានល្អ រវាងពលករខ្មែរធ្វើការនៅប្រទេសថៃ ត្រូវបានការយកចិត្តទុកដាក់ពីអាជ្ញាធរថៃ ពួកគាត់មានប្រាក់ចំណូលសមរម្យសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចគ្រួសារ ។ ជំនួបពិភាក្សានេះ បានប្រព្រឹត្តទៅ កាលពីរសៀលថ្ងៃចន្ទ ១២រោច ខែជេស្ឋ ឆ្នាំចសំរឹទ្ធិស័កព.ស២៥៦២ ត្រូវនិងថ្ងៃទី១១ មិថុនា ឆ្នាំ ២០១៨ នៅទីស្តីការកេនរស្នង ។

លោក ផានយ៉ារ៉ាក់ ភលធុប( Panyarak Poolthup ) ឯកអគ្គរាជទូតថៃ ប្រចាំនៅកម្ពុជា បានបញ្ជាក់ថា៖ ក្រសួងការងារថៃបានទទួលចុះបញ្ជីពលករខ្មែរឲ្យធ្វើការនៅប្រទេសថៃ ដើម្បីទទួលបានផលប្រយោជន៏ដូចពលរដ្ឋប្រទេសថៃនោះផងដែរ ។ ការចុះបញ្ជីពលករបរទេសធ្វើការនៅថៃ និងបញ្ចប់នៅខែមិថុនាឆ្នាំ២០១៨ នេះ។

នាឱកាសនោះដែរ លោកស្រីកិត្តិសង្គហបណ្ឌិត ម៉ែន សំអន បានបញ្ជាក់ថា៖ ប្រទេសទាំងពីរមានទំនាក់ទំនងមិត្តភាព ជាប្រពៃណីល្អជាមួយគ្នាក្នុងការផ្លាស់ប្តូរទំហំពាណិជ្ជកម្ម បានបង្កើនបន្ថែមទៀតរវាងប្រទេសទាំងពីរ និងទេសចរណ៏ថៃមានចំនួនច្រើនមកកម្ពុជា ។ លោកជំទាវកិត្តិសង្គហបណ្ឌិត បានថ្លែង អំណរគុណដល់អាជ្ញាធរថៃផងដែរដែលបានជួយសំរួលការងារដល់ពលខ្មែរស្នាក់នៅនិងធ្វើការនៅប្រទេសថៃ។ សម្តេចតេជោនាយករដ្ឋមន្ត្រីបានចាត់ឲ្យលោកជំទាវកិត្តិសង្គហបណ្ឌិតធ្វើជាតំណាងចុះទៅសួរសុខទុក្ខពលករខ្មែរធ្វើការនៅប្រទេសថៃ និងអរគុណដល់ក្រសួងការងារថៃ ដែលបានជួយសម្រួលឯកសារដល់ពលករខ្មែរធ្វើការនៅប្រទេសថៃ ។ពលករខ្មែរធ្វើការនៅប្រទេសថៃប្រមាណ១លាននាក់ ត្រូវបានការយក ចិត្តទុកដាក់ពីអាជ្ញាធរ ថៃ ពួកគាត់មានប្រាក់ ចំណូលសមរម្យសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច។ លោក ស្រីកិត្តិសង្គហបណ្ឌិត ម៉ែន សំអន មានប្រសាសន៏បញ្ជាក់ទៀតថា ៖ កម្ពុជាត្រូវ ការបេទពិសោធន៍អំពីការងារស្ត្រី និង កុមារ នុងចង់មានកិចហចសហការជាមួយភាគីថៃ។

ជាមួយគ្នានោះដែរលោកជំទាវកិត្តិសង្គហបណ្ឌិតបានសំណូមពរ ដល់ភាគីថៃដោយ សហការជាមួយក្រសួងអធិការកិច្ច ជាមួយអាជ្ញាធរថៃលើការងារស្ត្រីនិងកុមារ ។ លោកស្រីកិត្តិសង្គហបណ្ឌិតម៉ែន សំអននិងអញ្ជើញទៅបំពេញទស្សនៈកិច្ចនៅប្រទេសថៃនៅពេលវេលាសមរម្យ ដើម្បីសិក្សាលើការងារស្ត្រីកុមារនៅប្រទេសថៃ។ លោកស្រីកិត្តិសង្គហបណ្ឌិតម៉ែន សំអនបានថ្លែងអំណរគុណដល់ម្ចាស់ក្សត្រី សុរិន្ធ ថន ដែលជួយលើវិស័យអប់រំនៅតំពង់ធំនិងបានចុះMOU កំចាត់ជម្ងឺគ្រុន ចាញ់នៅខេត្តភាគឥសាន្តប្រទេស។ ឆ្លៀតក្នុងឱកាសនោះដែរលោកស្រីកិត្តិសង្គហបណ្ឌិតម៉ែន សំអន បានជំរាបភាគី ថៃអំពីស្ថាន ភាពការត្រៀមបោះឆ្នោត នៅថ្ងៃទី ២៩ខែកក្កដា ឆ្នាំ២០១៨ជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦និងការចុះជួយប្រជា ពលរដ្ឋដែករងគ្រោះដោយគ្រោះធម្មជាតិ។ ការបោះឆ្នោតរើសសមាជិសភានៅពេលខាងមុខនេះមាន២០គណបក្សចូករួមប្រកួតប្រជែង ដោយឡែកគណបក្សប្រជា ជនកម្ពុជានៅដែរជាស្នូលសំខាន់លើអភិ វឌ្ឍន៏ប្រទេសជាតិ មានកំណើនសេដ្ឋកិច្ចខ្ពស់៕ សំរិត

## មិនគួរសោះ ដោយសារតែបាល់មួយ ពលករខ្មែរម្នាក់បាត់បង់ជីវិត

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៨ ម៉ោង ០៩:០៤ ម៉ុត សារុន

ខេត្តបន្ទាយមានជ័យ ៖ ពលករខ្មែរម្នាក់ត្រូវចរន្តអគ្គិសនីឆក់ស្លាប់ បានបង្កឱ្យមានការភ្ញាក់ផ្អើលនៅខេត្តឈុនបុរី ប្រទេសថៃ ក្រោយពីបាល់រត់ចូលក្រោមបន្ទប់ស្នាក់នៅ ហើយយកឈើឆ្កិះ នៅតែយកមិនបាន ក៏លូនចូលទៅយក ហើយដងខ្លួនប៉ះចំជញ្ជាំងស័ង្កសីដែលមានខ្សែភ្លើងដាច់ពីខាងលើ បណ្តាលឱ្យប្រកាច់ស្លាប់នៅនឹងកន្លែងតែម្តង ។ ហេតុការណ៍នេះបានកើតឡើងនៅស្រុកផានថង ខេត្តឈុនបុរី ប្រទេសថៃ កាលពីរសៀលថ្ងៃទី១០ មិថុនា ឆ្នាំ២០១៨ នេះបើយោងតាមគេហទំព័រ និងកាសែតក្នុងស្រុករបស់ថៃចេញផ្សាយកាលពីពេលថ្មីៗ។

តាមប្រភពបានឱ្យដឹងថា ជនរងគ្រោះដែលស្លាប់ឈ្មោះកង កឿយ ភេទប្រុស អាយុ២៣ឆ្នាំ ជាកម្មករសំណង់ មានស្រុកកំណើតនៅស្រុកក្រឡាញ់ ខេត្តសៀមរាប។ អ្នកឃើញហេតុការណ៍ និងជាពលករខ្មែរដូចគ្នាបាននិយាយថា មុនពេលកើតហេតុ ជនរងគ្រោះ និងមិត្តភក្តិជាច្រើនបាននាំគ្នាលេងបាល់ទះ ព្រោះជាថ្ងៃឈប់សម្រាកពេលកំពុងតែលេងនោះ ស្រាប់តែបាល់នោះរត់ចូលទៅក្រោមបន្ទប់ស្នាក់នៅរបស់កម្មករ ហើយដំបូងជនរងគ្រោះបានយកឈើឆ្កិះដើម្បីទាញបាល់ចេញ តែយកមិនដល់ ក៏លូនចូលទៅយក ស្រាប់តែខ្លួនប៉ះទៅនឹងស័ង្កសីជញ្ជាំងបន្ទប់ បណ្តាលឱ្យប្រកាច់ស្លាប់នៅនឹងកន្លែងតែម្តង ។ ក្រោយកើតហេតុ សមត្ថកិច្ចថៃបានចុះទៅដល់កន្លែងកើតហេតុ ហើយពេលធ្វើការត្រួតពិនិត្យទើបរកឃើញខ្សែភ្លើងដែលគេតចូលបន្ទប់ចំណុចស្នាក់នៅផ្នែកខាងលើមានស្នាមដាច់ជាប់នឹងស័ង្កសីជញ្ជាំងបន្ទប់ ទើបបណ្តាលឲ្យឆក់ជនរងគ្រោះស្លាប់បែបនេះ ។

សមត្ថកិច្ចថៃយល់ថា ខ្សែភ្លើងដែលដាច់នោះអាចបណ្តាលមកពីខ្យល់បក់យូរៗទៅ វាកកិតនឹងស័ង្កសី ទើបដាច់ ។ យ៉ាងណាក៏ដោយ ពេលនេះសមត្ថកិច្ចថៃកំពុងស្រាវជ្រាវរកអ្នកតខ្សែភ្លើងខុសបច្ចេកទេសដើម្បីយកទៅសួរនាំហើយ ។ ចំណែកសពពលករដែលស្លាប់ដោយសារឆក់ចរន្តអគ្គិសនីនៅខេត្តឈុនបុរីនេះត្រូវបាននគរបាលអន្តោប្រវេសន៍ច្រកទ្វារអន្តរជាតិប៉ោយប៉ែតប្រាប់តាមទូរស័ព្ទថា ភាគីថៃបានបញ្ជូនសពឲ្យសាច់ញាតិរួចហើយតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតកាលពីវេលាម៉ោង៥ល្ងាចថ្ងៃទី១១ មិថុនានេះ ។ សពត្រូវបានសាច់ញាតិជួលរថយន្តដឹកបន្តយកទៅលំនៅដ្ឋានដើម្បីធ្វើបុណ្យតាមប្រពៃណី៕

# ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨
# អភិបាលរងខេត្តៈកម្លាំងឈរជើងតាមបន្ទាត់ព្រំដែនត្រូវចូលរួមទប់ស្កាត់ចំណាកស្រុកខុសច្បាប់ ទើបការពារការជួញដូរមនុស្សបាន

http://cambodiapolice.com/policekh/ 4:10 pm 12 មិថុនា 2018 50

**បន្ទាយមានជ័យៈ** នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៨នេះ អភិបាលរងខេត្តបន្ទាយមានជ័យបានណែនាំអាជ្ញាធរស្រុក ក្រុងជាប់ព្រំដែន និងកម្លាំងឈរជើងតាមបន្ទាត់ព្រំដែនត្រូវចូលរួមទប់ស្កាត់ចំណាកស្រុកខុសច្បាប់ ទើបការពារការជួញដូរមនុស្សបាន។

លោក ម៉ាក់ សុផាត មន្ត្រីសម្របសម្រួលថ្នាក់ខេត្តអង្គការ វីន រ៉ក អន្តរជាតិមានប្រសាសន៍ថា វគ្គបណ្តុះបណ្តាល ស្តីពីការពង្រឹងសមត្ថភាពជនបង្គោល ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជាត្រូវបានធ្វើឡើងរយៈពេល២ថ្ងៃចាប់ពីថ្ងៃទី១២ដល់១៣ ខែមិថុនា ឆ្នាំ២០១៨ នេះជាយន្តការនិងផែនការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

លោកស្រី ប៉ុក ណាឌី អភិបាលរងខេត្តបន្ទាយមានជ័យមានប្រសាសន៍ថា គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គឺយន្តការ និងផែនការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដំណោះស្រាយគឺច្បាប់ គោលនយោបាយ និងការអនុវត្ត និងកិច្ចសហការ និងភាពជាដៃគូក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ លោកស្រីបានណែនាំ និងដាក់វិធានការដល់អាជ្ញាធរស្រុក-ក្រុងដែលជាប់ព្រំដែន និងកម្លាំងដែលឈរជើងតាមបន្ទាត់ព្រំដែន ត្រូវចូលរួមទប់ស្កាត់ឱ្យបាននៅពលករចំណាកស្រុកខុសច្បាប់តាមបន្ទាន់ព្រំដែន ដើម្បីទប់ស្កាត់ការជួញដូរមនុស្សគ្រប់រូបភាព ការពារសុវត្ថិភាពជូនបងប្អូនប្រជាពលរដ្ឋស្របតាមគោលនយោបាលរបស់រាជរដ្ឋាភិបាលកម្ពុជា ៕

# ក្រសួងការងារបន្តក្រើនរំលឹកដល់ពលករខ្មែរឲ្យមកបំពេញឯកសារជាពលករស្របច្បាប់

https://wmc.org.kh/ ថ្ងៃអង្គារ ទី១២ ខែមិថុនា ឆ្នាំ២០១៨ ធូ វីរៈ

ភ្នំពេញ៖ គណៈកម្មាការផ្តល់ភាពស្របច្បាប់នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បន្តក្រើនរំលឹកដល់ពលករខ្មែរខុសច្បាប់កំពុងបម្រើការងារនៅប្រទេសថៃអោយមកបំពេញបែបបទឯកសារនានា ដើម្បីក្លាយជាពលករស្របច្បាប់ ខណៈដែលការិយាល័យច្រកចេញចូលតែមួយនឹងបិទនៅចុងខែ មិថុនានេះ ដោយគ្មានការពន្យាពេលទេ។

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់គណៈកម្មាការផ្តល់ភាពស្របច្បាប់ ចុះផ្សាយនៅថ្ងៃទី ១១ ខែ មិថុនានេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានក្រើនរំលឹកដល់ពលករខ្មែរខុសច្បាប់កំពុងបម្រើការងារនៅប្រទេសថៃឲ្យប្រញាប់រួសរាន់មកបញ្ជាក់អត្តសញ្ញាណសញ្ជាតិខ្មែរ។ តាមសេចក្តីប្រកាសដដែលនេះ ការទទួលបានអត្តសញ្ញាណសញ្ជាតិខ្មែរ គឺដើម្បីបន្តប័ណ្ណមិនមែនសញ្ជាតិថៃ ឬប័ណ្ណពណ៌ស៊ីជម្ពូ ហើយស្នើសុំទិដ្ឋាការស្នាក់នៅ និងប័ណ្ណអនុញ្ញាការងារ ខណៈដែលការិយាល័យច្រកចេញចូលតែមួយនឹងបិទនៅចុងខែ មិថុនានេះ ដោយគ្មានការពន្យាពេលទៀតទេ។ គណៈកម្មាការផ្តល់ភាពស្របច្បាប់នៃក្រសួងការងារ បញ្ជាក់នៅក្នុងសេចក្តីប្រកាសព័ត៌មានថា ពលករដែលមិនទាន់បានមកបញ្ជាក់អត្តសញ្ញាណសញ្ជាតិខ្មែរ និងលិខិតធ្វើដំណើរពលករខ្មែរ (TD) ហើយនិង ប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (OCWC) ប្រញាប់រួសរាន់មកបញ្ជាក់អត្តសញ្ញាណនៅគណៈកម្មាការផ្តល់ភាពស្របច្បាប់ ហើយពលករខ្មែរដែលចុះបញ្ជីជាមួយអាជ្ញាធរថៃតែមិនទាន់ទទួលបានប័ណ្ណពណ៌ស៊ីជម្ពូ នៅត្រឹមថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៨ ខាងមុខនេះ។

ក្រសួងការងារកម្ពុជាបានចាប់ផ្ដើមបើកការិយាល័យច្រកចេញចូលតែមួយចំនួន ៨០ កន្លែង នៅក្នុងទីក្រុងបាងកក និងតាមបណ្ដាខេត្តមួយចំនួនរបស់ថៃដោយដំណើរការជាងពីរខែមកហើយ ដើម្បីជួយពលករចំណាកស្រុកទៅជាពលករស្របច្បាប់បម្រើការងារនៅប្រទេសថៃ។ ការបើកវិយាល័យនេះ នៅចំពេលអាជ្ញាធរថៃធ្វើការបោសសម្អាតពលករបរទេសរស់នៅដោយខុសច្បាប់ ក្រោមការអនុវត្តន៍ច្បាប់ថ្មីត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ និងពិន័យជាប្រាក់ ចំពោះថៅកែថៃជួលពលករខុសច្បាប់ឲ្យធ្វើការក្នុងរោងចក្រ ឬឧស្សាហកម្មរបស់ខ្លួន។

គណៈកម្មាការផ្ដល់ភាពស្របច្បាប់ បានផ្ដល់ភាពស្របច្បាប់ដល់ពលករខ្មែរខុសច្បាប់បានជិត ៣៨ ម៉ឺននាក់។ ក្នុងចំណោមពលករខ្មែរ ៤០ នាក់ ពុំទាន់ទទួលបានឯកសារស្របច្បាប់ បើគិតត្រឹមថ្ងៃទី ៨ ខែ មិថុនា សប្ដាហ៍មុន។

លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារប្រាប់វិទ្យុស្ត្រីថា ពលករខ្មែរមានចំនួនជាង ២ ម៉ឺននាក់ទៀតដែលមានប័ណ្ណពណ៌ស៊ីជម្ពូរបស់ថៃ ប៉ុន្តែពលករខ្មែរនៅមិនទាន់មកបញ្ជាក់អត្តសញ្ញាណនៅគណៈកម្មាការផ្ដល់ភាពស្របច្បាប់កម្ពុជានៅឡើយទេ។ លោក ហេង សួរ៖ *«គិតត្រឹមថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១៨នេះ យើងនៅសល់ពលករតែចំនួនជាង ២ ម៉ឺននាក់ទៀតប៉ុណ្ណោះដែលមានប័ណ្ណពណ៌ស៊ីជម្ពូរបស់ថៃ ប៉ុន្តែមិនទាន់បានមកធ្វើការបញ្ជាក់អត្តសញ្ញាណពីគណៈកម្មាការផ្ដល់ភាពស្របច្បាប់របស់កម្ពុជាយើង។»*

បើតាមរបាយការណ៍របស់ក្រសួងការងារ និងបណ្ដុះបណ្ដាល វិជ្ជាជីវៈ រកឃើញថា ពលករខ្មែររស់នៅ និងធ្វើការនៅប្រទេសថៃមានចំនួន ១ លាន ៥ ម៉ឺននាក់។ ក្រោយផុតរលុតសុពលភាពផ្ដល់ភាពស្របច្បាប់ដល់ពលករខុសច្បាប់នៅចុងខែ មិថុនា នេះ អាជ្ញាធរថៃនឹងចាប់ផ្ដើមអនុវត្តន៍យុទ្ធនាការបោសសម្អាតពលករខុសច្បាប់ ក្រោមច្បាប់ថ្មីទើបអនុម័ត។ ច្បាប់ថ្មីនេះផ្ដោតការយកចិត្តទុកដាក់ និងការការពារសិទ្ធិពលករជាពិសេសពលករលើទូកនេសាទដោយច្បាប់ថ្មីថៃតម្រូវឲ្យនិយោជិក និងនិយោជកចុះកិច្ចសន្យាក្នុងការផ្ទេរប្រាក់តាមរយៈធនាគារ ហើយថៅកែត្រូវរក្សាកំណត់ត្រាការបង់ប្រាក់ ដើម្បីកាត់បន្ថយការជួញដូរមនុស្ស កេងប្រវ័ញ្ចកម្មករ ដោយមានការត្រួតពិនិត្យដោយតឹងរឹងពីអាជ្ញាធរថៃ។នេះបើតាម កាសែតរបស់ថៃ។

ទោះបីយ៉ាងណា ប្រទេសថៃនៅតែរងការរិះគន់ពីអង្គការសិទ្ធិមនុស្សអន្តរជាតិ ថាជាប្រទេសរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ។ ក្នុងរបាយការណ៍អង្គការ Human Right Watch ដែលមានចំណងជើងថា «ការរំលោភសិទ្ធិ និងការបង្ខំឲ្យធ្វើការនៅឧស្សាហកម្មនៅប្រទេសថៃ» បានចេញផ្សាយនៅដើមឆ្នាំនេះ បង្ហាញថា ពលករខ្មែរបានស្ថិតនៅក្នុងចំណោមពលករជាតិសាសន៍ផ្សេងទៀតរកការរំលោភបំពាន់សិទ្ធិ និងការជួញដូរមនុស្ស។ របាយការណ៍នេះរកឃើញទៀតថា កម្មករនៅលើទូកនេសាទ បើកប្រាក់ខែមិនទៀតទាត់ ហើយទទួលមក្រែទាប និងខ្វះការគាំពារផ្នែកច្បាប់។ អង្គការអន្តរជាតិនេះ ថាពលករធ្វើការលើទូកនេសាទនៅថៃប្រមាណ ៥ ម៉ឺននាក់ ត្រូវបានរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ។ នៅឆ្នាំ ២០១៥ រដ្ឋាភិបាលថៃរកមិនឃើញសូម្បីមួយករណីក្នុងចំណោមពលករជាង ៤៧ ម៉ឺននាក់ត្រូវបានបង្ខំឲ្យធ្វើការហួសកម្លាំង៕

## ពលករខ្មែរម្នាក់ទៀតហើយស្លាប់នៅក្នុងប្រទេសថៃ

http://ppd-news.net/ June 12, 2018

ប្រទេសថៃ ៖ កាលពីយប់មិញនៅវេលាម៉ោង១០យប់មានភ្លៀងធ្លាក់យ៉ាងខ្លាំង និងមានខ្យល់ព្យុះខ្យល់បានបក់ដើមកៅស៊ូបាក់ជួលសង្កត់លើខ្ទមស្នាក់នៅរបស់ពលករខ្មែរ បណ្ដាលឲ្យពលករខ្មែរម្នាក់មានឈ្មោះ ជា គេទ ប្រុស អាយុ៣២ ឆ្នាំបានបាក់កស្លាប់នៅកន្លែងកើតហេតុ។ ហេតុការណ៍នេះកើតឡើងនៅក្នុងសួនកៅស៊ូ ភូមិតះខៀន ឃុំតះខៀន ខេត្តត្រាត ប្រទេសថៃ៕

## ថៃបានចេញសេចក្តីប្រកាសចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៨ តទៅនឹងអនុវត្តច្បាប់តឹងរឹងហើយ មកមើលស្ថានភាពទោសទាំងអស់គ្នា សខ្ទេបខ្ទី។

https://www.facebook.com/profile.php? កម្មករ ឆ្លងដែន 12-6-2018

1-ជនបរទេស-លួចធ្វើការដោយមិនមានលិខិតអនុញ្ញាតធ្វើការ ឬ មានលិខិតអនុញ្ញាតធ្វើការតែធ្វើការផ្ទុយពីលិខិតអនុញ្ញាតធ្វើការបញ្ជាក់ ខុសប្រភេទ ខុសទីកន្លែង ឬ ខុសថៅកែ ចាប់បាននឹងមានទោសផាកពិន័យចាប់ពី 5,000បាត-50,000បាត នៅពេលដែលផាកពិន័យបានហើយនឹងត្រូវបញ្ជូនចេញពីប្រទេសថៃ និងហាមសុំអនុញ្ញាតចូលប្រទេសថៃរយៈពេលពេល2ឆ្នាំ រាប់ចាប់ពីថ្ងៃដែលបានទទួលទោស។

2-ថៅកែ -ទទួលជនបរទេសអោយធ្វើការដោយមិនមានលិខិតអនុញ្ញាតធ្វើការ ឬ មានលិខិតអនុញ្ញាតធ្វើការតែអោយធ្វើការផ្ទុយពីលិខិតអនុញ្ញាតធ្វើការបញ្ជាក់ ខុសប្រភេទ ខុសទីកន្លែង ឬ ខុសថៅកែ ចាប់បាននឹងមានទោសផាកពិន័យចាប់ពី10,000បាត-100,000បាត/ពលករម្នាក់។

បើប្រព្រឹត្តបទល្មើសម្តងហើយម្តងទៀត ចាប់បានផាកពិន័យចាប់ពី50,000បាត-200,000បាតឬទាំងផាកពិន័យនិងជាប់ពន្ធនាគារ ហើយហាមមិនអោយជួលពលករបរទេសរយៈពេល3ឆ្នាំ។

ពលករបរទេសដែលមានគោលបំណងចូលមកធ្វើការក្នុងប្រទេសថៃ គឺត្រូវដំណើរការតាមប្រព័ន្ធ MOUតែម្យ៉ាងប៉ុណ្ណោះ។

## ដល់ពេលហើយបងប្អូនពលករដែលពុំមានឯកសារត្រឹមត្រូវនៅក្នុងប្រទេសថៃ

https://www.facebook.com/profile. កម្មករ ឆ្លងដែន 13-6-2018

ដល់ពេលហើយបងប្អូនពលករដែលពុំមានឯកសារត្រឹមត្រូវនៅក្នុងប្រទេសថៃពេលគេណែនាំសូមមេត្តាយកព្រះនេត្រមើលផង។ អធិប្បាយតាមរូបភាពនិងបញ្ហាជាក់ស្តែង ពាក់ព័ន្ធនឹងបងប្អូនពលករពុំមានឯកសារត្រឹមត្រូវដែលកំពុងលួចស្នាក់អាស្រ័យ និងធ្វើការនៅក្នុងប្រទេសថៃ ដោយសារពេលវេលាអនុវត្តច្បាប់អន្តោប្រវេសន៍របស់ប្រទេសថៃគៀកនឹងចូលមកដល់៖

១-ថៅកែចាប់ផ្តើមបោះបង់ ធ្វើការប្រឈមនឹងថៅកែមិនបើកលុយអោយ និងកាត់លុយ ហើយមិនដំណើរការឯកសារអោយ មិនអាចទាមទារអ្វីបានទាំងអស់ ព្រោះយើងជាពលករពុំមានឯកសារត្រឹមត្រូវ។

២-ជួលគេដំណើរការអោយ មេដៃ មេខ្យល់ និងចាយលុយហើយគេមិនដំណើរការអោយ(បោកប្រាស់)មិនអាចទាមទារអ្វីបានទាំងអស់ ព្រោះជាពលករដែលពុំមានឯកសារស្នាក់និងធ្វើការត្រឹមត្រូវ។

## ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨

## សម្តេចប្រធានព្រឹទ្ធសភា ស្នើអាជ្ញាធរថៃបន្តយុទ្ធនាការផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណជូនពលករកម្ពុជា ដែលមិនទាន់មានឯកសារប្រមាណ ៥៤.៤១៣នាក់

http://www.rasmeinews.com/ June 14, 2018, 4:36 PM

ដោយ: សុផល / ភ្នំពេញ: នៅក្នុងជំនួបជាមួយលោក ផានយ៉ារ៉ាក់ ភុនថ័ប( Panyarak Poolthup )ឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាព នៃព្រះរាជាណាចក្រថៃ ប្រចាំព្រះរាជាណាចក្រកម្ពុជា សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា ស្នើដល់អាជ្ញាធរថៃបន្តសហការជាមួយនឹងក្រុមការងារកម្ពុជាក្នុងការបន្តយុទ្ធនាការផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណជូនពលករកម្ពុជា ដែលមិនទាន់មានឯកសារប្រមាណ ៥៤.៤១៣ នាក់ (ខែឧសភា ឆ្នាំ២០១៨)។ ក្នុងជំនួបសវនាការនាព្រឹកថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨នៅវិមានព្រឹទ្ធសភាសម្តេចវិបុលសេនាភក្តី

សាយ ឈុំ បានលើកឡើងថា រាជរដ្ឋាភិបាលថៃ និងអាជ្ញាធរពាក់ព័ន្ធ ក៏បានសហការជាមួយភាគីកម្ពុជា នៅក្នុងការជួយសម្របសម្រួលឱ្យមានយន្តការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងធ្វើការនៅប្រទេសថៃ។បច្ចុប្បន្ន ពលករកម្ពុជាធ្វើការនៅប្រទេសថៃ ប្រមាណ ១,០៥០,០០០ នាក់ បានរួមចំណែកដ៏សំខាន់នៅក្នុងការ លើកកម្ពស់សេដ្ឋកិច្ច-សង្គមនៅព្រះរាជាណាចក្រកម្ពុជា ជាពិសេស បានជួយលើកកម្ពស់ជីវភាពរស់នៅរបស់ ពួកគេកាន់តែល្អប្រសើរ។

ក្នុងឱកាសនោះ សម្តេចប្រធានព្រឹទ្ធសភា បានសម្តែងនូវការអបអរសាទរ និងស្វាគមន៍ យ៉ាងកក់ក្តៅចំពោះលោក Panyarak Poolthup ដែលត្រូវបានរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ តែង តាំងជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រថៃប្រចាំកម្ពុជា។ សម្តេចប្រធាន ព្រឹទ្ធសភា មានជំនឿជឿជាក់ថាតាមរយៈបេសកកម្មការទូតរបស់ឯកឧត្តមឯកអគ្គរាជទូត នៅព្រះរាជាណាចក្រ កម្ពុជា ពិតជារួមចំណែកពង្រឹងពង្រីកទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រជាជន និងប្រទេសទាំងពីរឱ្យកាន់តែល្អប្រសើរឡើងថែមទៀត ដើម្បីនាំមកនូវផលប្រយោជន៍សម្រាប់ប្រជាជន និងប្រទេសទាំងពីរ។ សម្តេច បានសម្តែងនូវសេចក្តីសប្បាយរីករាយ និងពេញចិត្តជាខ្លាំង ដោយបានមើលឃើញទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងកម្ពុជា-ថៃ បានបន្តរីកចម្រើនលើគ្រប់វិស័យជាបន្តបន្ទាប់គួរជាទីមោទនៈ។ ទំនាក់ទំនងដ៏ល្អនេះ ស្តែងឡើងតាមរយៈការផ្លាស់ប្តូរព្រះរាជទស្សនកិច្ច និងទស្សនកិច្ចរវាងរាជវង្សានុវង្ស រវាងប្រមុខរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងរវាងប្រជាជននៃប្រទេសទាំងពីរ ដែលកាន់តែស៊ីជម្រៅទូលំទូលាយ និងបានគាំទ្រគ្នាទៅវិញទៅមកនៅក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការលើឆាកអន្តរជាតិ។

សម្តេចប្រធានព្រឹទ្ធសភា បានសម្តែងនូវអំណរព្រះគុណ និងអរគុណដ៏ជ្រាលជ្រៅចំពោះរាជវង្សានុវង្សថៃ និងរាជរដ្ឋាភិបាលថៃ ដែលបានគាំទ្រ និងជួយជាបន្តបន្ទាប់ផ្នែកសុខាភិបាល វិស័យអប់រំ សង្គមកិច្ច និង ហេដ្ឋារចនាសម្ព័ន្ធ។ ទន្ទឹមនេះ ទំនាក់ទំនងខាងវិស័យវិនិយោគ ទេសចរណ៍ អប់រំ សុខាភិបាល ហេដ្ឋារចនា សម្ព័ន្ធតភ្ជាប់ ក៏មានការរីកចម្រើនជាលំដាប់ ព្រមទាំងបានបង្កើតនូវយន្តការទ្វេភាគីកម្ពុជា-ថៃ ជាច្រើនវិស័យ ដើម្បីសម្របសម្រួល និងដោះស្រាយបញ្ហានានា សំដៅឱ្យមានការអភិវឌ្ឍរួមគ្នា ប្រកបដោយសន្តិភាព ស្ថិរភាព និងសុខដុមនីយកម្ម សម្រាប់ប្រជាជន និងប្រទេសទាំងពីរ។ សម្តេចប្រធានព្រឹទ្ធសភា ក៏បានអបអរ និងត្រូវជំរុញថែមទៀតនូវទំនាក់ទំនងដ៏ល្អរបស់ស្ថាប័ននីតិប្បញ្ញត្តិ នៃប្រទេសទាំងពីរផងដែរ។ ក្នុងនាមព្រឹទ្ធសភា និងរូបសម្តេចផ្ទាល់ សម្តេចបានសម្តែងនូវសេចក្តីរីករាយ និងត្រៀមខ្លួនជានិច្ចក្នុងការធ្វើ កិច្ចសហប្រតិបត្តិការដ៏ជិតស្និតជាមួយនឹងឯកឧត្តមឯកអគ្គរាជទូត ក៏ដូចជាស្ថានទូតថៃប្រចាំព្រះរាជាណាចក្រកម្ពុជា ដើម្បីរួមចំណែកពង្រឹងពង្រីកចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការ នាំមកនូវផលប្រយោជន៍ទៅវិញ ទៅមកជូនប្រជាជន និងប្រទេសទាំងពីរ។

នៅក្នុងជំនួបសម្តែងការគួរសមនោះ លោក Panyarak Poolthup បានថ្លែងអំណរគុណចំពោះសម្តេចប្រធានព្រឹទ្ធសភា ដែលបានចំណាយពេលវេលាដ៏មានតម្លៃអនុញ្ញាតឲ្យឯកឧត្តមបានចូលជួប សម្តែងការគួរសមនាឱកាសនេះ។ លោកឯកអគ្គរាជទូត បានជម្រាបជូនសម្តេចប្រធានព្រឹទ្ធសភាថា បច្ចុប្បន្ន និងកាលពីពេលកន្លងទៅ ប្រទេសថៃ និងប្រទេសកម្ពុជា មានសភាពការណ៍ប្រហាក់ប្រហែលគ្នា ដោយសារតែមានការរិះគន់ពីពួកបរទេសមួយចំនួន ដែលពាក់ព័ន្ធនឹងបញ្ហាសិទ្ធមនុស្ស បញ្ហាលទ្ធិប្រជាធិបតេយ្យ។ ឯកឧត្តមឯកអគ្គរាជទូត បានវាយតំលៃខ្ពស់ចំពោះការដឹកនាំដ៏ត្រឹមត្រូវរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី និងរាជរដ្ឋាភិបាលកម្ពុជា ដែលបានផ្តល់តម្លៃ នឹងប្តេជ្ញាខ្ពស់ក្នុងការខិតខំថែរក្សាបាននូវសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខសណ្តាប់ធ្នាប់សង្គម ដើម្បីជានាឲ្យមានការអភិវឌ្ឍជាលំដាប់។

លោកឯកអគ្គរាជទូត បានសម្ដែងនូវការសប្បាយរីករាយដោយសារតែ នាយករដ្ឋមន្ត្រីនៃប្រទេសទាំងពីរ តែងតែបានជួបគ្នាជាញឹកញាប់នៅក្នុងគ្រប់ខ័ណ្ឌអន្តរជាតិ ជាពិសេសនៅក្នុងវេទិកានៃកិច្ចប្រជុំអាស៊ាន ហើយនៅថ្ងៃនេះដែរ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវចូលរួមក្នុងកិច្ចប្រជុំកំពូលយុទ្ធសាស្ត្រ នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាយ៉េយ៉ាវ៉ាឌី-ចៅប្រាយ៉ា-មេគង្គ (Ayeyawady-Chao Phraya-Mekong Economic Cooperation Strategy/ACMECS) លើកទី៨ និងកិច្ចប្រជុំកំពូលកម្ពុជា-ឡាវ-មីយ៉ាន់ម៉ា-វៀតណាម (Cambodia-Lao PDR-Myanmar-Viet Nam Summit/ CLMV) លើកទី៩ នៅទីក្រុងបាងកក ប្រទេសថៃ។

លោកឯកអគ្គរាជទូត បានវាយតម្លៃខ្ពស់ចំពោះការពង្រឹងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ ដ៏ល្អរវាងប្រជាជន រាជរដ្ឋាភិបាល ក៏ដូចជាអង្គការនីតិប្បញ្ញត្តិ នៃប្រទេសទាំងពីរ(កម្ពុជា-ថៃ)។ តាមរយៈ បេសកកម្មការទូត របស់ឯកឧត្តមនៅព្រះរាជាណាចក្រកម្ពុជា ឯកឧត្តមអគ្គរាជរដ្ឋទូតថៃបានសន្យាថា នឹងខិតខំឲ្យអស់ពីលទ្ធភាព ដើម្បីជំរុញឲ្យទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងសភាទាំងពីរ ឲ្យកាន់តែល្អប្រសើរថែមទៀត តាមរយៈការផ្លាស់ប្ដូរដំណើរទស្សនកិច្ចនិងបទពិសោធន៍គ្នាទៅវិញទៅមករវាងថ្នាក់ដឹកនាំ ក៏ដូចជាមន្ត្រីផងដែរ៕

## ពលករខ្មែរគ្រោះថ្នាក់លើទឹកដីថៃ ស្លាប់ និងរបួសជាបន្តបន្ទាប់

https://www.khmerload.com/news/ Khmerload 08:06 June 14, 2018

ខេត្តបន្ទាយមានជ័យ ៖ ពលករខ្មែរស្លាប់របួសជាហូរហែលើទឹកដីថៃក្នុងករណីផ្សេងគ្នា ក្នុងនោះ គ្រោះថ្នាក់ចរាចរណ៍របួសធ្ងន់២នាក់ និងម្នាក់ស្លាប់ដោយគ្រោះធម្មជាតិបាក់ដើមឈើសង្កត់ នៅខេត្តចាន់បុរី និងត្រាត នេះបើយោងតាមគេហទំព័រក្នុងស្រុករបស់ថៃចេញផ្សាយ។ ហេតុការគ្រោះថ្នាក់ ចរាចរណ៍កើតឡើងនៅព្រឹកថ្ងៃទី១៣ មិថុនា ២០១៨ ក្នុងស្រុកម៉ាក់ខាម ខេត្តចាន់បុរី ដោយរថយន្តកាមរី តូយ៉ូតាកូរ៉ូណា ពណ៌ស្វាយ ពាក់ស្លាកលេខថៃ 9726 បើកបុកបង្គោលខ្សែភ្លើងចំណុចផ្លូវកោង។ ជនរងគ្រោះ ជាពលករខ្មែរ ប្ដីឈ្មោះ សេម សុភា អាយុ៣៤ឆ្នាំ ប្រពន្ធឈ្មោះ ជួន គីម អាយុ៣១ឆ្នាំ។

ប្រភពថា ករណីគ្រោះថ្នាក់នេះដោយសារថយន្តបើកលឿនគាប់ជួនមេឃកំពុងភ្លៀងផងក៏រអិលបណ្ដាលឲ្យកើតគ្រោះថ្នាក់ចរាចរណ៍នេះឡើង។ នៅកន្លែងកើតហេតុជនរងគ្រោះជាប្រពន្ធគាបជាប់ក្នុងរថយន្តត្រូវអាជ្ញាធរ និងសមត្ថកិច្ចពិសេសក្រុមជួយសង្គ្រោះបន្ទាន់ប្រើឧបករណ៍ជួយកាត់ទ្វាររថយន្តដើម្បីដឹកយកទៅមន្ទីរពេទ្យក្នុងស្រុក។ ដោយឡែកកាលពីថ្ងៃទី១២ មិថុនា ម្សិលមិញ នៅឯខេត្តត្រាត មានករណីគ្រោះធម្មជាតិ ដើមកៅស៊ូដួលសង្កត់ខ្ទមស្នាក់ នៅបណ្ដាលឲ្យជនរងគ្រោះជាពលករខ្មែរម្នាក់ បាក់កស្លាប់នៅនឹងកន្លែង។ ជនរងគ្រោះឈ្មោះ ដា ភេទប្រុស អាយុ៣២ឆ្នាំ៕

## ពលករខ្មែរម្នាក់ ឈ្មោះ Phoun Sisouk អាយុ ៤៧ ឆ្នាំ ជាកម្មករធ្វើការក្នុងរោងចក្រកែច្នៃឈើ កើតឧបទ្ទវហេតុត្រូវម៉ាស៊ីនកិនឈើគៀបស្លាប់យ៉ាងអាណោចអាធ័ម

https://www.facebook.com/ **ពលករខ្មែរ**-khmerlabour June 14, 2018

"បុរសពលករខ្មែរម្នាក់ ឈ្មោះ Phoun Sisouk អាយុ ៤៧ ឆ្នាំ ជាកម្មករធ្វើការក្នុងរោងចក្រកែច្នៃឈើ កើតឧបទ្ទវហេតុត្រូវម៉ាស៊ីនកិនឈើគៀបស្លាប់យ៉ាងអាណោចអាធ័ម"។ ហេតុការណ៍នេះបានកាលពីវេលាម៉ោង១០ព្រឹកថ្ងៃព្រហស្បតិ៍ទី១៤ ខែមិថុនា ឆ្នាំ២០១៨ ស្ថិតនៅរោងចក្រកែច្នៃឈើក្នុងស្រុកគុនហាន ខេត្តស៊ីសាកេត ប្រទេសថៃ។ ១៤-០៦-២០១៨ Cr. ពលករខ្មែរ-KhmerLabour

## អាណិតណាស់លោកអើយ! ឪពុកម្ដាយទៅធ្វើការជាកម្មករនៅថៃ រស់នៅជាមួយជីដូន

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៨ ម៉ោង ១១:៥២ ចុក សុខា

ខេត្តកំពង់ធំ ៖ ក្មេងប្រុសម្នាក់បានលង់ទឹកស្រះស្លាប់ បានបង្កឱ្យមានការភ្ញាក់ផ្អើលកាលពីវេលាម៉ោង៥និង ៣០នាទីល្ងាចថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨ ស្ថិតនៅចំណុចស្រះទឹកមួយកន្លែងក្នុងភូមិតាប៉ោង ឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។

លោកវរៈសេនីយ៍ត្រី យន់ ឆៃយាន អធិការរងនគរបាលស្រុកកំពុងស្វាយបានឲ្យដឹងថា កុមារដែលស្លាប់ ឈ្មោះ គង់ គួន ភេទប្រុស អាយុ៣ឆ្នាំ មានឪពុកឈ្មោះ ង៉ោ គង់ អាយុ៣១ឆ្នាំ និងម្ដាយឈ្មោះ ប៊ី ចាន់ថន អាយុ ២៨ឆ្នាំ រស់នៅភូមិកើតហេតុខាងលើ។

បើយោងតាមការឲ្យដឹងពីសាច់ញាតិនិយាយថា ឪពុកម្ដាយកុមាររងគ្រោះខាងលើបាននាំគ្នាទៅធ្វើការជាកម្មករនៅឯប្រទេសថៃ ហើយក៏បានផ្ញើកូនប្រុស(កុមារដែលលង់ទឹកស្លាប់)ឲ្យរស់នៅជាមួយនឹងជីដូន ។ មុនពេលកើតហេតុ ជីដូនជាប់រវល់នឹងការងារមិនបានប្រយ័ត្នមើលថៅ ពេលនោះកុមាររងគ្រោះក៏បានដើរលេងនៅតាមមាត់ស្រះខាងលើ ហើយក៏រអិលជើងធ្លាក់ចូលទៅក្នុងស្រះបណ្ដាលឲ្យឈ្លក់ទឹកស្លាប់យ៉ាងអាណោចអាធ័ម ។ មួយសន្ទុះក្រោយពីបាត់ថៅក៏នាំគ្នាដើររក ឃើញដានជើងធ្លាក់ចូលក្នុងស្រះទឹកនាំគ្នាចុះរាវរកស្រង់យកសពមកដាក់លើផ្ទះ ។

ពេលទទួលបានព័ត៌មាននេះភ្លាម កំលាំងជំនាញក៏បានចុះដល់ទីកន្លែងកើតហេតុ និងពិនិត្យសព រកឃើញថា កុមាររងគ្រោះខាងលើពិតជាស្លាប់ដោយសារទៅលង់ទឹកស្រះប្រាកដមែន ក៏បានប្រគល់សពជូនក្រុមគ្រួសារយកទៅធ្វើបុណ្យតាមប្រពៃណី។

## ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៨

## ចាប់ស្ត្រីជាប់ចោទម្នាក់ តាមដីកាពីបទអូសទាញពេស្យាចារកុមារ ពេលរត់ចេញពីមន្ទីរពេទ្យទៅសម្រាលកូន

http://www.cen.com.kh/archives/ June 19, 2018

ភ្នំពេញ៖ សមត្ថកិច្ចនគរបាលផ្នែកយុត្តិធម៌ ខណ្ឌច្បារអំពៅ បានស្វែងរកចាប់ខ្លួនស្ត្រីម្នាក់ តាមដីកាបង្គាប់ឲ្យចាប់ខ្លួនរបស់លោកគុជ គីមឡុង ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ លេខ០០១ អ.យ.ក ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៨ ពីបទអំពើអូសទាញពេស្យាចារកុមារ ប្រព្រឹត្តនៅចំណុចអាផាតមេនឌីអឹម ផ្លូវ៤៧០ សង្កាត់ទួលទំពូង២ ខណ្ឌចំការមន កាលពីដើមឆ្នាំ២០១៧។ ដោយសារតែស្ត្រីរូបនេះ មានផ្ទៃពោះ ហើយត្រូវសម្រាកកូននោះ ត្រូវបានសមត្ថកិច្ចពន្ធនាគារព្រៃស បញ្ជូនមកមន្ទីរពេទ្យ ហើយក្រោយពេលសម្រាលកូនរួច ស្ត្រីរូបនោះ ក៏រត់គេចខ្លួន ហើយត្រូវសមត្ថកិច្ចស្រាវជ្រាវ ចាប់ខ្លួនមកវិញ។

លោកវរសេនីយ៍ទោ ម៉ៅ សឿត អធិការរងនគរបាលខណ្ឌច្បារអំពៅ បានឱ្យដឹងថា ជនសង្ស័យឈ្មោះ ជា សុខជី អាយុ២៧ឆ្នាំ ជន ជាតិខ្មែរ មុខរបរនៅផ្ទះ ស្នាក់នៅភូមិដើមចាន់ សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ។ ចាប់ខ្លួន នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង១១និង១០នាទី នៅភូមិដើមម៉ាកភ្លឿ សង្កាត់ច្បារ អំពៅ១ ខណ្ឌច្បារអំពៅ។ នៅថ្ងៃទី១៧ខែវិច្ឆិកាឆ្នាំ២០១៧ មណ្ឌលអប់រំកែប្រែទី២ (មព ២ ព្រៃស) បានបញ្ជូនជនជាប់ឃុំជា សុខជី ទៅសង្គ្រោះបន្ទាន់ ដោយឈឺពោះគ្រប់ខែឆ្លងទន្លេ នៅមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក។ កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៧ វេលាម៉ោង៦រំលងអធ្រាត្រនៅក្នុងមន្ទីរពេទ្យ ដោយមន្ត្រីពន្ធនាគារមានការធ្វេសប្រហែសមួយភ្លែត បណ្ដាលឲ្យជនជាប់ឃុំ សុខជី មានឱកាសគេចខ្លួនបាត់តែម្ដង។

ព្រះរាជអាជ្ញារង គុជ គីមឡុង បានចេញដីសម្រេចបង្គាប់ឲ្យកងកម្លាំងសាធារណៈទាំងអស់ ស្វែងរកចាប់ខ្លួន ឈ្មោះ ជា សុខជី យកមកធ្វើការឃុំខ្លួនបន្តតាមនីតិវិធី ។ ស្ត្រីរូបនោះ ត្រូវជាប់ចោទពីបទ អំពើអូសទាញពេស្យា

ចារកុមារ តាមបញ្ញត្តិមាត្រា ៣៥ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពោះធ្វើអាជីវកម្មផ្លូវភេទ ប្រព្រឹត្ត នៅចំណុចអាផាតមេនឌីអឹម ផ្លូវលេខ៤៧០ សង្កាត់ទួលទំពូងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីដើមឆ្នាំ ២០១៧។ ស្ត្រី ជា សុខធី អាយុ២៧ឆ្នាំ ត្រូវបានឃុំខ្លួនតាមដីកាបង្គាត់ឲ្យឃុំខ្លួនលេខ ៣២២៥ ទ ដ.ឃ.ដ ចុះថ្ងៃទី ២ ខែឧសភា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ៕ ដោយៈបញ្ញាស័ក្តិ

## កម្ពុជា-ថៃបញ្ចប់យុទ្ធនាការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា

http://www.rasmeinews.com/ June 19, 2018, 6:33 AM

*ដោយៈដេប៉ូ/ភ្នំពេញ*.ប្រទេសកម្ពុជានិងថៃបានប្រកាសថានឹងបញ្ចប់យុទ្ធនាការផ្តល់ភាពស្របច្បាប់ដល់ពលកម្ពុជាដែលកំពុងបំពេញការងារនៅប្រទេសថៃត្រឹមថ្ងៃទី១ ខែកក្កដា ឆ្នាំ២១០៨។ បន្ទាប់ពីប្រទេសទាំងពីរបានផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាគិតត្រឹមថ្ងៃទី១៨ខែមិថុនាឆ្នាំ២០១៨ចំនួន១លាន៧ម៉ឺននាក់រួចមក។ យោងតាមសេចក្តីជូនដំណឹងរបស់គណៈកម្មាធិការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅនិងធ្វើការនៅប្រទេសថៃបានឱ្យដឹងថាលទ្ធផលនេះធ្វើឡើងបន្ទាប់ពី លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានបំពេញទស្សនកិច្ចនៅប្រទេសថៃ។ក្នុងនោះបានជួបពិភាក្សាការងារជាមួយរដ្ឋមន្ត្រីក្រសួងការងារថៃ លោកPoGenAdlSangsingkeoកាលពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៨រួចមក។ ក្នុងសេចក្តីជូនដំណឹងដដែលបានបញ្ជាក់ថាគិតចាប់ពីយុទ្ធនាការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃដែលគិតត្រឹមថ្ងៃទី១៨ខែមិថុនាឆ្នាំ២០១៨ប្រទេសទាំងពីរបានរួមគ្នាផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ចំនួន១លាន៧ម៉ឺននាក់។ ប្រភពដដែលនេះបានបញ្ជាក់បន្ថែមថាក្នុងកិច្ចសហប្រតិបត្តិការកន្លងមកប្រទេសទាំងពីរបានបញ្ជាក់អត្តសញ្ញាណថ្មីជូនពលករកម្ពុជាដែលមានប័ណ្ណស៊ីជំពូ( ប័ណ្ណមិនមែនសញ្ជាតិថៃ )ដែលចេញដោយភាគីថៃដើម្បីយកទៅសុំភាពស្របច្បាប់ពីភាគីថៃបានចំនួនប្រមាណ៤២ម៉ឺននាក់។

ផ្តល់សហការគ្នាសម្រួលឯកសារនិងផ្តល់ភាពស្របច្បាប់ដល់ពលករតាមរយៈ MOUបានចំនួនប្រមាណ៦៥ម៉ឺននាក់។ ជាមួយគ្នាភាគីទាំងពីរនឹងប្តេជ្ញាបញ្ចប់ការបញ្ជាក់អត្តសញ្ញាណដល់ពលករកម្ពុជាចំនួនប្រមាណ១ម៉ឺននាក់ទៀតឱ្យបានចប់មុនថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ខាងមុខ។ ក្រៅពីនេះភាគីថៃក៏បានឯកភាពអនុញ្ញាតឱ្យពលកម្ពុជាដែលមិនទាន់មានឯកសារក្រោយពេលបញ្ចប់យុទ្ធនាការនេះអាចត្រឡប់មកកម្ពុជា ដើម្បីស្នើសុំធ្វើឯកសារស្របច្បាប់ហើយវិលត្រឡប់ទៅធ្វើការនៅប្រទេសថៃវិញជាពលករ MOU ។ ទាក់ទិនទៅនឹងពលកម្ពុជាដែលមិនទាន់មានឯកសារឬបាត់ឯកសារនោះវិញ ភាគីថៃសន្យាសហការជាមួយភាគីកម្ពុជាដោយភាពទន់ភ្លន់ដោយក្នុងនេះនឹងជូនដំណឹងមកស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃនិងទីប្រឹក្សាទទួលបន្ទុកពលករដើម្បីរួមគ្នាដោះស្រាយនិងចេញលិខិតបើកផ្លូវដើម្បីពលករទាំងនោះបានវិលត្រឡប់មកកម្ពុជាវិញ៕S/

## កម្ពុជា-ថៃ៖ ពលករខ្មែរជាង១លាននាក់ទទួលបានភាពស្របច្បាប់ ខណៈថៃរឹតបន្តឹងច្បាប់

http://km.rfi.fr/cambodia/ ដោយ សឿង ភារៈ 18/06/2018

គិតត្រឹមថ្ងៃទី១៦ ខែមិថុនា កម្ពុជា និងភាគីថៃ បានសហការគ្នា បញ្ជាក់អត្តសញ្ញាណថ្មីឲ្យពលករខ្មែរ បានប្រមាណ៥៤ម៉ឺននាក់ និង៥០ម៉ឺននាក់ទៀត បានទទួលភាពស្របច្បាប់តាមការយោគយល់គ្នារវាងកម្ពុជា និងថៃ។ នេះបើតាមអ្នកនាំពាក្យក្រសួងការងារកម្ពុជា។ ជាការបញ្ជាក់អត្តសញ្ញាណសម្រាប់ពលករបរទេស ដើម្បីបានភាពស្របច្បាប់ធ្វើការក្នុងប្រទេសថៃ ខណៈអាជ្ញាធរថៃគ្រោងនឹងអនុវត្តច្បាប់គ្រប់គ្រងពលករបរទេស នៅដំណាច់ខែមិថុនានេះ។

លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារ បានប្រាប់វិទ្យុបារាំងអន្តរជាតិតាមសារអេឡិចត្រូនិចថា គិតត្រឹមថ្ងៃទី១៦ ខែមិថុនា ២០១៨ កម្ពុជា និងភាគីថៃបានសហការគ្នាបញ្ជាក់អត្តសញ្ញាណថ្មី ជូនពលករកម្ពុជា ដែលមានបណ្ណពណ៌ស៊ីជម្ពូ(បណ្ណមិនមែនសញ្ជាតិថៃ) ចេញដោយភាគីថៃ ដើម្បីយកទៅសុំភាពស្របច្បាប់ពីភាគីថៃ បានចំនួនប្រមាណ ៥៤ម៉ឺននាក់។ លោកបន្តថា ទន្ទឹមនឹងនេះ ក្រសួងការងារកម្ពុជា បានសហការគ្នាសម្រួលឯកសារ និងផ្តល់ភាពស្របច្បាប់ដល់ពលករជាលក្ខណៈនៃការយោគយល់គ្នា (MoU) បានចំនួនប្រមាណ៥០ម៉ឺននាក់ផ្សេងទៀត។ ដោយឡែកសម្រាប់ពលករ ដែលមិនមានបណ្ណពណ៌ស៊ីជម្ពូ គឺក្រសួងការងារកម្ពុជានឹងបន្តសហការជាមួយភាគីថៃសម្រួលឲ្យពលករខ្មែរអាចចេញមកធ្វើឯកសារនៅកម្ពុជារួចចេញទៅវិញជាពលករ តាមរយៈការយោគយល់គ្នានៃក្រសួងការងារទាំងពីរវិញ។ នេះបើតាមលោក ហេង សួរ។

នាយកដ្ឋានផ្នែកការងាររបស់ថៃ លោក Anurak Thossarat បានបញ្ជាក់ កាលពីដើមខែមិថុនា ប្រាប់សារព័ត៌មាន The Nation ថា ការចុះឈ្មោះពលករបរទេសក្នុងប្រទេសថៃ នឹងមិនមានការពន្យារពេលតទៅទៀតទេ។ នាយកដ្ឋានការងារថៃបន្ថែមថា នៅក្រោយថ្ងៃទី៣០ ខែមិថុនា ពលករដែលធ្វើការខុសច្បាប់ ថៅកែរបស់ពួកគេនឹងប្រឈមនឹងការផាកពិន័យពីអាជ្ញាធរថៃក្រោមច្បាប់គ្រប់គ្រងពលករបរទេស ដែលបានវិសោធនកម្មកាលពីឆ្នាំ ២០១៧កន្លងទៅ។

បើតាមការជូនដំណឹងរបស់អគ្គនាយកដ្ឋានការងារថៃ ការបញ្ជាក់អត្តសញ្ញាណសញ្ជាតិខ្មែរ ការបន្តបណ្ណមិនមែនសញ្ជាតិថៃ(បណ្ណពណ៌ស៊ីជម្ពូ) និងការស្នើសុំទិដ្ឋាការស្នាក់នៅ និងបណ្ណអនុញ្ញាតការងារពីការិយាល័យច្រកចេញចូលតែមួយ នឹងត្រូវបញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ ខាងមុខនេះ ដោយមិនមានការពន្យារពេលឡើយ។

សូមជម្រាបជូនថា ពលករបរទេសដែលធ្វើការនៅក្នុងប្រទេសថៃ ដោយគ្មានការអនុញ្ញាតនឹងត្រូវផាកពិន័យពី១៥៥ដុល្លារ ដល់១,៥៦០ដុល្លារ ហើយនឹងមិនអនុញ្ញាតឲ្យដាក់ពាក្យសុំធ្វើការរយៈពេល២ឆ្នាំ។ ចំណែកឯនិយោជករូបណា ដែលទទួលយកពលករបរទេសមកធ្វើការខុសច្បាប់នឹងត្រូវផាកពិន័យពី៣១២ដុល្លារ ដល់ ៣,១២០ដុល្លារ ក្នុងពលករម្នាក់៕

## ឯកឧត្តម អ៊ិត សំហេង អញ្ជើញចុះសួរសុខទុក្ខ និងសំណេះសំណាលជាមួយពលករខ្មែរ នៅប្រទេសថៃ

https://www.facebook.com/clcw.gov.kh/ គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជានៅប្រទេសថៃ
June 17 at 9:22pm

(ខេត្តឈុនបុរី ប្រទេសថៃ)៖ ឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អញ្ជើញសួរសុខទុក្ខ និងសំណេះសំណាលជាមួយពលករខ្មែរដែលកំពុងបម្រើការងារនៅរោងចក្រ KING PAC INDUSTRIAL CO.,LTD. ជារោងចក្រផលិតថង់ប្លាសស្ទិច ដែលមានពលករកម្ពុជាធ្វើការនៅទីនោះមានចំនួនជាង ១ពាន់នាក់ ស្ថិតនៅក្នុងខេត្តឈុនបុរី ប្រទេសថៃ នាព្រឹកថ្ងៃទី១៧ ខែមិថុនានេះ។ ឯកឧត្តមរដ្ឋមន្ត្រី ពិតជាមានក្តីសប្បាយរីករាយ ដែលបានមកជួបសួរសុខទុក្ខបងប្អូនពលករខ្មែរយើង និងអរគុណដល់ ឯកឧត្តម រដ្ឋមន្ត្រីក្រសួងការងារថៃ ដែលបាន រៀបចំកម្មវិធីជួបជុំនាពេលនេះ។ប្រការនេះ បង្ហាញ ពីកិច្ចសហប្រតិបត្តិការ ដ៏ ជិតស្និទ្ធ រវាងប្រទេសយើងទាំងពីរ កម្ពុជា-ថៃ ពី ទំនាក់ទំនង ដ៏ ល្អ រវាង រាជរដ្ឋាភិបាល ទាំងពីរ កម្ពុជា-ថៃ និង កិច្ចសហការយ៉ាង ស្អិតល្មួត រវាង ក្រសួងការងារ នៃ ប្រទេសទាំងពីរ កម្ពុជា ថៃ ។

ឯកឧត្តមរដ្ឋមន្ត្រី អរគុណក្រុមហ៊ុនថៃ ទាំងអស់ដែលបានទទួលពលករ កម្ពុជា ឲ្យធ្វើការនៅក្នុង សហគ្រាស របស់ខ្លួននិង បាន ផ្តល់នូវលក្ខខណ្ឌ ការងារ ល្អ ស្របតាមច្បាប់ នៃព្រះរាជាណាចក្រថៃ និង MOU ស្តីពី កិច្ច

សហការលើ វិស័យការងារ នៃប្រទេសទាំងពីរ កម្ពុជា ថៃ។ ឯកឧត្តមបានពាំនាំមកនូវ ការផ្តាំផ្ញើសាកសួរសុខទុក្ខពីសំណាក់ សម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ជូនដល់បងប្អូនខ្មែររស់នៅថៃទាំងអស់ ដែលជានិច្ចកាលសម្តេចតែងតែយកចិត្តទុកដាក់ពីសុខទុក្ខរបស់បងប្អូនជាប់ជានិច្ច។

ឯកឧត្តមលើកឡើងថា រាជរដ្ឋាភិបាលកម្ពុជា បានចាត់តាំងប្រតិភូថ្នាក់ដឹកនាំ និងអាជ្ញាធរគ្រប់ខេត្ត មកសួរសុខទុក្ខ បងប្អូននៅ ថៃនិងបានកំពុងយកចិត្តទុកដាក់ដល់គ្រួសារបងប្អូនពលករខ្មែរនៅតាមមូលដ្ឋានក្នុងប្រទេសថៃ។ គោលនយោបាយ របស់ រាជរដ្ឋាភិបាលកម្ពុជា គឺ ផ្តល់ នូវ ការគាំទ្រ ដល់បងប្អូន ពលករ និង ក្រុមគ្រួសារ។ មិនដូចបក្សប្រឆាំង និង អង្គការក្រៅរដ្ឋាភិបាល ប្រឆាំងមួយចំនួន ចុះមកជួបបងប្អូនយើងនៅក្រៅប្រទេសតែងតែនិយាយភូតកុហក តាំងខ្លួនជាអ្នកជួយពលករ តែតាមពិតបោកប្រាស ទឹកចិត្តបងប្អូនប្រឆាំងស្អប់រាជរដ្ឋាភិបាលដែលខំជួយបងប្អូនពិតប្រាកដ។ តាមពិតពួកនេះមានគំនិតអាក្រក់ មិនទទួលស្គាល់តម្លៃការងារនិងសិទ្ធរបស់បងប្អូនពលករឡើយ ប្រើពាក្យប្រមាថពលករថា ជាខ្ញុំកញ្ជះគេ ជាវណ្ណៈថោកទាបទម្លាក់កំហុសលើរដ្ឋាភិបាលដែលខំការងារជូនបងប្អូនពិតប្រាកដ ទាំងអស់នេះដែលយើងមិនអាចទទួលយកបានឡើយ។

ឯកឧត្តម សូមកោតសសើរបងប្អូនពលករខ្មែរយើងគឺជាពលរដ្ឋដ៏ឆ្នើមរបស់ជាតិ រកប្រាក់ចំណូលជួយគ្រួសារ តាមរយៈ កសាង ជីវភាពគ្រួសារ កាត់បន្ថយភាពក្រីក្រ និង អភិវឌ្ឍន៍ ប្រទេសជាតិ ១ឆ្នាំ បាន ប្រមាណ ២ ពាន់លានដុល្លារ។ បងប្អូនពលករ ចេះជំនាញការងារដែលកំពុងធ្វើពេលត្រឡប់ទៅវិញមានការងារនិងកសាងប្រទេសតាមរយៈការងារនៅក្នុងស្រុកយើង។បងប្អូនបាន ជួយ ផ្សារភ្ជាប់ ទំនាក់ទំនង រវាងប្រជាជន និង ប្រជាជនប្រទេសទាំងពីរឈ្នះឈ្នះទាំងអស់គ្នា។

## LPNស្វែងរកយុត្តិធម៌ជូនពលករខ្មែរដែលរងគ្រោះដោយសារអំពើជួញដូរមនុស្សនៅក្នុងប្រទេសថៃ

https://www.facebook.com/khmerlabour/ ពលករខ្មែរ-KhmerLabour 18-06-2018

នៅថ្ងៃច័ន្ទទី១៨ ខែមិថុនា ឆ្នាំ២០១៨នេះ តំណាងមូលនិធិ LPN ប្រទេសថៃដឹកនាំដោយលោក SamakTubtanee បានធ្វើដំណើរឆ្ពោះទៅកាន់ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ប្រទេសកម្ពុជា ដើម្បីទទួលបុរសពលករខ្មែរម្នាក់ ដែលជនរងគ្រោះដោយសារអំពើជួញដូរមនុស្សបន្ទាប់ពីគាត់ត្រូវថៅកែរោងចក្រផលិតទឹកកកនៅក្នុងស្រុកបាងស៊ីមឿង ខេត្តនុនថាក់បុរីរំលោភពានសិទ្ធិការងារកាលពីដើមខែកុម្ភៈ ឆ្នាំ២០១៨កន្លងទៅ ។

ក្នុងការធ្វើដំណើរទៅទទួលជនរងគ្រោះលើកនេះ គឺបន្ទាប់ពីអគ្គនាយកដ្ឋានតម្រួតថៃ ស្នើសុំមូលនិធិLPN ទៅទទួលបុរសពលករខ្មែររងគ្រោះមកការស៊ើបអង្កេតសាក្សីបន្ថែម ដើម្បីបន្តនិតិវិធីតាមច្បាប់ទៅតុលាការអោយរកយុត្តិធម៌ជូនពលករខ្មែរដែលរងគ្រោះ។ យោងតាមការបញ្ជាក់របស់ លោក Samak Tubtanee ក្រុមការងារមូលនិធិ LPN ប្រទេសថៃបានប្រាប់ឲ្យថា រយៈកន្លងមកជនរងគ្រោះរងមានការលំបាកយ៉ាងខ្លាំងទាំងបញ្ហាសុខភាព និងជីវភាពរស់នៅបន្ទាប់ពីធ្លាក់ក្នុងក្រញ៉ាំអំពើជួញមនុស្សនៅក្នុងប្រទេសថៃ។ ហើយការធ្វើដំណើរទៅកាន់ប្រទេសកម្ពុជាលើកនេះក៏ដោយសារបានការរួមសហការពីអាជ្ញាធរមានសមត្ថកិច្ចប្រទេសថៃ និងអាជ្ញធរមានសមត្ថកិច្ចប្រទេសកម្ពុជា,មន្ត្រីកុងស៊ុល,តម្រួតព្រំដែន ដែលជួយសម្រួលដល់រូបគាត់ទើបរូបគាត់អាចធ្វើដំណើរទៅដល់ខេត្តបាត់ដំបង,ពោធិ៍សាត់ និងកំពុងឆ្នាំដែលជាលំនៅដ្ឋានរបស់ជនរងគ្រោះ ។ ហើយបច្ចុប្បន្នជនរងគ្រោះបានធ្វើដំណើរចូលមកកាន់ប្រទេសថៃ ប្រកបដោយសុវត្ថិភាព ។

ក្នុងនោះតំណាងមូលនិធិ LPN ប្រទេសថៃ សូមថ្លែងអំណរគុណដល់អាជ្ញាធរមានសមត្ថកិច្ចកម្ពុជា ព្រមទាំងមន្ត្រីកុងសូលប្រចាំព្រំដែនកម្ពុជា-ថៃ ព្រមទាំងអាជ្ញាធរមានសមត្ថកិច្ចទាំងអស់អស់ដែលជួយសម្រួលការធ្វើដំណើរលើកនេះប្រកបដោយជោគជ័យ និងក្តីមនុស្សធម៌ចំពោះជនរងគ្រោះ និងក្រុមការងារLPN។

# ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨

## ថៃឯកភាពបញ្ជូនពលករខ្មែរគ្មានឯកសារ មកស្រុកកំណើតវិញ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៨ ម៉ោង ០០:២៨ អ៊ាង ប៊ុនរិទ្ធ

រាជធានីភ្នំពេញ ៖ ប្រមុខដឹកនាំក្រសួងការងារកម្ពុជា និងប្រមុខដឹកនាំក្រសួងការងារថៃ បានឯកភាពគ្នាបញ្ជូនពលករខ្មែរដែលគ្មានឯកសារមកស្រុកកំណើតវិញ បញ្ចប់ការបញ្ជាក់ អត្តសញ្ញាណដល់ពលករកម្ពុជាចំនួនប្រមាណ១ម៉ឺននាក់ឲ្យបានចប់មុនថ្ងៃទី៣០ មិថុនា ឆ្នាំ២០១៨នេះ។ ការប្តេជ្ញានេះធ្វើឡើងក្នុងជំនួបពិភាក្សារវាងលោក អ៊ិតសំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាមួយលោកឧត្តមសេនីយ៍ Po. Gen .ADUL . SANGSINGKEO រដ្ឋមន្ត្រីក្រសួងការងារថៃ កាលពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៨ នៅទីស្តី ការក្រសួងការងារថៃ។

យោងតាមសេចក្តីជូនដំណឹងរបស់គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅក្នុងប្រទេសថៃ ដែលមានលោករដ្ឋមន្ត្រី អ៊ិត សំហេង ជាប្រធាន បានឲ្យដឹងថា កិច្ចពិភាក្សាមានបានប្រព្រឹត្តិទៅក្រោមបរិយាកាសយោគយល់ ស្និទ្ធស្នាល និងទទួលបានផលជាវិជ្ជមានជាច្រើន។ ប្រភពបានបន្តថា ភាគីទាំងពីរបានសម្តែងនូវការអបអរសាទរចំពោះកិច្ចសហប្រតិបត្តិការ ក្នុងយុទ្ធនាការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ដែលគិតត្រឹមថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៨ ប្រទេសទាំងពីរបានរួមគ្នាផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាបានចំនួន ១លាន ៧ម៉ឺននាក់ ក្នុងនោះបានសហគ្នាបញ្ជាក់អត្តសញ្ញាណថ្មីជូនពលករកម្ពុជា ដែលមានប័ណ្ណស៊ីជម្ពូ (ប័ណ្ណមិនសញ្ជាតិថា) ដែលចេញដោយភាគីថៃ ដើម្បីយកទៅសុំភាពស្របច្បាប់ពីភាគីថៃ បានចំនួនប្រមាណ៤២ម៉ឺននាក់។ បានសហការគ្នាសម្រួលឯកសារ និងផ្តល់ភាពស្របច្បាប់ដល់ពលករតាមរយៈ MOU បានចំនួនប្រមាណជា៦៥ម៉ឺននាក់។

ភាគីថៃបានប្តេជ្ញានឹងបញ្ចប់ការបញ្ជាក់អត្តសញ្ញាណដល់ពលរដ្ឋកម្ពុជាចំនួនប្រមាណ ១ម៉ឺននាក់ទៀតឲ្យបានចប់មុនថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨នេះ។សេចក្តីប្រកាសព័ត៌មាន បានបញ្ជាក់ថា«ភាគីថៃបានឯកភាពអនុញ្ញាតឲ្យពលករកម្ពុជា ដែលមិនទាន់មានឯកសារ ក្រោយពេលបញ្ចប់យុទ្ធនាការនេះអាចត្រឡប់ទៅប្រទេសកម្ពុជា ដើម្បីស្នើសុំធ្វើឯកសារស្រប ច្បាប់ ហើយវិលត្រឡប់មក ធ្វើការនៅប្រទេសថៃវិញ ជាពលករតាមរយៈMOU »។ ជាងនេះទៀត ភាគីថៃនឹងសហការជាមួយភាគីកម្ពុជា ដោយភាពទន់ភ្លន់ក្នុងករណីរកឃើញថា មានបងប្អូនលករកម្ពុជាដែលមិនទាន់ឯកសារ ឬបាត់ឯកសារ ដោយសហការជូនដំណឹងមកស្ថាន ឯកអគ្គរាជទូតកម្ពុជាប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍ និងទីប្រឹក្សាទទួលបន្ទុកពលករ ដើម្បីរួមគ្នាដោះស្រាយ និងចេញលិខិតបើកផ្លូវដើម្បីឲ្យពលករទាំងនោះបាន វិលត្រឡប់មកកម្ពុជាវិញ។ ប្រភពដដែលក៏បានលើកឡើងភាគីទាំងពីឯកភាពគ្នាបញ្ចប់ យុទ្ធនាការជាស្ថាពរ ក្នុងការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ របស់គណៈកម្មការផ្តល់ភាពស្របច្បាប់ ចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៨ តទៅ។ ជោគជ័យនាយុទ្ធនាការនេះ គឺពិតជាបានផ្តល់ផលប្រយោជន៍ដ៏ធំធេង ចំពោះប្រជាពលរដ្ឋនៃប្រទេសទាំពីរ៕

## យុទ្ធនាការផ្តល់ឯកសារដល់ពលករខ្មែរ នៅថៃ ត្រូវបញ្ចប់ចុងខែនេះ

https://www.postkhmer.com/ គង់ មេត្តា | Publication date 20 June 2018 | 09:24 ICT

**ភ្នំពេញៈ** ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនឹងបញ្ចប់យុទ្ធនាការផ្តល់ភាពស្របច្បាប់ដល់ពលករខ្មែរដែលមិនទាន់មានឯកសារហើយកំពុងធ្វើការនៅប្រទេសថៃនៅសល់ចំនួនប្រមាណ ១ ម៉ឺននាក់ទៀតនៅត្រឹមដំណាច់ខែនេះ ឬពួកគេត្រូវត្រឡប់មកធ្វើឯកសារនៅកម្ពុជាវិញ បន្ទាប់ពីបានផ្តល់ភាពស្របច្បាប់ដល់ពលករ ១ លាន ៧ ម៉ឺននាក់។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយមន្ត្រីការពារសិទ្ធិកម្មករបានថ្លែងថាចំនួនកម្មករខ្មែរដែលគ្មានឯក

សារគឺអាចមានចំនួនច្រើនជាងនេះ ហើយកំពុងប្រឈមនឹងការលំបាកនៅពេលពួកគេទៅបំពេញបែបបទធ្វើឯកសារស្របច្បាប់។ នៅក្នុងសេចក្តីជូនដំណឹងមួយរបស់ក្រសួងការងារដែលចេញផ្សាយកាលពីថ្ងៃទី ១៨ ខែមិថុនា បានបញ្ជាក់ថានឹងបញ្ចប់ការបញ្ជាក់អត្តសញ្ញាណដល់ពលករខ្មែរឲ្យបានចប់មុនថ្ងៃទី ៣០ ខែមិថុនានេះ។

សេចក្តីជូនដំណឹងនោះបានបញ្ជាក់ថាគិតត្រឹមថ្ងៃទី ១៨ ខែមិថុនាប្រទេសទាំង ២ បានរួមគ្នាផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាចំនួន ១ លាន ៧ ម៉ឺននាក់។ សេចក្តីជូនដំណឹងដដែលបានឲ្យដឹងថា៖ «ភាគីថៃឯកភាពអនុញ្ញាតឱ្យពលករកម្ពុជាដែលមិនទាន់មានឯកសារក្រោយបញ្ចប់យុទ្ធនាការនេះ អាចត្រឡប់ទៅប្រទេសកម្ពុជា ដើម្បីស្នើសុំធ្វើឯកសារស្របច្បាប់ ហើយវិលត្រឡប់មកធ្វើការនៅប្រទេសថៃវិញ»។ សេចក្តីជូនដំណឹងរបស់ក្រសួងការងារក៏បានបញ្ជាក់ផងដែរថា ភាគីថៃនឹងសហការជាមួយភាគីកម្ពុជាដោយភាពទន់ភ្លន់ក្នុងករណីរកឃើញថា មានពលករកម្ពុជាដែលមិនទាន់មានឯកសារ ឬបាត់ឯកសារ ដោយសហការជូនដំណឹងមកស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ។ ក្រសួងការងារបានហៅការផ្តល់ឯកសារស្របច្បាប់ដល់កម្មករនេះថាជារឿង «ជោគជ័យ» មួយដែលផ្តល់អត្ថប្រយោជន៍ដល់ប្រជាជននៃប្រទេសទាំង ២។

លោក Dy The Hoya មន្ត្រីអង្គការ Central ដែលជាអង្គការសិទ្ធិការងារបានថ្លែងថាចំនួនពលករកម្ពុជាដែលគ្មានឯកសារនៅក្នុងប្រទេសថៃគឺមានចំនួនខ្ពស់ជាងអ្វីដែលក្រសួងបានប្រកាស ហើយក្រសួងប្រហែលជាមិនអាចផ្តល់ឯកសារស្របច្បាប់ដល់ពលករកម្ពុជាដែលគ្មានឯកសារទាំងអស់ឲ្យបានទាន់ពេលវេលាបានទេ ទោះបីជាបានពន្យារពេលជាច្រើនលើកច្រើនសាហើយក្តី។ លោកថ្លែងថា៖ ដំណើរការផ្តល់ឯកសារស្របច្បាប់ប្រហែលមិនអាចទៅដល់ពលករគ្រប់គ្នាបានទេ។ ចំពោះតួលេខដែលផ្តល់ជូនដោយក្រសួង ខ្ញុំមិនគិតថាពលករដែលគ្មានឯកសារនៅសល់តិចជាង ២ម៉ឺនឬ ៣ម៉ឺននាក់នោះទេ។ យើងបានសង្កេតហើយរកឃើញថា ម្ចាស់អាជីវកម្មខ្នាតតូចតាមផ្ទះ និងនិយោជិតមិនបានដឹងអំពីដំណើរការផ្តល់ឯកសារនោះទេ ជាពិសេសអ្នកធ្វើការជាអ្នកលក់ដូរនៅក្នុងផ្ទះ។

លោក Hoya បានបន្ថែមថា ពលករដែលគ្មានឯកសារ ពួកគេប្រឈមនឹងការលំបាកក្នុងការទទួលបានភាពស្របច្បាប់។ លោកបន្តថា៖ «នៅពេលដែលយើងនិយាយជាមួយពលករចំណាកស្រុកទាំងនោះពួកគេបានប្រាប់យើងថា ឧទាហរណ៍ អំពីតម្លៃគឺអស់ប្រហែលពី ៣ ពាន់ទៅ ៤ ពាន់បាត ប៉ុន្តែពួកគេត្រូវចំណាយអស់ប្រមាណ ១ ម៉ឺនបាត ដោយសារតែឈ្មួញកណ្តាលប្រាប់ពួកគេ។ ដូច្នេះហើយទើបពួកគេបាត់បង់ទំនុកចិត្តក្នុងការធ្វើវា»។ លោក Hoya ថ្លែងថា ទាំងពលករ និងថៅកែ ពួកគេមិនទទួលបានព័ត៌មានអំពីដំណើរការផ្តល់ឯកសារស្របច្បាប់នេះទេ ជាពិសេសម្ចាស់អាជីវកម្មខ្នាតតូច។ លោកបញ្ជាក់ថា៖ «ចំពោះក្រុមហ៊ុនធំៗដែលបានចុះបញ្ជី ពួកគេដឹងហើយបានបញ្ជូនបុគ្គលិករបស់ខ្លួនទៅធ្វើឯកសារនោះ»។ លោកបន្ថែមទៀតថា ដូចអ្វីដែលជាច្បាប់ចុងក្រោយបំផុតរបស់ប្រទេសថៃ គឺថាពួកគេអាចប្រឈមនឹងការផាកពិន័យ គឺទាំងពលករ និងនិយោជករបស់ពួកគេ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ លោកមិនគិតថាវាអាចឈានដល់ដំណាក់កាលនេះទេ ពីព្រោះថាប្រទេសថៃនៅតែត្រូវការពលករចំណាកស្រុក ដើម្បីធ្វើការដដែល»៕ NS

## ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨

## ពិភាក្សាប្រជុំ RBC លើកទី២៦ កម្ពុជា-ថៃ លើវិស័យសន្តិសុខ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៨ ម៉ោង ១៧:១១ ហួត សុងហាក់

សៀមរាប ៖ ក្រុមលេខាធិការគណៈកម្មាធិការព្រំដែនថ្នាក់ភូមិភាគកម្ពុជា-ថៃលើកទី២៦ (ហៅកាត់ថា RBC-26) ដែលភាគីកម្ពុជាបានជួបប្រជុំចំនួន២៥នាក់ ភាគីថៃ២៧នាក់ មកពីស្ថាប័នកងទ័ព ប៉ូលិស អាវុធហត្ថ កងការពារព្រំដែន មន្ត្រីបរិស្ថាន សុខាភិបាល កសិកម្ម អប់រំទេសចរណ៍ ពាណិជ្ជកម្ម ខេត្តបាត់ដំបង ,បន្ទាយមានជ័យ និងខេត្តស្រះកែវ ខេត្តច័ន្ទបូរី ។ ដែលជួបប្រជុំគ្នានៅក្នុងសាលប្រជុំសណ្ឋាគារ អង្គរស៊ិនជូរី នៅក្រុង-ខេត្ត

សៀមរាបនៅសៀល ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨ ក្រោមការដឹកនាំលោកឧត្តមសេនីយ៍ទោ ឯក សំអូន មេបញ្ជាការង នាយសេនាធិការយោធភូមិភាគទី៥ និងជាប្រធានក្រុមលេខាគណៈកម្មាធិការព្រំដែនថ្នាក់ភូមិភាគខាងកម្ពុជាបានបើកកិច្ចប្រជុំជាមួយសហប្រធានលោកឧត្តមសេនីយ៍ត្រី គ្រីតដាក់ណៃ អ៊ិតធិម៉ុនថុន នាយសេនាធិការកងទ័ពភូមិភាគទី១ ភាគីថៃ ។

លោកឧត្តមត្រី សេង ថាប៊ី នាយរងសេនាធិការយោធភូមិភាគទី៥ អនុប្រធានក្រុមលេខាខាងកម្ពុជាបានអានរបាយការណ៍ កិច្ចប្រជុំ RBC លើកទី២៥ នាក្រុងប៉ាតាយ៉ាប្រទេសថៃកន្លងមកបានអនុវត្តន៍រួមគ្នាទទួលបានលទ្ធផលល្អប្រសើរ និងពង្រាងខ្លឹមសារពិភាក្សាសម្រាប់ប្រជុំ RBC លើកទី២៦ កម្ពុជា-ថៃលើកនេះ ដោយបានផ្តោតលើកិច្ចសហប្រតិបត្តិការទ្វេភាគី លើវិស័យសន្តិសុខ ដែលមានទី១- ការបង្ការទប់ស្កាត់ការកើតឡើងវិវាទ ទី២- ទប់ស្កាត់បញ្ហាឧក្រិដ្ឋកម្ម និងភរវកម្មឆ្លងដែន ទី៣- ការពារបង្រ្កាបទប់ស្កាត់គ្រឿងញៀនឆ្លងដែន ទី៤- បង្រ្កាបបទល្មើសតាមព្រំដែន ទី៥- ការឆ្លងកាត់តាមព្រំដែន ទី៦- ទប់ស្កាត់ការជួញដូរមនុស្ស និងក្មេងអនាថា និងទី៧ – ពលករខុសច្បាប់ ។

ក្នុងនោះអង្គប្រជុំបានពិភាក្សាបន្តដោយផ្តោតលើកិច្ចសហការបន្ថែមលើវិស័យសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថានវិទ្យាសាស្រ្ត និងបច្ចេកទេស សុខាភិបាល កសិកម្ម អប់រំ ទេសចរណ៍ អប់រំផ្សព្វផ្សាយ និងក្របខណ្ឌទិសដៅការអនុវត្តរួមគ្នា ក្រោយការចូលជាសហគមន៍អាស៊ាន ដែលហៅកាត់ថា (AC) ។

ចុងក្រោយលោកឧត្តមសេនីយ៍ទោ ឯក សំអូន និងលោកឧត្តមសេនីយ៍ត្រីគ្រីតដាក់ណៃ អ៊ិតធិម៉ុនថុន សហប្រធាននៃកិច្ចប្រជុំរួមក្រុមលេខាទាំងពីរបានពិនិត្យសម្រេច លើពង្រាងខ្លឹមសាររួម ដើម្បីដាក់ជូនឲ្យប្រធានគណៈកម្មាធិការថ្នាក់ភូមិភាគលើកទី២៦ ឯកភាពតាមឧបសម្ព័ន្ធបានធ្វើរួមនេះ ឲ្យទទួលបានលទ្ធផលល្អបន្ថែមទៀត ៕

## ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨

## សមត្ថកិច្ចឆ្មក់ឆែកឆេរទីតាំង ស៊ីឈ្នួលពរពោះ ឲ្យជនបរទេស រកឃើញស្រ្តីខ្មែរ មានផ្ទៃពោះ ៣៧នាក់ មេការនិងជនជាតិចិន ម្នាក់

http://peoplenews.asia/ ដោយ ៖ សុខ សាន្ត ថ្ងៃទី22 ខែ06 ឆ្នាំ2018 ម៉ោង 1:01 PM

ភ្នំពេញ៖កាលពី ម៉ោង៧និង៣០នាទី ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ស្ថិតនៅចំណុចផ្ទះលេខ២អា និង៩អា ក្រុម៤ ភូមិ៤ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កម្លាំងនគរបាលខណ្ឌឬស្សីកែវ សហការជាមួយ កម្លាំងការិយាល័យជួញដូរផ្លូវភេទ និងការពារអនិតិជន រាជអាវុធហត្ថខណ្ឌឬស្សីកែវ បាន ឆ្មក់ ចុះបង្រ្កាប ទីតាំង ចាក់ បញ្ចូលមេជីវិត ឲ្យស្រ្តីខ្មែរ ឲ្យពពោះជំនួសជាង៣០នាក់ រកឃើញ មេកា២នាក់ និងជនជាតិចិន ម្នាក់ ។

ប្រតិបត្តិការនេះ មានការសម្របសម្រួលពីព្រះរាជអាជ្ញារង កួច គឹមឡុង។ ជាលទ្ធផល ការបង្រ្កាបនេះ សមត្ថកិច្ចឃាត់ខ្លួនបានជនសង្ស័យម្នាក់ ឈ្មោះ LIU QIANG ភេទប្រុស អាយុ៤៩ឆ្នាំ (ជនជាតិចិន) និងស្រ្តីពពោះចំនួន៣៧នាក់ មេការ២នាក់ និងដកហូតរថយន្ត២គ្រឿង រួមមាន រថយន្តឡិចស៊ីស 470 រថយន្តសុាំយ៉ុង និងម៉ូតូ១គ្រឿងផងដែរ។ តាមសេចក្តីរាយការណ៍ដដែលបានបន្តថា ទីតាំង ខាងលើនោះ កន្លងមកគេឃើញ មានស្រ្តីខ្មែរចេញចូល ជារើយ ៗប៉ុន្តែ មិនសូវមាន ពីណាគេចាប់អារម្មណ៍ ថាជាទីតាំង អ្វីនោះទេ ក្រោយៗមកក៏ឃើញស្រ្តីមួយចំនួនមានផ្ទៃពោះ ជាហូរហែរ រហូតដល់ថ្ងៃ បង្រ្កាបទើប ដឹងថាជាទីតាំង ធ៏ឈ្នួលពរពោះ ។ នៅចំពោះមុខជនសង្ស័យ និងស្រ្តីពពោះ មេកា និងរថយន្ត ត្រូវបានសមត្ថកិច្ចប្រគល់ទៅកាន់ការិយាល័យជួញដូរផ្លូវភេទដើម្បីចាត់ការបន្តតាមនីតិវិធីច្បាប់៕

## រដ្ឋមន្ត្រីក្រសួងការងារថៃរឹតបន្តឹង ចាប់ដៃសហការជាមួយអគ្គនគបាលជាតិដើម្បីបង្ក្រាប ជនបរទេសខុសច្បាប់

https://www.facebook.com/បណ្តាញទំនាក់ទំនងសង្គមកម្មករឆ្លងដែន 22-06-2018

ថ្ងៃទី២១-២២ ខែមិថុនា ឆ្នាំ២០១៨ រដ្ឋមន្ត្រីក្រសួងការងារថៃ បានបើកកិច្ចប្រជុំប្រគល់គោលនយោបាយយុទ្ធសាស្ត្រ ក្រោមគម្រោងការត្រួតពិនិត្យ បង្ក្រាប ចាប់ខ្លួន និង ផ្តន្ទាទោសជនបរទេសដែលលួចស្នាក់អាស្រ័យនិងធ្វើការនៅក្នុងប្រទេសថៃដោយមិនមានលិខិតអនុញ្ញាតធ្វើការ។ ដោយអគ្គបញ្ជាការនគបាលជាតិលើផ្ទៃប្រទេសរបស់ថៃបានបញ្ជាអោយមន្ត្រីពាក់ព័ន្ធគ្រប់ខេត្តក្រុង អង្គភាពប៉ូលីសស៊ើបអង្កេតកណ្តាល ព្រមទាំងវរៈសេនាការពារព្រំដែន ចាត់ក្រុមការងារបំពេញបេសកកម្ម១១៣ក្រុម ក្នុង១ក្រុមមាន៥នាក់ សរុបទាំងអស់៥៦៥នាក់ ដើម្បីស៊ើបអង្កេត ចាប់ខ្លួន ផ្តន្ទាទោសអ្នកដែលប្រព្រឹត្យបទល្មើសច្បាប់ព្រះរាជក្រឹត្យស្តីពីការគ្រប់គ្រងការធ្វើការរបស់ពលករបរទេស នឹងចាប់ផ្តើមអនុវត្តថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៨ ទូទាំងប្រទេសថៃ។ (ពលករកម្ពុជា)

## ប្តីប្រពន្ធចិន ចង់បានកូនទីពីរ នាំគ្នាសម្រុកទៅរកការបង្កកំណើតតាមបែបវិទ្យាសាស្ត្រ នៅក្រៅប្រទេស

https://www.postkhmer.com/ Publication date 21 June 2018 | 15:05 ICT

**ក្រុងសៀងហៃ:** ការបន្ធូរបន្ថយគោលនយោបាយកូនមួយរបស់ប្រទេសចិន បានធ្វើឲ្យលោក ចាង យ៉ីនចេ (Zhang Yinzhe) និង ភរិយារបស់គាត់គឺអ្នកស្រី ស៊ូ ម៉េងសា (Xu Mengsha) បានសម្រេចចិត្តថា ពួកគាត់ចង់ប្រើប្រាស់បច្ចេកវិទ្យាបង្កកំណើតតាមរយៈការយកមេជីវិតឈ្មោល ដើម្បីធ្វើការបង្កកំណើតក្នុងកែវ ឬ ហៅថា Vitro Fertilization (IVF)។ យោងតាមការសិក្សារបស់ចិនបានបង្ហាញថា ប្រហែល ១២ ភាគរយនៃស្ត្រីស្ថិតក្នុងវ័យបន្តពូជ គឺពួកគេមិនអាចមានកូនតាមរយៈធម្មជាតិបានទេ ប៉ុន្តែប្រទេសចិនមានគ្លីនិកប្រើបច្ចេកវិទ្យា IVF ដែលមានអាជ្ញាប័ណ្ណមានតែ ៤០០ កន្លែង ប៉ុណ្ណោះ។ ដូច្នះហើយពួកគេអាចត្រូវរង់ចាំរហូតដល់មួយឆ្នាំក៏មាន។ ប៉ុន្តែប្រទេសចិននៅតែហាមប្រាម ឬរឹតបន្តឹងជម្រើសនៃការបង្កកំណើតមួយចំនួន ដូចជាការបរិច្ចាគមេជីវិតការស៊ីឈ្នួលពពោះជំនួស ការជ្រើសរើសភេទទារក និងការបង្កកមេជីវិត សម្រាប់ប្រើប្រាស់ពេលក្រោយជាដើម។

ប៉ុន្តែកំណើនតម្រូវការនៅតាមគ្លីនិក ដែលផ្តល់ការបង្កកំណើតបែបនេះបានកើនឡើងគួរឲ្យកត់សម្គាល់ចាប់តាំងពីគោលនយោបាយកូនមួយ របស់ចិន ត្រូវបានបន្ធូរបន្ថយកាលពី ២ ឆ្នាំមុន ប៉ុន្តែយ៉ាងណាក៏ដោយ ប្តីប្រពន្ធចិនជាច្រើនត្រូវរង់ចាំរាប់ខែ ដោយសារតែចំនួនគ្លីនិកក្នុងស្រុក មិនអាចឆ្លើយតបនឹងតម្រូវការ។ ដូច្នេះហើយប្តីប្រពន្ធមួយគូ ដែលមកពីទីក្រុងប៉េកាំងរូបនេះ បានធ្វើដំណើរមកកាន់ប្រទេសថៃ ដែលវាជាផ្នែកមួយនៃការធ្វើដំណើររបស់ជនជាតិចិនទៅក្រៅប្រទេសទៅកាន់តំបន់អាស៊ីអាគ្នេយ៍ សហរដ្ឋអាមេរិក និងកន្លែងដទៃទៀត ដែលវិធីសាស្ត្របង្កកំណើតតាមបច្ចេកវិទ្យាមានការរីកចម្រើនច្រើន។

លោក ចាង អាយុ ៣១ ឆ្នាំដែលជាអ្នកបើកយន្តហោះ បានថ្លែងថា៖ «នៅក្នុងប្រទេសចិនពាក្យចាស់ធ្លាប់និយាយថា គ្រួសារមួយពេញលេញគឺត្រូវមានកូនប្រុស និងកូនស្រី»។ លោក ចាង បាននិយាយបន្ទាប់ពីគាត់បានពិគ្រោះយោបល់នៅឯនៅឯមន្ទីរពេទ្យ Piyavate Hospital ក្នុងទីក្រុងបាងកក ដែលនៅលើជញ្ជាំងមានបិទផ្ទាំងរូបភាព និងសរសេអក្សរចិនស្តីអំពីបច្ចេកវិទ្យា IVF នេះខណៈដែលប្តីប្រពន្ធជនជាតិចិនដទៃទៀតកំពុងអង្គុយរង់ចាំវេនរបស់ពួកគេ។

តួលេខពិតប្រាកដ ស្តីអំពីចំណែកទីផ្សាររបស់ចិនលើវិស័យទេសចរណ៍ស្វែងរកការបង្កកំណើតតាមរយៈបច្ចេកវិទ្យានេះគឺមិនច្បាស់ទេ ប៉ុន្តែការចំណាយត្រូវបានវិទ្យាស្ថានស្រាវជ្រាវឧស្សាហកម្ម Qianzhan ប៉ាន់ស្មានថាបានកើនឡើងប្រមាណ ២២ ភាគរយជារៀងរាល់ឆ្នាំ ដោយក្នុងឆ្នាំ ២០១៧ មានតម្លៃរហូតដល់ ១,៤៣ពាន់លានដុល្លារ ហើយកំណើនត្រូវបានគេរំពឹងថានឹងកើនឡើងជាបន្តបន្ទាប់ទៀត។ តួលេខរបស់ចិនបានប៉ាន់ប្រមាណថាស្ត្រីចំនួន ៩០ លាននាក់មានសិទ្ធិទទួលបានការមានកូនម្នាក់ទៀត នៅពេលដែលគោលនយោបាយ គ្រួសារមួយ

កូនមួយ ត្រូវបានបន្ធូរបន្ថយ ហើយកាលពីឆ្នាំមុន ចំនួនសម្រាលកូនទី ពីរ មានកើនឡើងច្រើនជាងកូនទីមួយទៅទៀត។

គ្លីនិកនៅក្រៅប្រទេសកំពុងបន្ថែមបុគ្គលិក ដែលចេះនិយាយភាសាចិនហើយវេបសាយជាភាសាចិនក៏កំពុងកើនឡើងផងដែរ ដើម្បីឈោងចាប់ចំណែកទីផ្សារជនជាតិចិនដែលពួកគេកំពុងតែស្វែងរកឲ្យមានកូនទីពីរ ឬទីបីបន្ថែម។ ប៉ុន្តែទំរាំតែ គោលនយោបាយកូនមួយរបស់ចិនត្រូវបានបន្ធូរបន្ថយ គូស្វាមីភរិយាជនជាតិចិនមួយចំនួនពេលចង់បានកូនបន្ថែម ពួកគេកំពុងឈានដល់វ័យមួយ ដែលពិបាកមានផ្ទៃពោះដូច្នេះហើយពួកគេត្រូវការជំនួយវិទ្យាសាស្ត្រ។ បច្ចេកវិទ្យា IVF ពាក់ព័ន្ធទៅនឹងការដាក់បញ្ចូលមេជីវិតឈ្មោល និងញី ទៅក្នុងមន្ទីរពិសោធន៍ និងចាប់យកអំប្រីយ៉ុងណា ដែលអាចរស់បាននឹងយកទៅចាក់បញ្ចូលទៅក្នុងស្បូន។ គោលនយោបាយគ្រួសារមួយកូនមួយបានធ្វើឲ្យអត្រាកំណើតធ្លាក់ចុះ ហើយប្រទេសចិនបានបន្ធូរបន្ថយគោលនយោបាយនេះ ដើម្បីធានាថាមានកម្លាំងពលកម្មគ្រប់គ្រាន់នាពេលពេលអនាគត ដើម្បីជំនួសប្រជាជនវ័យចំណាស់របស់ខ្លួនដែលកំពុងកើនឡើងយ៉ាងរហ័សនោះ។

យោងតាមមន្ត្រីសុខាភិបាលបានប៉ាន់ប្រមាណថា ជនជាតិចិនស្វែងរកការប្រើប្រាស់វិធីបង្កកំណើតតាមរយៈបច្ចេកវិទ្យា IVF នៅប្រទេសចិន មានប្រមាណ ៥០ ម៉ឺននាក់ ប៉ុណ្ណោះនៅក្នុងឆ្នាំ២០១៦ ខណៈដែលគ្រូពេទ្យនិយាយថា វាមានចំនួនតិចជាងតម្រូវការឆ្ងាយណាស់។

លោក រី ជិនចៀន (Ri-Cheng Chian) ប្រធានផ្នែកឱសថបន្តពូជនៅមន្ទីរពេទ្យ 10th People's Hospital ក្នុងទីក្រុងសៀងហៃបានឲ្យដឹងថា៖ «មានតម្រូវការច្រើននៅក្នុងប្រទេសចិន ប៉ុន្តែយើងមិនអាចធ្វើអស់ទេនៅទីនេះ»។ ដូច្នេះហើយជនជាតិចិនកំពុងកក់សំបុត្រទៅកាន់ប្រទេស ថៃ ម៉ាឡេស៊ី កម្ពុជា និង សូម្បីតែប្រទេសរុស្ស៊ី។

បច្ចេកវិទ្យាបង្កកំណើតដោយ IVF មានតម្លៃប្រហែល ៣ ម៉ឺនយន់ (៤៧០០ដុល្លារ) នៅក្នុងប្រទេសចិន ប៉ុន្តែអាចមានតម្លៃច្រើនជាងនេះច្រើនដងនៅបរទេស ប៉ុន្តែជនជាតិចិនជាច្រើនមានអារម្មណ៍ថា ពួកគេអាចទទួលបានការថែទាំដែលមានគុណភាពខ្ពស់។

ក្នុងនាមជាអ្នកបើកយន្តហោះលោកបាន ចាង បាននិយាយថា ផ្នែកខ្លះនៃបច្ចេកវិទ្យា IVF គឺដើម្បីពិនិត្យមើលភាពមិនប្រក្រតីនៃហ្សែន ជាអ្វីដែលត្រូវបានរឹតត្បឹតនៅឯស្រុករបស់គាត់។ លោកបញ្ជាក់ថា៖ «ការចំណាយមានកូនដោយ IVF វាជាចំនួនទឹកប្រាក់ដ៏ច្រើនសម្រាប់គ្រួសារជនជាតិចិន ប៉ុន្តែបើប្រៀបធៀបទៅនឹងសុខភាពរបស់មនុស្សជំនាន់ក្រោយ គឺខ្ញុំគួរតែចំណាយ»៕ AFP/NS

## ទូតខ្មែរនៅសឹង្ហបូរី ម៉ាឡេស៊ី និងចិន បន្តជួយអន្តរាគមន៍ពលរដ្ឋខ្មែរបាន២១នាក់ទៀត ឱ្យត្រឡប់មកស្រុកកំណើតវិញ

http://www.freshnewsasia.com/ 2018-06-22

**(ភ្នំពេញ)៖** ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសសឹង្ហបូរី, ស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសម៉ាឡេស៊ី និងស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងសៀងហៃ ប្រទេសចិន នាថ្មីៗនេះ បានធ្វើអន្តរាគមន៍ ជួយពលរដ្ឋខ្មែរចំនួន២១នាក់ ឱ្យត្រឡប់មកប្រទេសកម្ពុជាវិញ។ នេះបើតាមសេចក្តីប្រកាសរបស់ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨នេះ។ **បើយោងតាមការប្រកាសរបស់ក្រសួងការបរទេសដែលសារព័ត៌មាន Fresh News ទទួលបាននៅថ្ងៃនេះ បានឱ្យដឹងថា៖**

**១៖** ស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសសឹង្ហបូរី បានជួយរៀបចំមាតុភូមិនិវត្តន៍របស់ពលការិនី ខ្មែរចំនួន២នាក់ មកពីខេត្តកំពង់ចាម និងខេត្តកំពង់ឆ្នាំង ដែលបានទៅបម្រើការងារជាជំនួយការ មេផ្ទះនៅប្រទេសសិង្ហបុរី កាលពីខែមេសា និងខែឧសភា ឆ្នាំ២០១៨ តែមិនអាចទ្រាំទ្រការងារលំបាកនៅទីនោះបាន និងដោយសារមានធុរៈក្នុងគ្រួសារ។ ស្ថានទូត បានផ្តល់កន្លែងស្នាក់នៅ អាហារបរិភោគ ព្រមទាំងជួយទាមទារលិខិតឆ្លងដែននិងសំបុត្រយន្តហោះពីភ្នាក់ងារនាំពលករ ហើយពលការិនីទាំងពីរនាក់បានមកដល់កម្ពុជាវិញ ជាបន្តបន្ទាប់ នៅថ្ងៃទី០៨ និងថ្ងៃទី២១ ខែ មិថុនា ឆ្នាំ២០១៨ ។

**២៖** ស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសម៉ាឡេស៊ី បានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់ម៉ាឡេស៊ី ដោះស្រាយបញ្ហា និងរៀបចំមាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរចំនួន១២នាក់ មកពីខេត្តកណ្ដាល ខេត្តកំពត, ខេត្តកំពង់ធំ, ខេត្តកំពង់ចាម, ខេត្តត្បូងឃ្មុំ, ខេត្តពោធិ៍សាត់, ខេត្តព្រះវិហារ និងរាជធានីភ្នំពេញ ក្នុងនោះពលករមានចំនួន២នាក់ និងពលការិនីពនាក់ ដែលបានទៅធ្វើការ ដោយខុសច្បាប់ នៅប្រទេសម៉ាឡេស៊ី និង៣នាក់ជាកុមារ (កូនរបស់ពល-ការិនីម្នាក់)។ ពលរដ្ឋខ្មែរទាំង១២នាក់នោះ បានមកដល់កម្ពុជាវិញ ជាបន្តបន្ទាប់ចន្លោះពីថ្ងៃទី០៣ ដល់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៨។

**៣៖** ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងសៀងហៃ ប្រទេសចិន សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់ចិន បានអន្តរាគមជួយសង្គ្រោះនិងរៀបចំមាតុភូមិនិវត្តន៍របស់ស្ត្រីខ្មែរចំនួន៧នាក់ មកពីខេត្តកណ្ដាល កំពង់ចាម តាកែវ បាត់ដំបង ពោធិ៍សាត់ ព្រៃវែង និងស្វាយរៀង ដែលត្រូវបានមេខ្យល់នាំធ្វើដំណើរពីកម្ពុជាទៅរៀបការ និងស្នាក់នៅដោយខុសច្បាប់នៅក្នុងប្រទេសចិន កាលពីខែធ្នូ ឆ្នាំ២០១៣ និងដើមឆ្នាំ២០១៨។

ក្រសួងការបរទេស ក៏បានបញ្ជាក់ទៀតថា ចំពោះករណីទី៣នេះ ស្ថានអគ្គកុងស៊ុល បានផ្ដល់កន្លែងស្នាក់នៅ និងអាហារបរិភោគ ហើយជូនស្ត្រីខ្មែរទាំង៧នាក់នោះ ហើយពួកគេនឹងមកដល់កម្ពុជាវិញ នៅយប់ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨នេះ៕

## ពលករខ្មែរ ធ្វើការក្រៅស្រុក នឹងងាយស្រួល ផ្ញើរប្រាក់ មកក្រុមគ្រួសារ ក្រោយធនាគារស្ថាបនា ចុះ MOU ជាមួយ Western Union

https://www.dap-news.com/kh/ ព្រហស្បតិ៍, ២១ មិថុនា ២០១៨ 18:07 ដោយ: ម៉ៅ ដារាត់ ID:119

**ភ្នំពេញ៖** ធនាគារ ស្ថាបនា និង Western Union នៅរសៀលថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨នេះ បានធ្វើការប្រកាស លើកិច្ចព្រមព្រៀង ផ្ដល់សេវាកម្មផ្ទេរប្រាក់ ទូទាំងពិភពលោក របស់ Western Union មកកាន់បណ្ដាសាខារបស់ខ្លួន (ធនាគារ ស្ថាបនា) ទូទាំងប្រទេស តាមរយៈសេវាកម្មនេះ ដោយអតិថិជនអាចធ្វើការផ្ញើ និងទទួលប្រាក់ យ៉ាងឆាប់រហ័ស ទូទាំងប្រទេសកម្ពុជា ជាពិសេស នឹងផ្ដល់ភាពងាយស្រួលជាងមុន ដល់ពលករ ពលការិនីខ្មែរ ដែលចេញទៅរកប្រាក់ តាមរយៈចំណាក់ស្រុក ទៅតាមបណ្ដាលប្រទេសនានា អាចផ្ញើប្រាក់ មកកាន់ក្រុមគ្រួសារ កាន់តែរហ័យ និងសុវត្ថិភាពជាងមុន ។

លោក KATO Norihiko ប្រធាននាយកប្រតិបត្តិធនាគារ ស្ថាបនា បានមានប្រសាសន៍ថា «យើងមានសេចក្ដីរីករាយ ដែលបានសហការជាមួយ Western Union ដែលអនុញ្ញាតឱ្យ អតិថិជនរបស់យើង អាចតភ្ជាប់ទំនាក់ទំនងគ្នា ទៅវិញទៅមកស្ទើរគ្រប់ប្រទេស នៅលើពិភពលោក រួមទាំងក្នុងស្រុកផងដែរ»។ លោកបន្ថែមទៀតផងដែរថា "ការផ្ដល់ជូនអតិថិជន នូវភាពងាយស្រួល និងភាពជឿជាក់ របស់ Westurn Union មានសារៈសំខាន់ចំពោះយើង ហើយយើងមានមោទនភាព ក្នុង ការពង្រីកវិសាលភាព សេវាកម្មរបស់យើង" ។

គួររំលឹកថា បច្ចុប្បន្នមានប្រជាជនកម្ពុជា ជាងមួយលាននាក់ កំពុងបម្រើការងារនៅបរទេស ដែលភាគច្រើននៅក្នុងប្រទេសថៃ។ ពលករកម្ពុជាក៏មាន នៅក្នុងប្រទេសផ្សេងៗទៀតផងដែរ មានដូចជា ប្រទេសកូរ៉េខាងត្បូង ប្រទេសម៉ាឡេស៊ី និងប្រទេសជប៉ុន។ បើយោងតាមសៀវភៅកំណត់ត្រា នៃការធ្វើចំណាក់ស្រុក និងការផ្ទេរប្រាក់របស់ធនាគារពិភពលោក (World Bank)ឆ្នាំ ២០១៦ ប្រទេសកម្ពុជា គឺជាប្រទេសទទួលប្រាក់ ពីបរទេសធំជាងគេ លំដាប់ទី៨ នៅតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ដោយមានចំនួន ០,៩ ពាន់លានដុល្លាអាមេរិក។

លោក Arish Shrestha នាយកតំបន់ Western Union ប្រចាំតំបន់ឥណ្ឌូចិនបានមាន ប្រសានសន៍ថា "ប្រាក់ដែលបានផ្ញើ ដោយពលរដ្ឋកម្ពុជា រស់នៅ ក្រៅប្រទេស ដើរតួនាទីយ៉ាងសំខាន់ ក្នុងការជម្រុញកំណើនសេដ្ឋកិច្ច នៅក្នុងក្រុមគ្រួសារ ក៏ដូចជាសេដ្ឋកិច្ចជាតិទាំងមូល។ ខណៈ ដែលមានប្រជាជនកម្ពុជា កាន់តែច្រើនស្វែងរកការងារធ្វើ នៅឯក្រៅប្រទេស ដើម្បីរកប្រាក់មកចិញ្ចឹមក្រុមគ្រួសារ របស់ពួកគេនៅឯស្រុកកំណើតវិញ។ ការប្ដេជ្ញាចិត្តរបស់យើង គឺធ្វើយ៉ាងណា បន្តពង្រីកវិសាលភាព នៃដំណើរការសេវាផ្ញើប្រាក់ពីក្រៅប្រទេស ក៏ដូចជានៅក្នុងប្រទេស ឱ្យកាន់តែមានភាពងាយស្រួល" ។

លោក Shrestha បានបន្ថែមថា "យើងសូមស្វាគមន៍ធនាគារ ស្ថាបនា មកកាន់គ្រួសារ Western Union និងជឿជាក់ថា វិសាលភាពនៃបណ្តាញសាខា របស់ពួកគេនឹង ផ្តល់ភាពងាយស្រួល សម្រាប់សេវាកម្មផ្ទេរប្រាក់ ទាំងក្នុងស្រុក និងក្រៅស្រុក" ។ ភាពជាដៃគូជាមួយ នឹងធនាគារ ស្ថាបនានេះ មិនត្រឹមតែអាចបំពេញតម្រូវការ ហិរញ្ញវត្ថុរបស់អតិថិជន បានប៉ុណ្ណោះទេ ថែមទាំងជួយក្នុងការអភិវឌ្ឍន៍ សេដ្ឋកិច្ច និងសង្គម របស់ប្រទេសផងដែរ៕

## សេចក្តីប្រកាសព័ត៌មានរបស់ស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ

https://www.facebook.com/Royal-Embassy-of-Cambodia-in-Bangkok ថ្ងៃទី22 ខែមិថុនា 2018

ព្រះរាជាណាចក្រកម្ពុជា

ស្ថានទូតព្រះរាជាណាចក្រកម្ពុជា
ប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍
លេខ: ៧៥០ /១៨/សកប៤

ជាតិ សាសនា ព្រះមហាក្សត្រ

### សេចក្តីជូនដំណឹង

ស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍ សូមជម្រាបជូនដល់សាធារណជន ជាពិសេសបងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅក្នុងប្រទេសថៃ មេត្តាជ្រាបថា មជ្ឈមណ្ឌលច្រកចេញចូលតែមួយ (OSS)របស់ភាគីថៃ នឹងត្រូវបិទបញ្ចប់នៅថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៨ នាពេលខាងមុខនេះ ដោយមិនមានការពន្យារពេលបន្តទៀតឡើយ។ ដោយឡែក ការិយាល័យបញ្ជាក់អត្តសញ្ញាណជូនពលករកម្ពុជា នឹងបិទបញ្ចប់នៅថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៨ ដើម្បីទុកពេលជូនបងប្អូនពលករទៅបន្តនីតិវិធីស្នើសុំទិដ្ឋាការស្នាក់នៅ និងប័ណ្ណអនុញ្ញាតការងារ នៅមជ្ឈមណ្ឌលច្រកចេញចូលតែមួយរបស់ភាគីថៃ ឱ្យបានរួចរាល់ត្រឹមថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៨។ ដូច្នេះសូមបងប្អូនពលករកម្ពុជា ដែលមិនទាន់បានបញ្ជាក់អត្តសញ្ញាណ បន្តសុពលភាពប័ណ្ណមិនមែនសញ្ជាតិថៃ (ប័ណ្ណស៊ីជំពូ) ស្នើសុំទិដ្ឋាការស្នាក់នៅ និងប័ណ្ណអនុញ្ញាតការងារ សូមប្រញាប់រួសរាន់ទៅដំណើរការឱ្យបានរួចរាល់ ដើម្បីអាចស្នាក់នៅ និងធ្វើការដោយស្របច្បាប់នៅក្នុងប្រទេសថៃបាន។

ស្ថានទូតសូមបញ្ជាក់ផងដែរថា **ចាប់ពីថ្ងៃទី ១ ខែកក្កដា ឆ្នាំ២០១៨** អាជ្ញាធរថៃនឹងអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងការធ្វើការរបស់ពលករបរទេស ដែលមិនអនុញ្ញាតឱ្យមានពលករបរទេសណាមកធ្វើការក្នុងប្រទេសថៃ ដោយមិនមានឯកសារស្របច្បាប់ (លិខិតឆ្លងដែន/លិខិតធ្វើដំណើរ ទិដ្ឋាការស្នាក់នៅ និងប័ណ្ណអនុញ្ញាតការងារ)នោះទេ។ ដូច្នេះ ពលករកម្ពុជាដែលធ្វើការនៅក្នុងប្រទេសថៃដែលមិនមានឯកសារស្របច្បាប់ សូមទំនាក់ទំនងមកស្ថានទូត ដើម្បីស្នើសុំ **លិខិតធ្វើដំណើរបណ្តោះអាសន្នប្រភេទថ្មី** (Laissez-Passer) ធ្វើដំណើរត្រឡប់ទៅប្រទេសកម្ពុជាវិញ រៀបចំឯកសារស្របច្បាប់ និងត្រឡប់ចូលមកធ្វើការក្នុងប្រទេសថៃ តាមរយៈ MOU។

ក្នុងករណីបងប្អូនពលករកម្ពុជា មានចម្ងល់ពាក់ព័ន្ធនឹងបញ្ហានេះ សូមទំនាក់ទំនងមកទូរស័ព្ទមន្ត្រីស្ថានទូតកម្ពុជានៅក្រុងបាងកក លេខ ០២ ៩៥៧ ៥៨៥១ /០៨៦ ៧៩៩ ៩៩៥៧ / ០៩៤ ០៩២ ៥៩០៥ / ០៦៤ ៧៥៤ ៧៤០១ /០៩៨ ៣៤៦ ៥៦៦៩។

សូមសាធារណជន ជាពិសេសបងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ១០កើត ខែបឋមសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
បាងកក ថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០១៨

អាស័យដ្ឋាន 518/4 Pracha Uthit Road, Soi Ramkamhaeng 39, Wangthonglang, Bangkok 10310, Kingdom of Thailand
ទូរស័ព្ទ: (៦៦-២) ៩៥៧ ៥៨៥១/៩៥៧ ៥៨៥២ ទូរសារ:(៦៦-២) ៩៥៧ ៥៨៥០ អ៊ីម៉ែល: camemb.tha@mfa.gov.kh

# ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨

## ជនជាតិខ្មែររស់នៅប្រទេសថៃ ដែលសមត្ថកិច្ចកម្ពុជាកំណត់មុខសញ្ញាសង្ស័យថាជួញដូរមនុស្ស និងបានសហការផ្តល់ព័ត៌មានតាមប្រមាញ់អស់រយៈពេលជិតមួយឆ្នាំ ត្រូវបានសមត្ថកិច្ចថៃ ឃាត់ខ្លួន, ឯតុលាការខេត្តកំពង់ធំ បាន និងកំពុងវិនិច្ឆ័យទោសក្រុមផ្សំគំនិត៥នាក់ទៀត

https://www.innnews.co.th/crime/news 19-06-2018

ប្រទេសថៃ៖ ពីថ្ងៃទី១៩ ខែមិថុនា សប្តាហ៍នេះ មន្ត្រីការិយាល័យ ប្រឆាំងបទឧក្រិដ្ឋជួញដូរមនុស្ស ពីនាយកដ្ឋានស៊ើបអង្កេតពិសេស (DSI) ថៃ បានធ្វើការយ៉ាងជិតស្និទ្ធ ជាមួយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន របស់អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា បានចល័តតាមចាប់ខ្លួនជនសង្ស័យថាជួញដូរមនុស្ស នៅជិតទីក្រុងបាងកក ។ ជនសង្ស័យ ឈ្មោះ សំ វណ្ណា ជាជនជាតិខ្មែរ រស់នៅក្នុងប្រទេសថៃ បានរកកម្រៃបានយ៉ាងច្រើន ពីការលក់ពលករទេសន្តរប្រវេសន៍ជាជនជាតិខ្មែរ ទៅក្នុងប្រភេទការងារដោយបង្ខំ ក្នុងកប៉ាល់នេសាទថៃ នៅកំពង់ផែសមុទ្រប្រាកាន ជាច្រើនឆ្នាំមកហើយ ។ ការចាប់ខ្លួននេះ គឺបន្ទាប់ពីមានកិច្ចសហការស៊ើបអង្កេតជាមួយគ្នា រវាង DSI ថៃ និងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស កម្ពុជា អស់រយៈពេលជាង ១០ខែមកហើយ ។ ក្នុងនោះក៏មានជំនួយកិច្ចសហការពីអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) សម្ព័ន្ធអង្គការចាប់ដៃផងដែរ ។

ប្រទេសកម្ពុជា៖ ថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០១៨ ក្រុមបណ្តាញពាក់ព័ន្ធនឹងឈ្មោះ សំ វណ្ណា ៥នាក់ទៀត ត្រូវបានតុលាការខេត្តកំពង់ធំ ធ្វើការវិនិច្ឆ័យទោសជាបឋម ដោយចោទប្រកាន់ពីបទល្មើសជួញដូរមនុស្ស ក្រោមច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ជនសង្ស័យទាំង៥នាក់នេះ ត្រូវបានឃាត់ខ្លួន ដោយសមត្ថកិច្ចដឹកនាំដោយឧត្តមសេនីយ៍ឯកជីវ ផល្លី អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន (បច្ចុប្បន្នជាអគ្គលេខាធិការរង គ.ជ.ប.ជ) កាលពីខែកញ្ញា ឆ្នាំ២០១៧ ។ ការស៊ើបអង្កេតបន្តដឹកនាំដោយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស សហការជាមួយអង្គភាព DSI ថៃ និងបានប្រមូលភស្តុតាងបានជុំ អំពីបណ្តាញជួញដូរមនុស្ស រួមទាំងអ្នកជ្រើសរើស និងអ្នកដឹកជញ្ជូន ក្នុងប្រទេសកម្ពុជា និងឈ្មួញកណ្តាលនៅប្រទេសថៃផងដែរ ។

ការចាប់ឃាត់ខ្លួន ឈ្មោះ សំ វណ្ណា នៅក្នុងប្រទេសថៃ និងដំណើរការផ្តន្ទាទោសអ្នករួមគំនិតនៅកម្ពុជា បង្ហាញអំពីប្រសិទ្ធភាពនៃកិច្ចសហការយ៉ាងពិតប្រាកដ ។ បណ្តាញជនជួញដូរមនុស្ស ត្រូវតែបានផ្សព្វផ្សាយឲ្យបានដឹងទូលំទូលាយ ថា អាជ្ញាធរ នឹងតាមប្រម៉ាញ់ជនល្មើស ទោះបីជានៅទីណាក៏ដោយ ឲ្យតែជាប្រទេសដែលមានកិច្ចសហការជាមួយគ្នា ។ សេចក្តីសម្រេចរបស់តុលាការ នឹងត្រូវបានប្រកាស នៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨ ខាងមុខនេះ ។ គ.ជ.ប.ជ

## បញ្ជូនជនសង្ស័យ៥នាក់ ទៅតុលាការ ពាក់ព័ន្ធជួញដូរមនុស្សឆ្លងដែន និងពពោះជំនួស

https://www.dap-news.com/kh/ ថ្ងៃច័ន្ទ, ២៥ មិថុនា ២០១៨ 16:22 ដោយ: នាង សួគ៌ ID:119

**ភ្នំពេញ៖** នៅព្រឹកថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨នេះ ជនសង្ស័យប្រុសស្រី៥នាក់ប្រុសស្រី ត្រូវបានកម្លាំងនគរបាល ការិយាល័យប្រឆាំង ការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បញ្ជូនខ្លួនមកអយ្យការ អមសាលាដំបូង រាជធានីភ្នំពេញ ពាក់ព័ន្ធអំពើលក់ដូរមនុស្ស សម្រាប់នាំឆ្លងដែនដោយខុសច្បាប់ តាមមាត្រា១៦ នៃច្បាប់ស្តីពីប្រឆាំងការជួញដូរមនុស្ស និងអន្តរការីរវាងអ្នកសុំកូន និងស្ត្រីពពោះជំនួស តាមមាត្រា៣៣២ នៃក្រមព្រហ្មទណ្ឌ ដើម្បីចាត់ការតាមនីតិវិធីច្បាប់។

កាលពីម៉ោង៦ល្ងាច ថ្ងៃទី២១ មិថុនា កម្លាំងនគរបាលការិយាល័យ ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន សហការជាមួយកម្លាំងនគរបាលមូលដ្ឋាន បានចុះបង្ក្រាបករណីលក់ដូរមនុស្ស សម្រាប់នាំឆ្លងដែន និងបទធ្វើអន្តរការីនៃអំពើ ពពោះជំនួស ឃាត់ខ្លួននារីរងគ្រោះ ចំនួន៣៣នាក់ និងជនសង្ស័យប្រុសស្រីចំនួន៥នាក់ ក្នុងនោះប្រុសម្នាក់ជាជនជាតិចិន។ ប្រតិបត្តិការនេះធ្វើឡើង ចំណុចផ្ទះវីឡាលេខ២A ផ្លូវ៣៤៨ និងផ្ទះវីឡាលេខ៩A ផ្លូវ៣៤៨ ស្ថិតនៅក្នុងបុរី វិមានភ្នំពេញ តាមបណ្តោយផ្លូវលេខ៥៩៨ ក្នុងសង្កាត់ច្រាំងចំរេះទី១ ខណ្ឌឬស្សីកែវ។

តាមសមត្ថកិច្ច ជនសង្ស័យទាំង៥នាក់ មានបុរសជនជាតិចិនទី១-ឈ្មោះ LiU QIANG ជនជាតិចិន ភេទប្រុស អាយុ៤៩ឆ្នាំ ជាមេការ។ ស្ត្រីសង្ស័យទី២-ឈ្មោះ ស្វាយ ស៊ីណុច ភេទស្រី អាយុ៣៤ឆ្នាំ។ស្ត្រីសង្ស័យទី៣-ឈ្មោះ គឿន ស្រីឡាង ភេទស្រី អាយ២៧ឆ្នាំ។ស្ត្រីសង្ស័យទី៤-ឈ្មោះ លឹម សុភាព ភេទស្រី អាយុ១៩ឆ្នាំ និងស្ត្រីសង្ស័យទី៥-ឈ្មោះ ថៃ ភាព ភេទស្រី អាយុ៤៣ឆ្នាំ (ស្ត្រី៤នាក់នេះសុទ្ធតែជាជនជាតិខ្មែរ) ។ ក្នុងប្រតិបត្តិការនេះ ផ្ទះទី១ ផ្ទះផ្ទះលេខ២A ផ្លូវ៣៤៨ ឃាត់ខ្លួនមនុស្សបានចំនួន២៥នាក់ ប្រុស២នាក់ ដែលបុរសម្នាក់ ឈ្មោះ LIU QIANG ភេទប្រុស អាយុ៤៩ឆ្នាំ (ជនជាតិចិន) និងរថយន្ត១គ្រឿង ម៉ាក់ស្តារិច ពណ៌ស ពាក់ស្លាកលេខ ព្រះសីហនុ ២A -៦៨៨៣ ម៉ូតូហុងដា today ពណ៌ខ្មៅ ១គ្រឿង និងផ្ទះទី២ ផ្ទះលេខ៩A ផ្លូវ៣៤៨ ឃាត់ខ្លួនបាន មនុស្សចំនួន១៨នាក់ រួមទាំងក្មេង២នាក់ និងរថយន្ត១គ្រឿងម៉ាក់Lexus 470 ពណ៌ខ្មៅ ពាក់ស្លាកលេខភ្នំពេញ ២C-៨៨៦៣។ថែមទាំងដកហូតឯកសារមួយចំនួន រួមមាន លិខិតឆ្លងដែនមួយចំនួន និងឯកសារពាក់ពន្ធ័។ ក្រោយពេលចប់ប្រតិបត្តិការ កម្លាំងនគរបាល នៃការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ឃាត់ខ្លួនមនុស្សចំនួន៤៥នាក់ (ក្មេង២នាក់) ប្រុស២នាក់ (ប្រុសជនជាតិចិនម្នាក់) ក្នុងនោះស្ត្រីដែរមានផ្ទៃពោះ មានចំនួន៣៣នាក់។ ចំណែកមនុស្សផ្សេងទៀត មិនពាក់ព័ន្ធ ត្រូវនគរបាលឲ្យត្រឡប់ទៅវិញ។ សម្រាប់ស្ត្រីពពោះជំនួសចំនួន៣៣នាក់ បញ្ជូនទៅមន្ទីរសង្គមកិច្ច រាជធានីភ្នំពេញ។

ប្រភពពីនារីរងគ្រោះឲ្យដឹងថា ខ្លួនរាល់ថ្ងៃធ្វើការនៅរោចក្រ បន្ទាប់មកក៏មានមិត្តភក្តិ បបួលដោយនិយាយថាបានលុយច្រើន រហូតដល់១ម៉ឺនដុល្លារ ក៏យល់ព្រម ពេលនោះ មិត្តភ័ក្តក៏បានឲ្យម៉ូតូឌុប ឌុបយកទៅបុរីវិមានភ្នំពេញ តែម្តង។ នារីរងគ្រោះឲ្យដឹងទៀតថា ពេលរូបនាង បានសម្រេចចិត្តធ្វើការងារ ស៊ីឈ្នួលពពោះនេះ ពេលនោះគេក៏បាននាំ ទៅមន្ទីពេទ្យ ដើម្បីបាញ់មេជីវិត ចូលដោយបានឈ្នួលក្នុងតម្លៃ ពពោះកូន១ បានចំនួន១ម៉ឺនដុល្លារ គិតចាប់ពីខែដំបូង ឲ្យចំនួន៥០០ដុល្លារ ខែបន្ទាប់ៗមកទៀត៣០០ដុល្លារ រហូតដល់កើត ទើបទទួលបានចំនួន ៦០០០ដុល្លារបន្ថែមទៀត។

ជាការកត់សំគាល់ លក្ខណៈពិសេស នៃការពពោះជំនួស ក្នុងករណីនេះ ពេលជិតដល់សម្រាល គឺក្រុមហ៊ុនបញ្ជូនស្ត្រីពពោះ ទៅប្រទេសចិន ហើយសម្រាលកូនរួច ទើបបញ្ជូនមកស្រុកខ្មែរវិញ ហើយប្រគល់លុយបង្គ្រប់១ម៉ឺនដុល្លារ៕

## នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស បើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់មន្ត្រី លើយុទ្ធវិធីប្រតិបត្តិការ និងការប្រើប្រាស់អាវុធ

http://cambodiapolice.com/policekh/ 10:19 am 25 មិថុនា 2018 53

ភ្នំពេញ៖ ដោយផ្អែកលើសមត្ថភាពជំនាញនៅមានកម្រិត នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន រួមជាមួយអង្គការជាដៃគូសហការ បានបើកវគ្គបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពដល់មន្ត្រីជំនាញ នៃនាយកដ្ឋាន និងតាមបណ្តាស្នងការដ្ឋាននគរបាលខេត្តមួយចំនួនទៀត នៅព្រឹកថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ ក្រោមអធិបតីភាពឯកឧត្តមឧត្តមសេនីយ៍ឯក ប៉ុល ភិធេយ្យ ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ។

ថ្លែងនៅក្នុងពិធីបើកបើកវគ្គបណ្តុះបណ្តាលនេះ ឯកឧត្តមឧត្តមសេនីយ៍ឯក ប៉ុល ភិធេយ្យ បានមានប្រសាសន៍ថា គោលបំណងសំខាន់ក្នុងវគ្គបណ្តុះបណ្តាលគឺ ពង្រឹងសមត្ថភាពមន្ត្រីជំនាញក្នុងពេលប្រតិបត្តិការបង្ក្រាបបទល្មើស លើបច្ចេកទេសចាប់ជនសង្ស័យ ការប្រើប្រាស់អាវុធក្នុងពេលប្រតិបត្តិការ និងសង្គ្រោះបឋមពេលដែលមានការទទួលរងរបួស ។ ឯកឧត្តមឧត្តមសេនីយ៍ឯក ប៉ុល ភិធេយ្យ បានមានប្រសាសន៍បន្តថា វគ្គបណ្តុះបណ្តាលនេះដែរពិតជាបានផ្តល់នូវចំណេះដឹង បទពិសោធន៍ថ្មីៗតាមរយៈការហ្វឹកហាត់ផ្ទាល់សំដៅរកភាពរីកចម្រើន និងសហប្រតិបត្តិការល្អក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ពិសេសការបង្ក្រាបចាប់ជនសង្ស័យបញ្ជូនទៅតុលាការ និងជួយសង្គ្រោះជនរងគ្រោះបានទាន់ពេលវេលា ។ ឯកឧត្តមឧត្តមសេនីយ៍ឯក ប៉ុល ភិធេយ្យ ក៏បានផ្តាំផ្ញើដល់សិក្ខាកាមទាំងអស់ត្រូវគោរពវិន័យ និងខិតខំយកចិត្តទុកដាក់ក្នុងការហ្វឹកហាត់ឲ្យបានល្អសំដៅពាំនាំយកចំណេះដឹងទាំងនេះទៅអនុវត្ត និងចែករំលែកដល់មិត្តរួមការងារ ក្នុងការបំពេញភារកិច្ចរបស់ខ្លួនឲ្យសម្រេចបានជោគជ័យ ។

ឆ្លៀតក្នុងឱកាសនេះដែរ ឯកឧត្តមឧត្តមសេនីយ៍ឯក ប៉ុល ភិធេយ្យ ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អង្គការមេត្រីអន្តរជាតិ (AIMSWAT) និងសេចក្តីអំណរអន្តរជាតិ (JOY INTERNATIONAL) ជានិច្ចកាល តែងតែមានកិច្ចប្រតិបត្តិការគ្នានាពេលកន្លងមកទាំងការប្រមូលព័ត៌មានស៊ើបអង្កេត ក៏ដូចជាការជួយគាំទ្រលើការងារពង្រឹងសមត្ថភាព និងការផ្តល់សម្ភារៈ ដល់នគរបាលជាតិកម្ពុជាផងដែរ ។

គួរបញ្ជាក់ដែរថា វគ្គបណ្តុះបណ្តាលនេះមានសិក្ខាកាមចូលរួម ២០រូប ស្រី ៦រូប ក្នុងនោះមកពីនាយកដ្ឋាន ១០រូប, ព្រៃវែង ២រូប, ស្ទឹងត្រែង ២រូប, បន្ទាយមានជ័យ ២រូប, រតនគិរី ២រូប និងក្រចេះ ២រូប ដែលមានរយៈពេល ៥ថ្ងៃចាប់ពីថ្ងៃទី២៥-២៩ ខែមិថុនា ឆ្នាំ២០១៨៕

## សំណុំរឿងអន្តរការីពរពោះជំនួស!ឃុំខ្លួនមេការចិនម្នាក់និងនារីមេការខ្មែរ៤នាក់

http://www.rasmeinews.com/ June 25, 2018, 4:25 PM

*ដោយៈសរិទ្ធ/ភ្នំពេញ:* បុរសជនជាតិចិនម្នាក់និងនារីខ្មែរ៤នាក់ដែលជាប់ពាក់ព័ន្ធករណីអន្តរការីពរពោះជំនួសនិងជួញដូរមនុស្សឆ្លងដែនត្រូវចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញសម្រេច នៅរសៀលថ្ងៃទី ២៥មិថុនា ឆ្នាំ២០១៨ឃុំខ្លួនដាក់ពន្ធនាគារ ដើម្បីរង់ចាំការស៊ើបអង្កេតជាបន្តទៀត ។

លោកវរសេនីយ៍ឯកកែវជាប្រធានការិយាល័យនគរបាលប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជនរាជធានីភ្នំពេញ បានឱ្យដឹងថា ជនសង្ស័យទាំង៥នាក់នេះ៖ឈ្មោះ Tiu Qiang ភេទប្រុស ជនជាតិចិនអាយុ៤៩ ឆ្នាំ ជាមេការ ឈ្មោះ ស្វាយ ស៊ីណុច ហៅ សី ភេទស្រី អាយុ៣៤ឆ្នាំ ជាមេការ ឈ្មោះ នឿន ស្រីឡាង ភេទស្រី អាយុ២៧ ឆ្នាំ ជាមេការ ឈ្មោះ លឹម សុភាព ហៅស្តើង ភេទស្រី អាយុ១៩ឆ្នាំ ជាអ្នកបកប្រែ និងឈ្មោះ ថៃ ភាព ភេទស្រី អាយុ ៤៣ឆ្នាំ ជាមេការ ។ បុរសជនជាតិចិននិងនារីខ្មែរទាំង៥នាក់ត្រូវបានជាប់សង្ស័យក្នុងការប្រព្រឹត្តបទល្មើសលក់ដូរមនុស្សសំរាប់នាំឆ្លងដែន តាមមាត្រា១៦នៃច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្សនិងការធ្វើអាជីវកម្មលើផ្លូវភេទ និងបទអន្តរការីរវាងអ្នកសុំកូននិងស្ត្រីពរពោះជំនួស មាត្រា៣៣២នៃក្រមព្រហ្មទណ្ឌ ។

សូមបញ្ជាក់ថា ការឃាត់ខ្លួនជនសង្ស័យទាំង៥នាក់ខាងលើនេះធ្វើឡើងកាលពីវេលាម៉ោង៦ល្ងាច ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ ចំណុចផ្ទះវីឡាលេខ២A ផ្លូវ៣៤៨ និងផ្ទះវិឡាលេខ៩A ផ្លូវ៣៤៨ ស្ថិតនៅក្នុងបុរី វិមានភ្នំពេញ តាមបណ្តោយផ្លូវលេខ៥ ក្នុងសង្កាត់ឬស្សីកែវ ខណ្ឌឬស្សីកែវ។ ប្រតិបត្តិការណ៍នេះ មានការសម្របសម្រួលពីលោក គុជ គីមឡុង ព្រះរាជអាជ្ញារង អមសាលាដំបូងរាជធានីភ្នំពេញសមត្ថកិច្ចនគរបាលបានអោយដឹងផងដែរថា ក្នុងប្រតិបត្តិការនេះ ផ្ទះទី១ ផ្ទះផ្ទះលេខ២A ផ្លូវ៣៤៨ ឃាត់ខ្លួនមនុស្សបានចំនួន២៥នាក់ ប្រុស២នាក់ ដែលបុរស

ម្នាក់ ឈ្មោះ LIU QIANG និងរថយន្ត១គ្រឿងម៉ាក់ស្តារិច ពណ៌ស ពាក់ស្លាកលេខ ព្រះសីហនុ ២A -៦៨៨៣ ម៉ូតូហុងដា today ពណ៌ខ្មៅ ១គ្រឿង និងផ្ទះទី២ ផ្ទះលេខ៩A ផ្លូវ៣៤៨ ឃាត់ខ្លួនបានមនុស្សចំនួន១៨នាក់ រួមទាំងក្មេង២នាក់ និងរថយន្ត១គ្រឿងម៉ាកLexus 470 ពណ៌ខ្មៅ ពាក់ស្លាកលេខភ្នំពេញ ២C-៨៨៦៣និងដកហូតឯកសារមួយចំនួន រួមមាន លិខិតឆ្លងដែនមួយចំនួន និងឯកសារពាក់ពន្ធ័និងឱសថការពារទារកមួយចំនួនធំ ។

បើតាមលោកវរសេនីយ៍ឯកកែវ ធា បានឱ្យដឹងថាតាមចម្លើយនារីពរពោះជំនួសទាំង៣៣នាក់ គឺក្នុងកូន១ ដែលពួកគាត់ពរពោះជំនួសនេះទទួលបានប្រាក់កំរៃចំនួន១ម៉ឺនដុល្លារ គិតចាប់ពីខែដំបូងអោយចំនួន៥០០ដុល្លារខែបន្ទាប់៣០០ដុល្លារ រហូតដល់កើត ទើបទទួលបានចំនួន៦.០០០ដុល្លារបន្ថែមទៀត។ ចំពោះការថែទាំគ័ភ ការប្រសូត្រ គឺជាបន្ទុករបស់ក្រុមហ៊ុន ។ លក្ខណៈពិសេសនៃការពរពោះជំនួសក្នុងករណីនេះគឺពេលជិតដល់ត្រូវឆ្លងទន្លេប្រសូត្រ គឺក្រុមហ៊ុនបញ្ជូនស្ត្រីពរពោះទៅប្រទេសចិនសម្រាលកូនរួចទើបបញ្ជូនមកស្រុកខ្មែរវិញហើយប្រគល់លុយបង្គ្រប់១ម៉ឺនដុល្លារ ៕S/

## ឧទ្ធរណ៍បន្ថយទោស ស្ត្រីម្នាក់រឿងប៉ងនាំនារីទៅយកប្តីចិន

https://www.postkhmer.com/ គឹម សារុំ | Publication date 26 June 2018 | 10:38 ICT

**ភ្នំពេញៈ** សាលាឧទ្ធរណ៍កាលពីម្សិលមិញបានប្រកាសសាលដីកាបន្ថយទោសស្ត្រីជាប់ចោទម្នាក់ពីជាប់គុក ៨ ឆ្នាំមក៧ ឆ្នាំវិញបន្ទាប់ពីជំនុំជម្រះជាថ្មីកាលពីថ្ងៃទី១១ ខែមិថុនាក្រោយពេលតុលាការកំពូលបង្វិលឲ្យជម្រះឡើងវិញករណីនាំនារីខ្មែរ ២ នាក់ក្នុងបំណងទៅការប្ដីនៅប្រទេសចិនប្រព្រឹត្តកាលពីឆ្នាំ ២០១៥ នៅរាជធានីភ្នំពេញ។ នៅចំពោះមុខស្ត្រីជាប់ចោទក្នុងបន្ទប់សវនាការលោកចៅក្រម ប្លង់ សំណាង ប្រធានក្រុមប្រឹក្សាជំនុំជម្រះបានអានសាលដីកាថាៈ «ស្ត្រីជាប់ចោទឈ្មោះ អ៊ុក វ៉ាន់នី ដែលសំណុំរឿងបានបង្វិលពីតុលាការកំពូល ហើយក្រោយពីឧទ្ធរណ៍ជំនុំជម្រះគឺសម្រេចបន្ថយទោស ១ ឆ្នាំដល់ស្ត្រីជាប់ចោទ។ ការបន្ថយទោសនេះដោយមូលហេតុថាស្ត្រីជាប់ចោទប៉ុនប៉ងនាំនារីរងគ្រោះបម្រុងទៅប្រទេសចិន និងរក្សាប្រាក់សំណងនៅដដែល»។

គួររំឭកថាកាលពីជំនុំជម្រះនៅថ្ងៃទី ៥ ខែមេសាឆ្នាំ ២០១៦ ស្ត្រីជាប់ចោទត្រូវសាលាដំបូងរាជធានីភ្នំពេញផ្ដន្ទាទោសដាក់គុក ៩ ឆ្នាំចោទពីបទ «ប៉ុនប៉ងនាំចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែន» និងបង្គាប់ឲ្យសងប្រាក់ទៅនារីរងគ្រោះម្នាក់ ២ លានរៀល។ ឯឈ្មោះ អ៊ុក ចំរើន ជាកូនប្រុសស្ត្រីជាប់ចោទឲ្យរួចខ្លួន។ ប៉ុន្តែស្ត្រីជាប់ចោទបានប្ដឹងឧទ្ធរណ៍ហើយត្រូវសាលាឧទ្ធរណ៍បន្ថយទោសមកត្រឹម ៨ ឆ្នាំវិញ តែរក្សាប្រាក់សំណងទៅនារីរងគ្រោះម្នាក់ ២ លានដដែល។ នេះបើតាមកំណត់ហេតុរបស់តុលាការ។

កំណត់ហេតុដដែលបញ្ជាក់ថាដោយមិនសុខចិត្ត ស្ត្រីជាប់ចោទបានប្ដឹងសារទុក្ខទៅតុលាការកំពូលហើយត្រូវតុលាការកំពូលបង្វិលសំណុំរឿងមកឲ្យសាលាឧទ្ធរណ៍ជំនុំជម្រះឡើងវិញ ព្រោះយល់ថាការសម្រេចរបស់សាលាឧទ្ធរណ៍ផ្ទុយនឹងមាត្រា ១១ នៃច្បាប់ស្ដីពីការជួញដូរមនុស្ស និងមាត្រា ២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ដោយឡែកតាមកំណត់ហេតុនគរបាលបានបង្ហាញថាស្ត្រីឈ្មោះ អ៊ុក វ៉ាន់នី អាយុ ៦០ ឆ្នាំបានលួងលោមនារីខ្មែរ ២ នាក់ឈ្មោះ វ៉ាត លី អាយុ ២០ ឆ្នាំ និងឈ្មោះ សំ ស្រីទូច អាយុ ២២ ឆ្នាំថាទៅធ្វើការនៅចិនបានប្រាក់ខែ ៨០០ ដុល្លារក្នុង ១ ខែ។ បន្ទាប់ពីនារីរងគ្រោះយល់ព្រមស្ត្រីជាប់ចោទក៏ចេញលុយ ១៥០ ដុល្លារក្នុងម្នាក់ដើម្បីរត់ការលើឯកសារ។ កំណត់ហេតុនគរបាលបន្តថាដោយដឹងថាខ្លួនអាចចាញ់បោកស្ត្រីជាប់ចោទ នារីរងគ្រោះឈ្មោះ វ៉ាត លី បានប្ដឹងទៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សក្រសួងមហាផ្ទៃ។ លុះដល់ថ្ងៃ ២៤ មិថុនា ឆ្នាំ ២០១៥ កូនប្រុសរបស់ស្ត្រីជាប់ចោទ ឈ្មោះ អ៊ុក ចំរើន បានជិះម៉ូតូឌុបនារីរងគ្រោះមកផ្ទះស្ត្រីជាប់ចោទក្នុងបំណងជិះរថយន្តក្រុងនាំចេញតាមច្រកព្រំដែនវៀតណាម តែត្រូវនគរបាលឃាត់ខ្លួននាថ្ងៃនោះនៅភូមិត្រពាំងអណ្ដូង សង្កាត់ត្រពាំងក្រសាំង ខណ្ឌពោធិ៍សែនជ័យ។ កាលពីថ្ងៃជំនុំជម្រះនៅសាលាឧទ្ធរណ៍ស្ត្រីជាប់ចោទបានឆ្លើយថា នារីរងគ្រោះ ឈ្មោះ សំ ស្រីទូច គឺត្រូវ

ជាកូនធម៌របស់ខ្លួនហើយពេលនោះនាងខឹងអ្នកស្រីហាមមិនឲ្យនិយាយទូរស័ព្ទច្រើន ក៏ប្តឹងថាអ្នកស្រីនាំនាងទៅចិនតែម្តងទៅ។

ចំណែកនារីម្នាក់ទៀតឈ្មោះ រ៉ាត លី គឺម្តាយនាងសុំឲ្យអ្នកស្រីជួយណែនាំទៅធ្វើការនៅចិន ព្រោះម្តាយគាត់ដឹងថា អ្នកស្រីមានកូនស្រី ២ នាក់នៅចិន៕

## កងទ័ពជើងទឹកថៃបញ្ជូនបុរសពលករខ្មែរដែលធ្វើការនៅលើទូកនេសាទត្រី 01នាក់បន្ទាប់ពីត្រូវខ្សែរភ្លើងនៅលើទូកឆក់បណ្តាលឲ្យសន្លប់បាត់ស្មារតី

https://www.facebook.com/prakpheaktra.official/ PrakPheaktra.Official June 23 at 8:08 PM •

កងទ័ពជើងទឹកថៃបញ្ជូនបុរសពលករខ្មែរដែលធ្វើការនៅលើនេសាទត្រី 01នាក់បន្ទាប់ពីត្រូវខ្សែរភ្លើងនៅលើទូកឆក់បណ្តាលឲ្យសន្លប់បាត់ស្មារតី" ករណីនេះបានកើតកាលពីព្រឹកថ្ងៃសៅរ៍ទី23 ខែមិថុនា ឆ្នាំ2018 ស្ថិតនៅលើសមុទ្រខេត្តត្រាត ក្រោយពេលកើតហេតុបុរសពលករខ្មែររងគ្រោះខាងលើ ត្រូវបានតែកុងទូកបញ្ជូនបន្តតាមរយៈនាវាល្បាតរបស់កងទ័ពជើងទឹកថៃមកកាន់កំពុងផែ ខេត្តត្រាតរួចបញ្ជូនបន្តទៅសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យត្រាត។ យោងតាមប្រភពបឋមពីភ្នាក់ងារសង្គ្រោះខេត្តត្រាតបានប្រាប់ថា បុរសពលករខ្មែររងគ្រោះខាងលើបានស្លាប់បាត់បង់ជីវិតហើយបន្ទាប់បញ្ជូនមកដល់លើគោក។ ប្រភពពី÷ណ័ទ្ធតរាជ 23-06-2018

## ពលករខ្មែរម្នាក់ជិះម៉ូតូទៅតប័ត្រជួបគ្រោះថ្នាក់បណ្តាលឲ្យរងរបួសធ្ងន់

http://www.khmerlabour.com/ 26-06-2018

កាលពីថ្ងៃច័ន្ទទី25 ខែមិថុនា ឆ្នាំ2018 មានករណីបុរសជនជាតិខ្មែរម្នាក់ឈ្មោះ ចិន ធាន អាយុ27ឆ្នាំ ជិះម៉ូតូមួយគ្រឿងម៉ាក Yamaha mio ពណ៌ខ្មៅជម្ពូពាក់ស្លាក់លេខ 523 ក្រុងថេម ធ្វើដំណើរទៅតប័ត្រនៅ(ម៉ុំណើន400) បានកើតឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍ដោយខ្លួនឯងនៅត្រង់ចំណុចណើន400 ស្ថិតក្នុងភូមិម៉ាមួង ឃុំមុនទី ស្រុកបរ៉ៃ ខេត្តត្រាត ប្រទេសថៃ បណ្តាលឲ្យរងរបួសធ្ងន់។ ក្រោយពេលកើតហេតុបុរសរងគ្រោះត្រូវបានភ្នាក់ងារសង្គ្រោះស្រុក បរ៉ៃបញ្ជូនតាមរថយន្តទៅព្យាបាលនៅមន្ទីរពេទ្យខេត្តត្រាតប្រទេសថៃ។

## ភ្ញាក់ផ្អើល! ឥណ្ឌា និងសហរដ្ឋអាមេរិក ជាប់ក្នុងចំណោមប្រទេសគ្រោះថ្នាក់បំផុតសម្រាប់ស្ត្រី

http://news.sabay.com.kh/article/ ថ្ងៃនេះ ម៉ោង 09:10 ថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០១៨

យោងតាមការស្ទង់មតិថ្មីមួយរបស់អ្នកជំនាញបានបង្ហាញឲ្យដឹងថា ឥណ្ឌាជាប្រទេសដែលមានគ្រោះថ្នាក់បំផុតនៅលើពិភពលោកសម្រាប់ស្ត្រី ដោយសារតែ ហានិភ័យខ្ពស់នៃអំពើហិង្សាផ្លូវភេទ និងពលកម្មទាសករ។ មូលនិធិ Thomson Reuters Foundation របស់សារព័ត៌មាន Reuters បានចេញផ្សាយលទ្ធផលរបស់ខ្លួនកាលពីថ្ងៃអង្គារ នៃការស្ទង់មតិរបស់អ្នកជំនាញចំនួន ៥០០នាក់ ដោយបានរកឃើញថា ឥណ្ឌា ជាប្រទេសដែលគ្រោះថ្នាក់បំផុតសម្រាប់អំពើហិង្សាផ្លូវភេទលើស្ត្រី ក៏ដូចជា ការជួញដូរមនុស្សសម្រាប់ការងារតាមផ្ទះ , ការបង្ខំឲ្យធ្វើការ , ការបង្ខំឲ្យរៀបមង្គលការ និងទាសករផ្លូវភេទ ក្នុងចំណោមហេតុផលដទៃផ្សេងទៀតផង។ មិនតែប៉ុណ្ណោះ វាក៏ជាប្រទេសដែលមានគ្រោះថ្នាក់បំផុតនៅលើពិភពលោក ចំពោះទំនៀមទម្លាប់វប្បធម៌ដែលជះឥទ្ធិពលដល់ស្ត្រី ដូចជា ការវាយប្រហារដោយទឹកអាស៊ីដ , ការវះកាត់ប្រដាប់ភេទស្ត្រី , មង្គលការកុមារ និង ការរំលោភបំពានលើរាងកាយ ផងដែរ។ គួរបញ្ជាក់ថា កាលពី៧ឆ្នាំមុន ឥណ្ឌា បានឈរនៅលំដាប់លេខ៤ ជាប្រទេសគ្រោះថ្នាក់បំផុតសម្រាប់ស្ត្រី៕ **នេះគឺជាប្រទេសដែលគ្រោះថ្នាក់បំផុតសម្រាប់ស្ត្រី ស្ទង់មតិដោយ Thomson Reuters Foundation៖** ១ ឥណ្ឌា. ២ អាហ្វហ្គានីស្ថាន. ៣ ស៊ីរី. ៤ សូម៉ាលី. ៥ អារ៉ាប៊ីសាអ៊ូឌីត. ៦ ប៉ាគីស្ថាន. ៧ សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ. ៨ យេម៉ែន. ៩ នីហ្សេរីយ៉ា. ១០ សហរដ្ឋអាមេរិក។

# សេចក្តីជូនដំណឹងរបស់គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ

https://www.facebook.com/ Royal Embassy of Cambodia in Bangkok  26-06-2018

បងប្អូនពលករខ្មែរដែលធ្វើការនៅក្នុងប្រទេសថៃ ដោយមិនមានឯកសារស្រេបច្បាប់ អាចមកស្នើសុំលិខិតដើរផ្លូវ (Laissé passer )សម្រាប់ធ្វើដំណើរត្រឡប់ទៅប្រទេសកម្ពុជាយើងវិញបាន នៅស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ មុននឹងច្បាប់ថៃគេអនុវត្តថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៨ខាងមុខនេះ។ សូមអគុណ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា
ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ
លេខ: ៦៦៨ គ.ផ.ថ

## សេចក្តីជូនដំណឹង

គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ សូមជម្រាបជូនដំណឹងដល់សាធារណជន ជាពិសេសបងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ជ្រាបថា យោងតាមការជូនដំណឹងពីភាគីថៃ ការិយាល័យបញ្ជាក់អត្តសញ្ញាណនៅទីក្រុងបាងកក ខេត្តរ៉ាក់យ៉ង និងខេត្តប៉ាធុមថានី នឹងត្រូវបញ្ចប់ដំណើរការការងារត្រឹម ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ នេះ។ ចំពោះបងប្អូនពលករដែលបានទទួលឯកសារបញ្ជាក់អត្តសញ្ញាណពីក្រុមការងារនៃគណៈកម្មការផ្តល់ភាពស្របច្បាប់ហើយ អាចទៅបន្តស្នើសុំទិដ្ឋាការការងារ និងសៀវភៅអនុញ្ញាតការងារ នៅតាមការិយាល័យច្រកចេញចូលតែមួយ (OSS)របស់ភាគីថៃ ដែលមានចំនួន៨០កន្លែង ក្នុងនោះ៤កន្លែងនៅទីក្រុងបាងកក និង៧៦កន្លែងនៅទូទាំងប្រទេសថៃ ត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨។ អាស្រ័យហេតុនេះ សូមបងប្អូនពលករដែលមិនទាន់បានមកបញ្ជាក់អត្តសញ្ញាណ ប្រញាប់រួសរាន់មកបញ្ជាក់អត្តសញ្ញាណជាមួយក្រុមការងារនៃគណៈកម្មការផ្តល់ភាពស្របច្បាប់ទាំងបីទីតាំងខាងលើឱ្យបានត្រឹមកាលបរិច្ឆេទដូចបានជម្រាបជូនខាងលើ។

ក្នុងករណីមានចម្ងល់ពាក់ព័ន្ធបញ្ហានេះ សូមទំនាក់ទំនងមកក្រុមការងារនៃគណៈកម្មការផ្តល់ភាពស្របច្បាប់ តាមប្រព័ន្ធទូរស័ព្ទលេខ ០៨២ ៤២២ ០០១១ / ០៨២ ៤២២ ០០២២ និង ០៨២ ៤២២ ០០៤៤។

អាស្រ័យដូចបានជម្រាបជូន សូម សាធារណជន ជាពិសេសបងប្អូនពលករកម្ពុជា ជ្រាបជាព័ត៌មាន។

ថ្ងៃ ចន្ទ ១៣ កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
បាងកក ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០១៨

**ឯកអគ្គរាជទូត និងជាអនុប្រធានគណៈកម្មការ**

**ឡុង ទិសារលោ**

## ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨

## ហ៊ានម្ល៉េះ...ចិនហ៊ានបើកពេស្យាចា លើដីខ្មែរ មិនញញើត ច្បាប់អីបន្តិច

https://www.khmernews.news/ By sitha back June 27, 2018

ព្រះសីហនុ៖ មួយរយៈពេលកន្លងទៅនេះឃើញថា មានរឿងរ៉ាវកើតឡើងជាហូហែរដែលបង្កឡើងដោយជនជាតិចិនដូចជារឿងចិន ជិះឡានទំនើប វាយសន្តិសុខកោះពេជ្រ ,ចិនជិះឡានរ៉ឺម៉ក ធ្វើសកម្មភាពប្លន់ផ្អើលក្រុងព្រះសីហនុ,ចិនចេញសកម្មភាពវាយគ្នាធ្វើឲ្យមានចលាចលគ្រប់បែបយ៉ាងនោះ ស្រាប់តែថ្មីៗនេះចិនបានស្លាកយីហោបនពេស្យាចារទៀត។

ទាក់ទិនបនពេស្យាចារ ដែលកំពុងបើកយ៉ាងគគ្រឹកគគ្រេងសួរថា ចិនអាចមានសិទ្ធធ្វើអ្វីក៏បានគ្រប់បែបយ៉ាងនៅប្រទេសខ្មែរដោយមិនគោរពច្បាប់ប្រទេសទេមែនទេ?។ យ៉ាងណាមិញសមត្ថកិច្ចសង្កាត់លេខ២ និងមន្ត្រីពាក់ព័ន្ធ ខេត្តព្រះសីហនុ បានធ្វើការចុះរុះរើស្លាកយីហោបនពេស្យាចារមួយកន្លែងឈ្មោះ គីគី ដែលមិនមានច្បាប់អនុញ្ញាតត្រឹមត្រូវ។ ប៉ុន្តែនៅមិនទាន់មានការបញ្ជាក់ច្បាស់នៅឡើយពី អាជ្ញាធរនៅតំបន់ភ្នំខៀវនោះថា នឹងមានចំណាត់ការបែបណា។

## ប្រទេសថៃ ៖ ពលករបរទេស ដែលគ្មានឯកសារនឹងត្រូវចាប់ខ្លួនចាប់ពីថ្ងៃទី០១ ខែកក្កដា

https://wmc.org.kh/ ថ្ងៃអង្គារ ទី២៦ ខែមិថុនា ឆ្នាំ២០១៨ លៀ ស៊ីណា

ភ្នំពេញ ៖ ស្ថានទូតកម្ពុជា ប្រចាំនៅប្រទេសថៃ បានចេញសេចក្តីជូនដំណឹងមួយ ដែលអ្នកសារព័ត៌មានទទួលបាននៅថ្ងៃទី២៦ ខែមិថុនានេះ បញ្ជាក់ថា ចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៨ តទៅ អាជ្ញាធរថៃនឹងចុះអនុវត្តច្បាប់ស្តីពី ការគ្រប់គ្រង ការធ្វើការងារ របស់ពលករបរទេស នៅក្នុងប្រទេសនេះ។

ស្ថានទូតកម្ពុជា បញ្ជាក់ទៀតថា ដើម្បីគេចផុតពីការចាប់ខ្លួន បញ្ជូនចេញពីប្រទេសថៃ ក៏ដូចជាការផាកពិន័យ ប្រជាពលរដ្ឋខ្មែរទាំងអស់ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ត្រូវរួសរាន់ទៅស្នើសុំការធ្វើលិខិតបញ្ជាក់អត្តសញ្ញាណ បន្តសុពលភាពប័ណ្ណមិនមែនសញ្ជាតិថៃ ស្នើសុំទិដ្ឋាការស្នាក់នៅ ឲ្យបានមុនថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ សម្រាប់ការិយាល័យបញ្ជាក់អត្តសញ្ញាណកម្ពុជា។ លើសពីនេះស្ថានទូតកម្ពុជា ប្រាប់ឲ្យដឹងថា មជ្ឈមណ្ឌលច្រកចេញចូលតែមួយ (OSS) របស់ភាគីថៃ នឹងបិទបញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ ដោយគ្មានការពន្យាពេលឡើយ។ ចំណែកការិយាល័យបញ្ជាក់អត្តសញ្ញាណជូនពលករកម្ពុជា នឹងបិទបញ្ចប់នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨។

ជាមួយគ្នានេះ ស្ថានទូតកម្ពុជា ប្រចាំនៅប្រទេសថៃ ក៏បញ្ជាក់បន្ថែមដែរថា ចំពោះពលករកម្ពុជា ដែលធ្វើការនៅក្នុងប្រទេសថៃ ដែលមិនមានឯកសារស្របច្បាប់ សូមទំនាក់ទំនងទៅស្ថានទូត ដើម្បីសុំលិខិតធ្វើដំណើរបណ្តោះអាសន្នប្រភេទថ្មី (Laisses-Passer) ធ្វើដំណើរត្រឡប់មកកម្ពុជាវិញ រៀបចំឯកសារស្របច្បាប់ និងត្រឡប់ចូលទៅការនៅប្រទេសថៃវិញតាមរយៈ MOU៕

## ចាប់ពីថ្ងៃទី ១ ខែកក្កដា ឆ្នាំ២០១៨ នេះតទៅប្រសិនបើរកឃើញពលករបរទេសណា ដែលធ្វើការមិនមានប័ណ្ណអនុញ្ញាតការងារ ឬធ្វើការក្រៅពីសិទ្ធិដែលអាចធ្វើបាន

https://www.facebook.com/Royal-Embassy-of-Cambodia-in-Bangkok 27-06-2018

ចាប់ពីថ្ងៃទី ១ ខែកក្កដា ឆ្នាំ២០១៨ នេះតទៅប្រសិនបើរកឃើញពលករបរទេសណា ដែលធ្វើការមិនមានប័ណ្ណអនុញ្ញាតការងារ ឬធ្វើការក្រៅពីសិទ្ធិដែលអាចធ្វើបាន នឹងត្រូវទទួលការផាកពិន័យជាទឹកប្រាក់ចាប់ពី ៥,០០០បាត ទៅ ៥០,០០០បាត ហើយនៅពេលពលករបរទេសបង់ប្រាក់ពិន័យហើយ ពលករនោះនឹងត្រូវបញ្ជូន

ត្រឡប់មកប្រទេសកំណើតវិញ ដោយហាមមិនឱ្យសុំធ្វើការនៅប្រទេសថៃ រយៈពេល២ ឆ្នាំ គិតចាប់ពីថ្ងៃទទួលការផាកពិន័យ។ ចំណែក និយោជកណាដែលប្រើប្រាស់ពលករបរទេសដែលមិនមានប័ណ្ណអនុញ្ញាតការងារ នឹងត្រូវទទួលការពិន័យជាទឹកប្រាក់ ពី ១០,០០០ ទៅ ១០០,០០០បាត ក្នុងពលករម្នាក់ ហើយបើនិយោជកនោះ ប្រព្រឹត្តកំហុសដដែល នឹងត្រូវទទួលទោស ដាក់ពន្ធនាគារ ចំនួន ១ឆ្នាំ ឬពិន័យជាទឹកប្រាក់ ពី ៥០,០០០បាត ទៅ ២០០,០០០បាត ក្នុងពលករម្នាក់ និងបញ្ឈប់មិនឱ្យជួលពលករបរទេសរយៈពេល ៣ឆ្នាំ។ ដូច្នេះ ពលករបរទេសទាំង៣ សញ្ជាតិ ដែលមានបំណងចង់មកធ្វើការនៅក្នុងប្រទេសថៃ គឺត្រូវតែចូលមកធ្វើការតាមរយៈអនុស្សរណៈនៃការយោគយល់គ្នា MOU។

## ក្រសួងការងារថៃប្រកាសមិនពន្យារពេលជូនពលករបទេសទៀតឡើយជួបពលករខុសច្បាប់ចាប់,ផាក និងបញ្ជូនទៅប្រទេសវិញ

http://www.khmerlabour.com/ KhmerLabour 27-06-2018

លោករដ្ឋមន្ត្រីក្រសួងការងារថៃប្រកាស នឹងមិនពន្យារពេលអោយពលករបទេសទៀតឡើយ.! ជួបពលករខុសច្បាប់ចាប់,ផាក់ ,បញ្ជូន នៅព្រឹកថ្ងៃពុធទី27 ខែមិថុនា ឆ្នាំ2018 នេះ លោក អាឌុល សែងសិងកែវ រដ្ឋមន្ត្រីនៃក្រសួងការងារថៃ បានប្រកាសអោយនិយោជិកថៃប្រញាប់នាំពលករបរទេសដែលមិនទាន់ស្របច្បាប់ទៅទំនាក់ទំនងមជ្ឈមណ្ឌលផ្តល់សេវាកម្មស្របច្បាប់ OSS អោយបានចប់រួចរាល់នៅថ្ងៃទី30 ខែមិថុនាឆ្នាំ 2018ខាងមុខនេះ។ ខណៈពេលបច្ចុប្បន្ននេះនៅសល់ត្រឹមតែ4ថ្ងៃទៀតប៉ុណ្ណោះ មជ្ឈមណ្ឌលផ្តល់សេវាកម្មស្របច្បាប់ជូនពលករបទេសនិងបិទឈប់ដំណើរហើយដូច្នេះសូមនយោជិកទាំងប្រញាប់រួសរាន់ឡើង ព្រោះក្រសួងការងារនិងមិនពន្យារពេលទៀតទេ ។ ហើយចាប់ពីថ្ងៃទី01 ខែកក្កដា ឆ្នាំ2018 តទៅបើសិនជាសម្ថិកិច្ចរកឃើញថានយោជិកណាជួលពលករបរទេសខុសច្បាប់ ធ្វើការ ត្រូវមានទោសចាប់,ផាក,និងបញ្ជូនឲ្យវិលត្រលប់ទៅប្រទេសវិញ។

## ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨

## នាយករដ្ឋមន្ត្រីនៃកម្ពុជា៖ ការរកការងារជូនពលរដ្ឋនៅក្រៅប្រទេស គឺជានយោបាយមួយបានធ្វើឲ្យជីវភាពពលរដ្ឋកាន់តែប្រសើរ

http://www.freshnewsasia.com/index.php/ 2018-06-28

**(កំពង់ឆ្នាំង)៖** នាយករដ្ឋមន្ត្រីនៃកម្ពុជា ដែលកំពុងបាញ់ឆ្ពោះអភិវឌ្ឍវិស័យឧស្សាហកម្ម សម្តេចតេជោ ហ៊ុន សែន នៅព្រឹកថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨នេះ បានថ្លែងថា ការរកការងារជូនប្រជាពលរដ្ឋនៅក្រៅប្រទេស គឺជានយោបាយមួយ ក្នុងការស្វែងរកការងារជូនប្រជាពលរដ្ឋ ហើយតាមរយៈការងារនោះ បានធ្វើឲ្យជីវភាពរបស់ប្រជាពលរដ្ឋកាន់តែប្រសើរ។ ក្នុងឱកាសបានបន្តអញ្ជើញជួបសំណេះសំណាលជាមួយ បងប្អូនកម្មករ កម្មការិនី សរុប ២១,៤៦៥នាក់ មកពីរោងចក្រចំនួន១៤ ស្ថិតនៅស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង នៅព្រឹកមិញនេះ សម្តេចតេជោនាយករដ្ឋមន្ត្រី ក៏បានគូសបញ្ជាក់ថា បច្ចុប្បន្នរាជរដ្ឋាភិបាលកម្ពុជា កំពុងតែខិតខំបើកទីផ្សារការងារនៅប្រទេសដ៏ទៃផ្សេងទៀត ដែលមានប្រាក់ចំណូលខ្ពស់ ដូចជានៅមជ្ឈិមបូព៌ាជាដើម។

សម្តេចតេជោ ហ៊ុន សែន បានមានប្រសាសន៍យ៉ាងដូច្នេះថា «**យើងសង្កេតឃើញថា គ្រួសារដែលមានកូនធ្វើជាកម្មកររោងចក្រនៅក្នុងប្រទេស និងទៅធ្វើការនៅក្រៅប្រទេស ឥលូវស្ថានភាពគ្រួសារនោះ បានធូរស្រាលជាងពេលមុន ផ្ទះសម្បែងក៏ល្អជាងពេលមុន ដោយសារតែប្រាក់ចំណូល បានពីរគួបផ្សំគ្នា ដែលម្ខាងបានមកពីឪពុកម្តាយធ្វើវិស័យកសិកម្ម ឬធ្វើមុខរបរផ្សេងៗទៀត ឯម្ខាងទៀតគឺបានមកពីក្មួយៗ ដែលជាកូនចៅ ឬជាប្រពន្ធធ្វើការជាកម្មការិនីរោងចក្រ**»។ និយាយដល់ចំណុចនេះប្រមុខនៃរាជរដ្ឋាភិបាលកម្ពុជា ក៏បានឆ្លើយតបចំពោះអ្នករិះគន់សម្តេចថា ដឹកនាំធ្វើ

ឲ្យប្រជាជនធ្វើការ នៅក្រៅប្រទេសកាន់តែច្រើននោះ សម្ដេចបានបញ្ជាក់ថា វាមិនមែនជារឿងចម្លែកនោះទេ ព្រោះមានប្រទេសជាច្រើន បានបញ្ជូនពលរដ្ឋខ្លួន ទៅធ្វើការនៅក្រៅប្រទេស។ បើតាមសម្ដេចតេជោ ហ៊ុន សែន គ្រាន់តែហ្វីលីពីន មានប្រជាពលរដ្ឋធ្វើការនៅក្រៅប្រទេសជាង១០លាននាក់ ហើយការរកការងារជូនប្រជាពលរដ្ឋ ធ្វើការនៅក្រៅប្រទេសនេះ ជានយោបាយមួយ ជួយរកការងារជូនប្រជាពលរដ្ឋ ហើយសម្ដេចកំពុងចរចាសុំឲ្យកូរ៉េខាងត្បូងបង្កើនការទទួលកម្មករខ្មែរ ឲ្យបានកាន់តែច្រើនថែមទៀត។

សូមជម្រាបថា គិតត្រឹមដើមឆ្នាំ២០១៨ ពលករកម្ពុជាដែលកំពុងតែបំពេញការងារនៅក្រៅប្រទេស មានប្រមាណ១លាន៥ម៉ឺននាក់ ក្នុងនោះនៅប្រទេសថៃមានជាង១លាននាក់ ក្រៅពីនេះមាននៅកូរ៉េខាងត្បូង ជប៉ុន ម៉ាឡេស៊ី និងហុងកុង។ ជាមួយគ្នានេះ សម្ដេចតេជោ ហ៊ុន សែន បានរំលឹកថា ដើម្បីឲ្យកម្មករ កម្មការិនីទទួលបានការងារធ្វើ និងទទួលបានក្ដីសុខដូចពេលបច្ចុប្បន្ននេះ គឺជីដូនជីតា និងឪពុកម្ដាយ បានធ្វើពលីកម្មច្រើនណាស់ជាមួយសម្ដេចតេជោ ហ៊ុន សែន ដែលបានគាំទ្រគណបក្សប្រជាជនកម្ពុជា ធ្វើចលនាជាមួយគណបក្សប្រជាជនកម្ពុជា ដើម្បីបញ្ចប់សង្គ្រាមតាមរយៈនយោបាយឈ្នះឈ្នះ នាំមកនូវសុខសន្តិភាព។ សម្ដេចតេជោ ហ៊ុន សែន ក៏មិនភ្លេចនូវការថ្លែងអំពាវនាវឲ្យប្រជាពលរដ្ឋ ចូលរួមការពារនូវសុខសន្តិភាព ដែលរកមកបានដោយលំបាកនេះ ហើយដើម្បីរក្សាបាននូវសុខសន្តិភាពនេះ គឺបោះឆ្នោតជូនគណបក្សប្រជាជនកម្ពុជា គឺជាការស្រេចទៅហើយ៕

## ពលករបរទេសមានសិទ្ធិប្តូរថៅកែថ្មីបានតាម ព្រះរាជក្រឹត្យច្បាប់គ្រប់គ្រងពលករបរទេសនៃ (ផ,ស2018)

http://www.khmerlabour.com/ KhmerLabour JUNE 27, 2018

យោងតាមព្រះរាជក្រឹត្យនៃច្បាប់គ្រប់គ្រងពលករបរទេសនៃផ,សឆ្នាំ2017 បានកែសម្រួលបន្ថែមនៃផ,សឆ្នាំ 2018 បានកំណត់ដូចខាងក្រោម÷ 1-និយោជិកដំបូងឬក៏និយោជិកថ្មីត្រូវរាយការណ៍ជូនដំណឹងអំពីការជួលពលករបរទេសទៅមន្ត្រីការងារមូលដ្ឋានបានដឹងក្នុងរយៈ15ថ្ងៃចាប់តាំងពីថ្ងៃចាប់ផ្តើមធ្វើការ(តាមមាត្រា13) 2-ពលករបរទេសមានសិទ្ធិអនុញ្ញាតធ្វើការត្រូវរាយការណ៍ជូនដំណឹងការចូលធ្វើការឲ្យមន្ត្រីការងារមូលដ្ឋាន បានដឹងក្នុងរយៈពេល15ថ្ងៃ ចាប់តាំងពីថ្ងៃចូលធ្វើការ(តាមមាត្រា64/2) #បទកំណត់ទោស •មាត្រា103 និយោជិកមិនរាយការណ៍តាមមាត្រា13 ផាកពិន័យប្រាក់មិនលើសពី2ម៉ឺនបាត។ •មាត្រា119/1 ពលករបរទេសមិនអនុវត្តន៍តាមមាត្រា64/2 ផាកពិន័យប្រាក់មិនលើស2ម៉ឺនបាត។ លក្ខខណ្ឌប្តូរថៅកែចំពោះពលករចូលមកធ្វើការតាមរយៈMOU និយោជិកឈប់ជួលឬនិយោជិតស្លាប់បាត់បង់ជីវិត ក្រុមហ៊ុនក្ស័យធន និយោជិតធ្វើទារុណកម្មឬវាយដំលើរៀងកាយពលករ។ និយោជិតមិនគោរពតាមកិច្ចសន្យាជួលឬមិនគោរពតាមច្បាប់គ្រប់គ្រងពលករ។ ឲ្យពលករធ្វើការនៅកន្លែងដែលប្រថុយនិងគ្រោះថ្នាក់ឬកន្លែងធ្វើការស្ថិតក្នុងស្ថានភាពប៉ះពាល់ដល់សុខភាពផ្លូវកាយនិងផ្លូវចិត្តរបស់ពលករ។ និយោជិតថ្មីព្រមចេញថ្លៃប្រាក់សំណងដល់និយោជិតដើមដែលធ្វើងសារឲ្យពលករ។

## អភិបាលខេត្តប៉ៃលិន ស្នើឲ្យប្រទេសថៃ បន្តលក្ខណៈងាយស្រួលដល់ពលករខ្មែរ ក្នុងការធ្វើដំណើរឆ្លងព្រំដែនមកបោះឆ្នោត

http://www.freshnewsasia.com/index.php/ 2018-06-28

**(ចាន់បុរី)៖** នៅថ្ងៃទី២៧-២៨ ខែមិថុនា ឆ្នាំ២០១៨ ប្រតិភូខេត្តប៉ៃលិន ដឹកនាំដោយលោកផាន់ ចាន់ធុល អភិបាលខេត្តប៉ៃលិន បានអញ្ជើញចូលជួបសម្ដែងការគួរសម និងពិភាក្សាការងារ ជាមួយរដ្ឋបាលខេត្តចាន់បុរី ដើម្បីពង្រឹងចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការ រវាងខេត្តនៅជាប់ព្រំដែននៃប្រទេសទាំង២ ឱ្យបានកាន់តែជិតស្និទ្ធថែមទៀត។

កិច្ចពិភាក្សាការងារ ដែលបានធ្វើឡើងនៅ សាលាខេត្តចាន់បុរី ប្រទេសថៃនោះ លោកផាន់ ចាន់ធុល បានសំណូមពរដល់ភាគីថៃ បង្កលក្ខណៈងាយស្រួលសម្រាប់ ពលករខ្មែរដែលកំពុងធ្វើការនៅក្នុងប្រទេសថៃ ដើម្បីបានធ្វើដំណើរឆ្លងដែន មកចូលរួមបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៦ នាថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ ខាងមុខនេះ។ ក្នុងឱកាសនោះ លោកអភិបាលខេត្ត ក៏បានស្នើឲ្យភាគីថៃ បន្តសហប្រតិបត្តិការនូវបញ្ហាមួយចំនួនដូចជា ការប្រើប្រាស់បណ្ណឆ្លងព្រំដែនថ្មី (Border Pass) មិនទាន់បានទូលំទូលាយ តាមកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃប្រទេសទាំងពីរ, ការកសាងស្ពានឆ្លងព្រំដែន, បញ្ហាពលករខ្មែរឆ្លងដែនខុសច្បាប់, ព្រមទាំងបទល្មើសឆ្លងដែននានា, ការនាំចេញកសិផល, និងការធ្វើពាណិជ្ជកម្មឆ្លងដែនរវាងខេត្តចាន់បុរី-ប៉ៃលិន។

ជាការឆ្លើយតបលោក វីធូវ៉ាត់ ស្រីណាម អភិបាលខេត្តចាន់បុរី បានសន្យាខិតខំសហប្រតិបត្តិការ និងដោះស្រាយនូវរាល់សំណូមពរ របស់រដ្ឋបាលខេត្តប៉ៃលិន ក្នុងក្របខណ្ឌសមត្ថកិច្ចរបស់ខេត្ត ចំណែកបញ្ហាមួយចំនួនទៀត លោកបានសន្យាថា នឹងនាំយកនូវរាល់សំណូមពរទាំងអស់នេះ ធ្វើការពិភាក្សាជាមួយមន្ត្រីជំនាញពាក់ព័ន្ធ និងថ្នាក់ដឹកនាំ ព្រមទាំងរាជរដ្ឋាភិបាលថៃដើម្បីរកលទ្ធភាព និងដំណោះស្រាយ ក្នុងការបង្កើនកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំង២ ឱ្យបានកាន់តែល្អប្រសើរឡើង។ ក្នុងឱកាសនោះលោក វីធូវ៉ាត់ ស្រីណាម ក៏បានកោតសសើរដល់រដ្ឋបាលខេត្តប៉ៃលិន ដែលកន្លងមកបានខិតខំពង្រឹងកិច្ចសហប្រតិបត្តិការជាមួយខេត្តជាប់ព្រំដែននៃប្រទេសទាំង២ ដើម្បីរក្សាឱ្យបាននូវសន្តិសុខ សណ្តាប់ធ្នាប់តាមបណ្តោយព្រំដែន និងបម្រើឱ្យផលប្រយោជន៍របស់ប្រជាជន និងប្រទេសទាំង២ ដោយស្មើភាព និងស្មោះត្រង់។

នៅរសៀលថ្ងៃដដែល ក្រោយពីបញ្ចប់កិច្ចពិភាក្សា លោក ផាន់ ចាន់ធុល និងលោក វីធូវ៉ាត់ ស្រីណាម បានអញ្ជើញជាគណអធិបតីក្នុងពិធីបើកពិព័រណ៌ត្បូង និងគ្រឿងអលង្ការ ដែលខេត្តចាន់បុរី ធ្វើឡើងជារៀងរាល់ឆ្នាំ ព្រោះខេត្តនេះជាខេត្តដែលមានឈ្មោះល្បីល្បាញខាងត្បូងធម្មជាតិដ៏មានតម្លៃ ដូចគ្នានឹងខេត្តប៉ៃលិនដែរ៕

## ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨

## លោក ហ៊ុន សែន ថាការរកការងារធ្វើនៅក្រៅប្រទេសជានយោបាយធ្វើឲ្យជីវភាពពលរដ្ឋល្អប្រសើរ

https://www.rfa.org/khmer/news/ ដោយ តាំង សារ៉ាដា 2018-06-28

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្លែងថា ការរកការងារជូនប្រជាពលរដ្ឋ ទៅធ្វើការនៅក្រៅប្រទេស គឺជាគោលនយោបាយ មួយធ្វើឲ្យពលរដ្ឋមានជីវភាពល្អប្រសើរ ហើយបញ្ហាចំណាកស្រុក ជាបញ្ហាសកល។ ពលរដ្ឋ និងសង្គមស៊ីវិល ថា ការលើកឡើងរបស់ លោក ហ៊ុន សែន គឺមិនបានគិតដល់ពលករដែលរងគ្រោះនោះទេ។ ពួកគេជំរុញឲ្យរបបលោកហ៊ុន សែន គួរតែព្យាយាមបង្កើតទីផ្សារការងារឲ្យបានច្រើនសម្រាប់ពលករដែលអត់មានជំនាញជាជាងបញ្ជូនពួកគាត់ ឬទុកឲ្យគាត់បង្ខំចិត្តចំណាកស្រុក ព្រោះពួកគាត់ងាយប្រឈមនឹងរងគ្រោះដោយមូលហេតុផ្សេងៗ។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងការពារខ្លួនជុំវិញរឿងដែលគេរិះគន់បញ្ហាពលរដ្ឋខ្មែរចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេសជាបន្តបន្ទាប់ ក្រោមរបបគ្រប់គ្រងរបស់លោកជាង ៣០ឆ្នាំ ថា បញ្ហាចំណាកស្រុកមិនមែនតែពលរដ្ឋខ្មែរនោះទេ ពោលគឺប្រជាពលរដ្ឋប្រទេសដទៃក៏ធ្វើចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេសដែរ។ ថ្លែងក្នុងពិធីឃោសនារកសន្លឹកឆ្នោតពីកម្មករនៅខេត្តកំពង់ឆ្នាំងនៅព្រឹកថ្ងៃទី២៨ ខែមិថុនា លោក ហ៊ុន សែន អះអាងថា ការរកការងារឲ្យ ប្រជាពលរដ្ឋចេញទៅធ្វើនៅក្រៅប្រទេសនេះ គឺជាគោល នយោបាយ មួយដែលបានធ្វើឲ្យប្រជាពលរដ្ឋ មានជីវភាពល្អប្រសើរ។ «»

ថ្វីដ្បិតតែមានការរិះគន់រឿងបញ្ជូនពលករខ្មែរទៅធ្វើការនៅក្រៅប្រទេសក្តី លោក ហ៊ុន សែន នៅតែមានគម្រោងបញ្ជូនពលករកម្ពុជាទៅធ្វើការនៅប្រទេសមួយចំនួនទៀត ទាំងនៅតំបន់អាស៊ាន និងតំបន់មជ្ឈិមបូព៌ា។

ផ្ទុយពីការលើកឡើងរបស់លោក ហ៊ុន សែន នេះ ពលការិនីខ្មែរនៅប្រទេសថៃម្នាក់ ឈ្មោះ អ៊ុំ ស្រីដាវ រៀបរាប់ថា នាងបានបង្ខំចិត្តធ្វើចំណាកស្រុកចាកចោលផ្ទះសម្បែង និងគ្រួសារជាង៦ឆ្នាំហើយ ប៉ុន្តែនៅតែមិនមានជីវភាពល្អប្រសើរឡើយ។ រយៈពេលជាង ៦ឆ្នាំ ពលការិនីរូបនេះ អះអាងថា នាងរកបានប្រាក់ចំណូលតិចតួចគ្រាន់តែសម្រាប់ដោះទាល់ ឬសម្រាប់ផ្គត់ផ្គង់គ្រួសារ នៅស្រុកកំណើតពីមួយថ្ងៃទៅមួយថ្ងៃប៉ុណ្ណោះ។ «» ពលការិនីរូបនេះ បន្តថា គ្មានអ្នកណាចង់បែកបាក់គ្រួសារនោះទេ ប៉ុន្តែដោយសារតែកត្តាជីវភាព ព្រោះនៅស្រុកកំណើតគ្មានមុខរបរ ឬប្រាក់ឈ្នួលទាប ហើយធ្វើស្រែចម្ការ គ្មានទីផ្សារសម្រាប់លក់កសិផលទើបបង្ខំចិត្តចំណាកស្រុកទាំងប្រថុយប្រថានបែបនេះ។

កន្លងទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈលោក អ៊ិត សំហេង ឲ្យដឹងថា បច្ចុប្បន្នមានពលករកម្ពុជាជាង ១.២លាននាក់ កំពុងធ្វើការងារនៅបរទេស ហើយបាននាំយកប្រាក់ចំណូលមកក្នុងប្រទេសវិញជិត២លានដុល្លារក្នុង១ឆ្នាំ ព្រមទាំងទទួលបានមុខ ជំនាញវិជ្ជាជីវៈ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិផងដែរ។

មន្ត្រីកម្មវិធីនៃមជ្ឈមណ្ឌលសម្ព័ន្ធការងារ និងសិទ្ធិមនុស្ស ហៅកាត់ថា សង់ត្រាល់ (CENTRAL) លោក ឌី ថេហូយ៉ា មានប្រសាសន៍ថា បញ្ហាចំណាកស្រុកមិនអាក្រក់ទាំងអស់នោះទេ ហើយលោកទទួលស្គាល់ថា ប្រទេសណាក៏មានពលករទៅធ្វើការនៅប្រទេសគេផ្សេងៗដែរ ប៉ុន្តែពលករប្រទេសគេមិនមែនធ្វើចំណាកស្រុកដោយបង្ខំចិត្តឡើយ គឺជាជម្រើស ហើយប្រជាពលរដ្ឋគេទៅធ្វើការក្នុងឋានៈជាពលករជំនាញ ឬអ្នកគ្រប់គ្រងតែម្តង ខុសឆ្ងាយពីពលរដ្ឋខ្មែរដែលធ្វើការនៅក្រៅប្រទេសក្នុងឋានៈជាពលករប្រើកម្លាំង និងទទួលបានប្រាក់ខែទាប ហើយងាយរងគ្រោះ។ លោកសង្កេតឃើញថា ពលករខ្លះដែលអាចរកចំណូលបានជួយគ្រួសារនោះ គឺអាស្រ័យលើសំណាងល្អរបស់ខ្លួនដែលជួបថៅកែ និងក្រុមហ៊ុនល្អ ប៉ុន្តែមិនមែនដោយសារ តែប្រព័ន្ធបញ្ជូនពលកររបស់រដ្ឋាភិបាលនោះទេ។ លោកបន្តថា របបលោក ហ៊ុន សែន ក៏មិនគួរប្រៀបធៀបប្រទេសកម្ពុជាជាមួយនឹងប្រទេសហ្វីលីពីនដែរ ព្រោះប្រទេសគេមានប្រព័ន្ធការពារពលករ បានយ៉ាងល្អ ខុសឆ្ងាយពីកម្ពុជា។ «» លោក ឌី ថេហូយ៉ា ឲ្យដឹងដែរថា តាមរបាយការណ៍ស្រាវជ្រាវរបស់ថៃមួយចំនួន បង្ហាញថា លក្ខខណ្ឌការងាររបស់ពលករខ្មែរ គឺ អាក្រក់ជាងគេ បើប្រៀបធៀបជាមួយនឹងប្រទេស ភូមា និងឡាវ ដោយសារ តែពលករខ្មែរ អត់មានជំនាញ និងមិនមានប្រព័ន្ធការការពារ និងការយកចិត្តទុកដាក់ ពីរដ្ឋស្ថាប័នជំនាញ ឬរដ្ឋាភិបាល។ លោក ឌី ថេហូយ៉ា ផ្តល់មតិថា ជម្រើសទីមួយ គឺរដ្ឋាភិបាល គួរតែពិចារណាបង្កើតមុខរបរ និងការងារក្នុងស្រុកឲ្យបានច្រើនសម្រាប់ពលករដែលអត់មានជំនាញ ជាជាងបញ្ជូនពួកគាត់ ឬទុកឲ្យគាត់បង្ខំចិត្តចំណាកស្រុកទៅរកការងារធ្វើការនៅក្រៅប្រទេស។ ជម្រើសទី២ ប្រសិនបើរដ្ឋាភិបាល មិនទាន់អាចកាត់បន្ថយបញ្ហាចំណាកស្រុក បានទេ គឺរដ្ឋាភិបាល ត្រូវពង្រឹងប្រព័ន្ធការពារពលករ តាមដានក្រុមហ៊ុនបញ្ជូន និងទទួលពលករដើម្បីធានាកុំឲ្យពលករចាញ់បោក និងរងគ្រោះ។ ទន្ទឹមគ្នា នេះ រដ្ឋត្រូវផ្តល់វិជ្ជាជីវៈ ឬជំនាញដល់ពលករមុន ចេញទៅធ្វើការ។ បន្ទាប់ពីពលករបញ្ចប់កុងត្រា ការងារ នៅក្រៅប្រទេស រដ្ឋត្រូវរៀបចំគម្រោងធ្វើមាតុភូមិនិវត្តន៍ដើម្បី ផ្តល់ឱកាសឲ្យពលករយក បទពិសោធន៍និងជំនាញនៅប្រទេសផ្សេងៗ មកបម្រើការងារនៅក្នុងស្រុកវិញ។ «»

កាលពីចុងឆ្នាំ២០១៧ ក្នុងរបាយការណ៍រួមគ្នារបស់អង្គការពលកម្មអន្តរជាតិ ហៅកាត់ថា (ILO) និងអង្គការទេសន្តរប្រវេសក៍អន្តរជាតិ ហៅកាត់ថា (IOM) បានរកឃើញថា ពលករចំណាកស្រុកខ្មែរ ៨នាក់ក្នុងចំណោម ១០នាក់ត្រូវបានរំលោភបំពានសិទ្ធិការងារ និង៧នាក់ក្នុងចំណោម ១០នាក់ បានកើតជំងឺផ្លូវចិត្ត។ ពលករខ្មែរចំណាកស្រុកទៅក្រៅប្រទេសត្រូវបានឲ្យដឹងថា មានចំនួន ១លាន ១សែន ៥ម៉ឺននាក់ ដែលក្នុងចំនួននេះ ពលរដ្ឋខ្មែរមានអវត្តមាននៅប្រទេសថៃជាង ១លាននាក់។ តាមរបាយការណ៍ដដែលនេះ ពលការិនី បម្រើការងារតាមផ្ទះ ត្រូវបានរំលោភសិទ្ធិការងារនិងជួបប្រទះការកើតជំងឺផ្លូវចិត្តធ្ងន់ធ្ងរក្រោយពេលពួកគេត្រឡប់មកកាន់ទឹកដីកំណើតវិញ។

ជាការពិតណាស់! ជារៀងរាល់ខែ គេតែឃើញក្រសួងការបរទេសកម្ពុជា ចេញសេចក្ដីប្រកាសព័ត៌មានអំពីការជួយសង្គ្រោះ និងការបញ្ជូនពលករ-ពលការិនីខ្មែរពីក្រៅប្រទេសវិញ ជាបន្តបន្ទាប់ ដោយសារតែពួកគេ ត្រូវបានមេខ្យល់បោកប្រាស់ថៅកែធ្វើបាបជាដើម។ ពលករងគ្រោះទាំងនោះ ភាគច្រើនទៅធ្វើការនៅម៉ាឡេស៊ី ថៃ និងប្រទេសចិន។

អង្គការសង្គមស៊ីវិល ថាមូលហេតុដែលពលរដ្ឋខ្មែរភាគច្រើនបង្ខំចិត្តធ្វើចំណាកស្រុកនេះ គឺបង្ហាញឲ្យឃើញថា រដ្ឋាភិបាលបរាជ័យក្នុងការអនុវត្តគោលនយោបាយដីធ្លី និងកសិកម្ម និងកង្វះការងារ ដែលមានប្រាក់ខែសមរម្យសម្រាប់ពលរដ្ឋធ្វើការនៅក្នុងស្រុក៕

## អាសូរពលករខ្មែរកំពុងធ្វើការជួបគ្រោះអកុសលរថយន្តក្រឡាប់សង្កត់ស្លាប់ប្ដីប្រពន្ធនិងកូន3នាក់

https://www.facebook.com/matemohachunnews/ សារព័ត៌មាន មតិមហាជន 28-06-2018

បន្ទាយមានជ័យ៖ ជីវិតពិតជាផុយស្រួយមែនហើយក៏កើតឡើងមិនមានពេលកំណត់ដែរ។ជាក់ស្តែងពលករខ្មែរ1គ្រួសារខណៈកំពុងធ្វើការស្រាប់តែរថយន្តធំដឹកទំនិញមួយគ្រឿង ដែលកំពុងបើកបរក្រឡាប់សង្កត់ស្លាប់ប្ដីប្រពន្ធ3នាក់ប្ដីប្រពន្ធ និងកូន។ ហេតុការណ៍ដ៏កម្រខាងលើកើតឡើងនៅខេត្តត្រាតប្រទេសថៃកាលពីថ្ងៃទី27 មិថុនា 2018។ ជនរងគ្រោះគេមិនទាន់ស្គាល់អត្តសញ្ញាណទាំងស្រុងនៅឡើយទេគ្រាន់តែដឹងថា អ្នកស្លាប់ឈ្មោះ វ័ន្ត គេទ ប្រុសអាយុ35ឆ្នាំ ហើយពួកគាត់ទាំង3នាក់ជាគ្រួសារតែមួយប្ដី ប្រពន្ធ និងកូន។ អ្នកបើកបររថយន្តបង្ករសារភាពថាហេតុការណ៍ខាងលើកើតឡើង គឺដោយសារខ្លួនងកមួយភាំងម្យ៉ាងចំណុចកើតហេតុជាផ្លូវកោងទើបបួងចង្កូតបញ្ចៀសស្ថានការណ៍មិនទាន់៕ ដោយសារុនកញ្ញា

## និយោជកត្រូវផ្ដល់ម៉ោងឈប់សម្រាកដល់ពលករ ករណីមិនអនុវត្តន៍តាមត្រូវមានទោសពិន័យជាប្រាក់ មិនលើស 2ម៉ឺនបាត

http://www.khmerlabour.com/ KhmerLabour JUNE 28, 2018

នៅថ្ងៃព្រហស្បតិ៍ទី28 ខែមិថុនា ឆ្នាំ2018នេះ លោកអាណានថៃ អ៊ូថៃផាត់ធីប អគ្គនាយកដ្ឋាននៃក្រសួងគាំពារសិទ្ធិការងារនិងសុខមាលភាពពលករប្រទេសថៃ បានមានប្រសាសន៍ប្រកាសតឿនដល់និយោជកថៃ គ្រប់រូបត្រូវផ្តល់ម៉ោងឈប់សម្រាកយ៉ាងតិចណាស់ក្នុងថ្ងៃមួយម៉ោងដល់ពលករ បន្ទាប់ពីធ្វើការមិនលើសពី5ម៉ោងដើម្បីអោយពលករបានសម្រាប់បំបាត់ការនឿយហត់និងភាពតានតឹងការងារ ដើម្បីបង្ការគ្រោះថ្នាក់ដែលកើតឡើងដោយសាររាងកាយហត់នឿយនៅពេលដែលពលករធ្វើការច្រើនម៉ោងជាប់គ្នា ត្រូវទុកពេលខ្លះដើម្បីអោយពលករទៅធ្វើធុរៈផ្ទាល់ខ្លួន។ ទាំងនេះនិយោជកនិងពលករអាចសម្រេចគ្នាអំពីម៉ោងឈប់សម្រាកដោយបែងចែកម៉ោងសម្រាកក្នុងរយៈពេលប៉ុន្មានដងក៏បានប៉ុន្តែមិនឲ្យតិចពីមួយម៉ោងក្នុងមួយថ្ងៃ។ អគ្គនាយកដ្ឋាននៃក្រសួងគាំពារសិទ្ធិការងារនិងសុខុមាលភាពពលករ សូមអោយនិយោជិកទាំអស់អនុវត្តន៍ឲ្យត្រឹមត្រូវ តាមច្បាប់គាំពារសិទ្ធិការងារ ក្នុងករណីមិនអនុវត្តន៍តាមច្បាប់ត្រូវមានទោសផាកពិន័យជាប្រាក់មិនលើស 2ម៉ឺនបាត។ ចំពោះនិយោជកឬពលករមានចម្ងល់សូម ទំនាក់ទំនងមកកាន់ទូរស័ព្ទនាយកកដ្ឋាននៃក្រសួងគាំពារសិទ្ធិការងារ និងសុខុមាលភាពពលករ តាមរយៈលេខ1506 ចុចលេខ3 ។